Woori Financial Group, Korea

WOORI BANK

របាយការណ៍ប្រចាំឆ្នាំ2022

ធនាគារ អ៊ូរី ជម្រើសហិរញ្ញវត្ថុដ៏ឆ្លាតវៃរបស់អ្នក!



មាតិកា

I
អំពីស្ថាប័ន

យើងជានរណា? 8
សារពីប្រធានក្រុមប្រឹក្សាភិបាល 10
សារពីអគ្គនាយកប្រតិបត្តិ 12
ព្រឹត្តិការណ៍សំខាន់ប្រចាំឆ្នាំ 14
អំពីធនាគារអ៊ូរី 16

II
អភិបាលកិច្ច សាជីវកម្ម

រចនាសម្ព័ន្ធរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក 20
អំពីក្រុមប្រឹក្សាភិបាល 22
អំពីគណៈគ្រប់គ្រងជាន់ខ្ពស់ 26
ការគ្រប់គ្រងហានិភ័យ 32
ការប្រតិបត្តិតាម 34
សវនករផ្ទៃក្នុង 35

III
លទ្ធផលសម្រេចបាន

ធនាគារ អ៊ូរី បានក្លាយខ្លួនជា ធនាគារពាណិជ្ជជាផ្លូវការ 38
ការបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត 40
ដៃគូអាជីវកម្មឌីជីថលថ្មី 40
ការបើកដំណើរការសាខាថ្មី 41
ការដាក់ដំណើរការផលិតផលថ្មីៗ 41

IV
ចំនុចសំខាន់ៗ អំពីអាជីវកម្ម 2022

ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ 44
របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស 48
សក្តីកម្មរបស់បុគ្គលិក 49
ពត៌មានសំខាន់ៗ 52
អំពីភាពជោគជ័យរបស់អតិថិជន 58
អំពីផលិតផល និងសេវាកម្ម 60
របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម 78
បណ្តាញសាខា និងតំបន់ប្រតិបត្តិការ 80

V
របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ 84
របាយការណ៍ចំណូលលម្អិត 85
របាយការណ៍បម្រែបម្រួលមូលធន 86
របាយការណ៍លំហូរសាច់ប្រាក់ 87
របាយការណ៍របស់សវនការឯករាជ្យ 88
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល 92



ធនាគារ អ៊ូរី
ជម្រើសហិរញ្ញវត្ថុដ៏ឆ្លាតវែរបស់អ្នក!

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺជាធនាគារពាណិជ្ជដែលមានការរីកចម្រើនលឿនបំផុតមួយនៅកម្ពុជាដែលមានបទពិសោធន៍ ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជាប្រកបដោយវិជ្ជាជីវៈខ្ពស់ និងបានពង្រីកបណ្តាញប្រតិបត្តិការរហូតដល់138សាខាទូទាំងប្រទេស។

អំពីស្ថាប័ន

យើងជានរណា? 8
សារពីប្រធានក្រុមប្រឹក្សាភិបាល 10
សារពីអគ្គនាយកប្រតិបត្តិ 12
ព្រឹត្តិការណ៍សំខាន់ប្រចាំឆ្នាំ 14
អំពីធនាគារអ៊ូរី 16

យើងជានរណា?

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺជាធនាគារពាណិជ្ជដែលឈានមុខគេក្នុងប្រទេសកម្ពុជា ហើយក៏ជាសមាជិកគ្រួសាររបស់ធនាគារពាណិជ្ជអ៊ូរីដែលជាធនាគារឈានមុខគេមួយនៅប្រទេសកូរ៉េដែលត្រូវបានបង្កើតឡើងនៅឆ្នាំ1899 មកម្ល៉េះ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានប្តេជ្ញាធ្វើឱ្យជីវិតអតិថិជន កាន់តែប្រសើរ តាមរយៈដំណោះស្រាយហិរញ្ញវត្ថុងាយៗ និងវៃឆ្លាតដោយភ្ជាប់ជាមួយបច្ចេកវិទ្យាទាន់សម័យ ជាមួយការផ្តល់ជូននូវផលិតផល និងសេវាដែលឆ្លើយតបនឹងតម្រូវការអតិថិជនគោលដៅរបស់យើង។

នាខែវិច្ឆិកា ឆ្នាំ2021 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានទទួលអាជ្ញាបណ្ណជាធនាគារពាណិជ្ជ ពីធនាគារជាតិនៃកម្ពុជា និងបានដាក់ដំណើរការជាផ្លូវការជាធនាគារពាណិជ្ជចាប់ពីខែមករា ឆ្នាំ 2022។

យើងកំពុងតែជម្រុញឱ្យមានកំណើនលូតលាស់ ជួយបង្កើតការងារ អភិវឌ្ឍន៍សហគមន៍ ជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ច និងដំណោះស្រាយបញ្ហាប្រឈមមុខធំៗនៅក្នុងសង្គមជាមួយនឹងការបន្តការគ្រប់គ្រងហានិភ័យ និងការសងត្រឡប់ទៅវិញជូនអតិថិជន និងភាគទុនិករបស់យើង។ យើងជឿជាក់ថា យើងអាចទទួលបានជោគជ័យនៅពេលដែលអតិថិជនម្នាក់ៗ ក្រុមហ៊ុននានា សហគមន៍ និងបុគ្គលិកដែលយើងបានបម្រើសេវាកម្មជូនអាចឈានដល់ភាពជោគជ័យរបស់ពួកគេ។

គិតត្រឹមខែធ្នូ ឆ្នាំ2022 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បាន ពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ 138(1) សាខាទូទាំងប្រទេស។

(1) ចំនួនសាខាដែលកំពុងប្រតិបត្តិការ គិតត្រឹមខែធ្នូឆ្នាំ២០២២ មានចំនួន១៣៨សាខា ហើយមានសាខាមួយទៀតដែលបានកែលម្អរួចរាល់ ដើម្បីដំណើរការ ដោយរង់ចាំការអនុម័តលើអាជ្ញាបណ្ណពី ធនាគារជាតិនៃ កម្ពុជា។



សារពី
ប្រធានក្រុមប្រឹក្សាភិបាល



លោក ចង់ សុងអ៊ូក
ប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

យោងតាមរបាយការណ៍នៃធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករណ៍ថាកម្ពុជានឹងមានកំណើនសេដ្ឋកិច្ចនៅក្នុងស្រុកលើការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ និងកំណើនខ្ពស់ក្នុងវិស័យសេវាកម្មក្នុងអត្រា 5.5% ក្នុងឆ្នាំ 2023 និង 6.0% ក្នុងឆ្នាំ 2024 ។

ដូច្នេះយើងទាំងអស់បាននឹងកំពុងប្រឹងប្រែងបំពេញការងារដ៏អស្ចារ្យដើម្បីសម្រេចឱ្យបានលទ្ធផលកាន់តែប្រសើរនាពេលអនាគត។ ជាមួយគ្នានេះដែរ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានចាប់យកឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការស្នូលនិងដំណើរការអាជីវកម្មឱ្យឈរនៅចំណុចកំពូលក្នុងទីផ្សារហិរញ្ញវត្ថុ។

យោងតាមរបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ 2022 របស់ធនាគារជាតិនៃកម្ពុជា បានបង្ហាញថាផលប័ត្រប្រាក់កម្ចីរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុបានកើនឡើងដល់ជាង 47 ពាន់លានដុល្លារអាមេរិក គិតជាភាគរយមានការកើនឡើង 16.8% ។ ប្រាក់បញ្ញើក៏បានកើនឡើងដល់ 38 ពាន់លានដុល្លារអាមេរិក កើនឡើង 7.3% ។ សរុបមក វិស័យធនាគាររបស់កម្ពុជាបានបន្តកើនឡើងក្នុងកំឡុងឆ្នាំ 2022 ធៀបនឹងឆ្នាំ 2021 ទោះបីជាមានការផ្ទុះឡើងនៃជំងឺរាតត្បាត កូវីដ19 និងសង្គ្រាមនៅប្រទេសអ៊ុយក្រែនក៏ដោយ។

គិតត្រឹមខែធ្នូ ឆ្នាំ 2022 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក យើងសម្រេចបានទ្រព្យសកម្មសរុបចំនួន 1.4 ពាន់លានដុល្លារអាមេរិក និងប្រាក់ចំណូលសុទ្ធចំនួន 46លានដុល្លារអាមេរិក ជាមួយនឹងអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មសរុបស្មើនឹង3.5%។ វាកើនឡើងយ៉ាងខ្លាំងរហូតដល់ឆ្នាំ2021 ប៉ុន្តែឆ្នាំ2022 អត្រាកំណើនបានបង្ហាញពីការថមថយ ហើយជាពិសេសអនុបាតចំណេញសុទ្ធធៀបជាមួយទ្រព្យសកម្មសរុបបានធ្លាក់ចុះក្រោម 4%ជាលើកដំបូង។

ទោះបីជាមានផលលំបាកក្នុងទីផ្សារ តែសមិទ្ធផលគួរឱ្យកត់សម្គាល់ដែលយើងទទួលបានរហូតមកដល់ពេលនេះ គឺដោយសារតែធនធានមនុស្សដ៏ប៉ិនប្រសប់ និងវិរិយមាំរបស់យើងដែលបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការនាំមកនូវទិន្នផល និងលទ្ធផលជាវិជ្ជមានជាបន្តបន្ទាប់។

ឆ្នាំ 2022 នេះ គឺជាឆ្នាំដំបូងដែលបង្កើតគ្រឹះសម្រាប់ធនាគារពាណិជ្ជ ហើយឆ្នាំ 2023 យើងនឹងនៅតែបន្តកំណើនដ៏រឹងមាំទាំងបរិមាណនិងគុណភាព ដូច្នេះយើងអាចក្លាយជាស្ថាប័នហិរញ្ញវត្ថុកំពូលមួយក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុកំពូលទាំង 5 នៅកម្ពុជាក្នុងរយៈពេល 3 ឆ្នាំ។ ការបំប្លែងទៅជាធនាគារពាណិជ្ជ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានផ្តល់នូវផលិតផល និងសេវាកម្មកាន់តែច្រើនធ្វើឱ្យការប្រើប្រាស់សេវាធនាគារកាន់តែមានភាពងាយស្រួលជាងមុនដែលការរីកចម្រើនជាបន្តបន្ទាប់។ លទ្ធផលការងាររបស់យើងទាំងនេះ គឺដោយសារការធ្វើសកម្មភាពយ៉ាងសកម្ម និងបត់បែនការអនុវត្តភ្លាមៗក្នុងក្រុមហ៊ុន ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងដែលប្រែប្រួលឥតឈប់ឈរ។ ហើយយើងក៏កំពុងនៅតែខំប្រឹងជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំបែបនេះដែលនឹងអាចសម្រេចបាននូវលទ្ធផលសំខាន់ៗនាឆ្នាំខាងមុខនេះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកគ្រប់គ្រង និងបុគ្គលិក ធនាគារ អ៊ូរី (ខេមបូឌា) ម.ក របស់យើងដែលលះបង់ការខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីជំរុញឱ្យមានការរីកលូតលាស់នៃក្រុមហ៊ុនរបស់យើង។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនរបស់យើងដែលបង្ហាញពីការគាំទ្រជារៀងរហូត។ ខ្ញុំមានការជឿជាក់ និងប្តេជ្ញាចិត្តយ៉ាងខ្លាំងក្នុងការផ្តល់នូវអនុសាសន៍ និងការណែនាំដ៏ល្អបំផុតក្នុងការកសាងធនាគារ អ៊ូរី (ខេមបូឌា) ម.ក ឱ្យក្លាយជាស្ថាប័នហិរញ្ញវត្ថុកំពូលនៅកម្ពុជា។



លោក ចង់ សុងអ៊ូក
ប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ចំនួនទ្រព្យសកម្មសរុប
1,442លានដុល្លារអាមេរិក
(កំណើន 24%)

ចំនួនឥណទានសរុប
1,183 លានដុល្លារអាមេរិក
(កំណើន 27%)

ចំនួនប្រាក់បញ្ញើសរុប
353 លានដុល្លារអាមេរិក
(កំណើន 63%)

សារពី
អគ្គនាយកប្រតិបត្តិ



លោក គីម ហុងជូ
អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

យើងមើលទៅលើស្ថានភាពទីផ្សារនាពេលបច្ចុប្បន្ន បម្រែបម្រួលនៃបរិយាកាសទីផ្សារ អត្រាកំណើនសេដ្ឋកិច្ចសកលបានវិលត្រឡប់ទៅភាពល្អប្រសើរវិញនៅឆ្នាំ 2021 បន្ទាប់ពីជំងឺរាតត្បាតកូវីដ19 ប៉ុន្តែចាប់តាំងពីពេលនោះផងដែរ វាបែរជាមានការកើនឡើងយឺតៗទៅវិញ។ ប្រទេសចិនដែលមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយកម្ពុជាយើងក៏ទទួលរងការធ្លាក់ចុះយ៉ាងខ្លាំងនូវអត្រាកំណើនរបស់ខ្លួន បន្ទាប់ពីជំងឺរាតត្បាតកូវីដ19 នេះបើយោងតាមសេចក្តីប្រកាសអំពីការស្តារឡើងវិញនៃជំងឺរាតត្បាតកូវីដ19។ ការធ្លាក់ចុះនោះត្រូវបានគេរំពឹងថានឹងត្រលប់ទៅរកការកើនឡើងវិញនៅឆ្នាំ 2023 យ៉ាងណាមិញ នៅមានចម្ងល់ថាតើកំណើននេះនឹងបន្តឬយ៉ាងណា។

រីឯអត្រាកំណើនជាអតិបរមារបស់សេដ្ឋកិច្ចកម្ពុជាត្រឹមឆ្នាំ 2019 គឺប្រមាណជា 7% ប៉ុន្តែវាបានធ្លាក់ចុះវិញនៅ -3.1% ក្នុងឆ្នាំ 2020 ដោយសារជំងឺរាតត្បាតកូវីដ-19។ ចាប់តាំងពីពេលនោះមក វាក៏ស្ថិតនៅលើគន្លងនៃការងើបឡើងវិញផងដែរ។ សេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងងើបឡើងវិញបានល្អ បន្ទាប់ពីការផ្ទុះជំងឺកូវីដ19 ហើយកំណើនសេដ្ឋកិច្ចប្រទេសនេះនៅឆ្នាំ2022 ត្រូវបានព្យាករណ៍ថានឹងកើន 4.8%។ នេះបើតាមការវាយតម្លៃរបស់ធនាគារពិភពលោកដែលទើបតែបានចេញផ្សាយរបាយការណ៍ថ្មីមួយស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា។ ការព្យាករណ៍បាននិយាយថាកំណើននេះនឹងបន្តនៅឆ្នាំ 2023 ប៉ុន្តែគ្មាននរណាម្នាក់អាចធានាលទ្ធផលនោះបានទេ។

នៅក្នុងឆ្នាំ2022 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ទទួលបានកំណើនរហូតដល់ 1,442.18 លានដុល្លារអាមេរិកលើទ្រព្យសកម្មដែលស្មើនឹង24% ពី 1,162.46 លានដុល្លារអាមេរិកកាលពីឆ្នាំមុន។ លើសពីនេះ សំវៀតឥណទានរបស់យើងមានការកើនឡើង 26% ពី 927.83 លានដុល្លារអាមេរិកកាលពីឆ្នាំមុនដែលស្មើនឹង 1,183.32 លានដុល្លារអាមេរិក។ ប្រាក់បញ្ញើរបស់យើងក៏បានកើនឡើងដល់ 353.46 លានដុល្លារអាមេរិកក្នុងឆ្នាំ2022 ស្មើនឹង63% ពី 217.46 លានដុល្លារអាមរិកក្នុងឆ្នាំ2021។

នៅក្នុងខែធ្នូ ឆ្នាំ 2022 ធនាគារយើងមានកំណើនបុគ្គលិករហូតដល់ទៅជាង 4,000នាក់ ដែលបានខំប្រឹងបម្រើការនឹងប្តេជ្ញាចិត្តក្នុងការរួមចំណែកលើកកម្ពស់ជីវភាពរបស់អតិថិជន ក៏ដូចជាសង្គម ហើយក៏ផ្តោតខ្លាំងទៅលើការអភិវឌ្ឍន៍ជំនាញការងារ និងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេតាមរយៈការបណ្តុះបណ្តាលពង្រឹងសមត្ថភាពផងដែរ។ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនរហូតដល់ 138 សាខានៅទូទាំងប្រទេស។ ដោយរង់ចាំដំណើរការនៃផ្តល់អាជ្ញាបណ្ណការពង្រីកសាខាបន្ថែមក្នុងផែនការឆ្នាំ 2022 ក្នុងខណ្ឌដូនពេញ និងខណ្ឌសែនសុខ សាខាទាំងពីរបានត្រៀមរួចរាល់សម្រាប់បម្រើអតិថិជនផងដែរ។ លើសពីនេះ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានពង្រីកនូវផលិតផល និងសេវាកម្មថ្មីៗ ដោយបន្ថែមកម្ចីអាជីវកម្មខ្នាតតូចនិងមធ្យម និងកម្ចីពាណិជ្ជកម្ម គណនីសន្សំធ្លឹស គណនីសន្សំធែនការធ្លឹស និងថេប ប៊ែងយីង សម្រាប់បម្រើដល់អតិថិជនរបស់យើង ជាពិសេសការពង្រឹងសេវាធនាគារតាមទូរសព្ទ ការរីកចម្រើនរបស់ពាណិជ្ជករ KHQR ដើម្បីផ្តល់សេវាធនាគារឱ្យកាន់តែល្អប្រសើរ និងងាយស្រួលដល់អតិថិជនរបស់យើង។

ឆ្នាំ 2022 គឺជាឆ្នាំដ៏អស្ចារ្យសម្រាប់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលជាឆ្នាំដំបូងដំណើរការជាធនាគារពាណិជ្ជ។ យើងបានសម្រេច និងចែកចាយដល់នូវកិច្ចការសង្គម និងមនុស្សធម៌ (CSR) ជាច្រើន ដើម្បីនាំមកនូវការរីកចម្រើនប្រកបដោយចីរភាពដល់សង្គមកម្ពុជាតាមការណែនាំរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងវិស័យអប់រំតាមរយៈការចុះអនុស្សារណៈជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ក្នុងការផ្តល់អាហារូបករណ៍ចំនួន 100 ដល់សិស្សានុសិស្សនៅក្នុង 5មុខវិជ្ជាសម្រាប់ឆ្នាំ2022។ ជាងនេះទៅទៀត យើងបានបណ្តុះបណ្តាលដោយជោគជ័យនូវអ្នកបន្តវេនក្នុងកម្មវិធីជំនាន់ទី 1 (Incubation Program) ដើម្បីផ្តល់ការអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈនៅក្នុងធនាគាររបស់យើង។ វាផ្តល់នូវការកែលម្អយ៉ាងសំខាន់លើការកសាងសមត្ថភាពទេពកោសល្យរបស់ពួកគេ។

អាចនិយាយថា ឆ្នាំ 2022 គឺជាការចាប់ផ្តើមនៃដំណើរដ៏រំភើបមួយក្នុងនាមជាធនាគារពាណិជ្ជរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក របស់យើង។ ទោះស្ថិតក្នុងឆ្នាំដ៏លំបាកមួយទៀត យើងមានសុទិដ្ឋិនិយមចំពោះការបន្តដំណើរទៅមុខនៃដំណើរការអាជីវកម្មរបស់យើង។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័ត្រចំពោះអតិថិជន ដៃគូសហការ និងធនាគារជាតិនៃកម្ពុជាដែលតែងតែបន្តការគាំទ្រ និងជឿជាក់យ៉ាងមុតមាំមកលើយើងកន្លងមក។ ទន្ទឹមនឹងនេះ ខ្ញុំសូមសម្តែងការអរគុណយ៉ាងកក់ក្តៅចំពោះបុគ្គលិកធនាគារ អ៊ូរី (ខេមបូឌា) ម.ក ជាង 4,000 នាក់ដែលខិតខំប្រឹងប្រែងលះបង់អស់ពីកម្លាំងកាយចិត្តក្នុងការធ្វើការងារប្រកបដោយប្រសិទ្ធភាព។



លោក គីម ហុងជូ
អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

1990s

ត្រូវបានបង្កើតឡើងជា
សកម្មភាពមួយរបស់
កម្មវិធីអភិវឌ្ឍន៍តំបន់របស់
អង្គការទស្សន:
ពិភពលោកកម្ពុជា

2000

ត្រូវបានដាក់ឈ្មោះថា
កម្មវិធីអភិវឌ្ឍន៍ សហគ្រាសខ្នាតតូច
ដែលជាកម្មវិធីឥណទានមួយរបស់
អង្គការទស្សន:ពិភពលោកកម្ពុជា

2003

បានក្លាយជាក្រុមហ៊ុន
មួយបានចុះបញ្ជីដោយមាន
ឈ្មោះថាជា វីសិនហ្វាន់
(ខេមបូឌា) អិលធីឌី
នៅក្រសួងពាណិជ្ជកម្ម

2004

បានទទួលអាជ្ញាបណ្ណពី
ធនាគារជាតិនៃកម្ពុជា
ដោយមានឈ្មោះថាជា
វីសិនហ្វាន់ (ខេមបូឌា)
អិលធីឌី

2011

បានទទួលអាជ្ញាបណ្ណ
ប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ
ពីធនាគារជាតិនៃកម្ពុជា

2016

- ការសម្ពោធជាផ្លូវការអគារ
ការិយាល័យកណ្តាលថ្មី
- ទទួលបានការទទួលស្គាល់ថាជា
ស្ថាប័នបានគោរពតាមគោលការណ៍
ការពារអតិថិជន យ៉ាងខ្ជាប់ខ្ជួន
និង ត្រូវតាមស្តង់ដាអន្តរជាតិពី
Smart Campaign

2017

- ទទួលបានវិញ្ញាបនបត្រអនុលោម
ភាពសារពើពន្ធ ប្រភេទមាស
ពីអគ្គនាយកដ្ឋានពន្ធដារ
នៃព្រះរាជាណាចក្រកម្ពុជា
- ជាសមាជិកស្ថាបនិកនៃគម្រោង
សេវាផ្ទេរមូលនិធិភ្លាមៗ របស់
ធនាគារជាតិនៃកម្ពុជា

2018

- ផ្លាស់ប្តូរម្ចាស់ភាគហ៊ុន
(មិថុនា 2018) ទៅជា
ធនាគារ អ៊ូរី នៃប្រទេស
កូរ៉េ ខាងត្បូង
- ប្តូរឈ្មោះទៅជា
ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក

2019

- បានទទួលការអនុម័តជាគោលការណ៍
ពីធនាគារជាតិនៃកម្ពុជា លើសំណើសុំ
គួបបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថាន
មីក្រូហិរញ្ញវត្ថុ អ៊ូរី ហ្វាយនែន
ខេមបូឌា ភីអិលស៊ី

2020

- ខែកុម្ភៈ: ឆ្នាំ2020 ដំណើរការគួបបញ្ចូលគ្នា
ដោយជោគជ័យរវាងគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី
ហ្វាយនែន ឯ.ក និងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន
(ខេមបូឌា) ភីអិលស៊ី
- ខែធ្នូ ឆ្នាំ2020 បញ្ចូលដើមទុន 100 លាន
ដុល្លារអាមេរិក បន្ថែមពីម្ចាស់ភាគហ៊ុន
ធនាគារ អ៊ូរី

2021

- ខែវិច្ឆិកា ឆ្នាំ2021 ទទួលបាន
អាជ្ញាបណ្ណថាជាធនាគារពាណិជ្ជពី
ធនាគារជាតិនៃកម្ពុជា និងខែធ្នូ
ឆ្នាំ2021 ទទួលបានសិទ្ធិក្នុងការ
ក្លាយខ្លួនទៅជាធនាគារពាណិជ្ជ
ហើយផ្លាស់ប្តូរឈ្មោះទៅជា
ធនាគារអ៊ូរី (ខេមបូឌា) ម.ក

2022

ដាក់សម្ពោធជាធនាគារពាណិជ្ជជាផ្លូវការ
នៅថ្ងៃទី 03 ខែមករា ឆ្នាំ2022 ។
គិតត្រឹម ខែធ្នូ ឆ្នាំ2022 ធនាគារ អ៊ូរី
(ខេមបូឌា) ម.ក មាន៖

ចំនួនទ្រព្យសកម្មសរុប
1,442 លានដុល្លារអាមេរិក
(កំណើន 24%)

ចំនួនប្រាក់បញ្ញើសរុប
353 លានដុល្លារអាមេរិក
(កំណើន 63%)

ចំនួនឥណទានសរុប
1,183 លានដុល្លារអាមេរិក
(កំណើន 26%)

អំពី ធនាគារ អ៊ូរី

ធនាគារ អ៊ូរី គឺជាម្ចាស់ភាគហ៊ុនតែមួយគត់របស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ជាធនាគារពហុជាតិកូរ៉េដែលមានទីស្នាក់ការកណ្តាលនៅទីក្រុង សេអ៊ូល ប្រទេសកូរ៉េខាងត្បូង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ1899 ហើយជាធនាគារពាណិជ្ជឈានមុខគេមួយនៅប្រទេសកូរ៉េដែលមានបណ្តាញអន្តរជាតិដ៏ធំទូលាយនៅទូទាំងពិភពលោក ផ្តល់ជូននូវការវិនិយោគលើវិស័យពាណិជ្ជកម្ម និងវិស័យធនាគារយ៉ាងទូលំទូលាយតាមរយៈបណ្តាញប្រតិបត្តិការសកលចំនួន 465 សាខានៅក្នុង 24 ប្រទេស។


465
បណ្តាញប្រតិបត្តិការសកល

24
ប្រទេស

ឆ្នាំ 2022 គឺជាខួបទី

123 Years ANNIVERSARY OF WOORI BANK

រក្សាបាននូវប្រវត្តិសាស្ត្រកន្លងមកជាងមួយរយឆ្នាំ។ ធនាគារមានបំណងបន្តរីកលូតលាស់សម្រាប់សតវត្សមួយទៀត បន្តទៅមុខទៀត ដើម្បីក្លាយជាម៉ាកយីហោហិរញ្ញវត្ថុដែលតែងតែនៅទីនេះសម្រាប់លោកអ្នក។




II

អភិបាលកិច្ច សាជីវកម្ម

រចនាសម្ព័ន្ធរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក 20
អំពីក្រុមប្រឹក្សាភិបាល 22
អំពីគណៈគ្រប់គ្រងជាន់ខ្ពស់ 26
ការគ្រប់គ្រងហានិភ័យ 32
ការប្រតិបត្តិតាម 34
សវនករផ្ទៃក្នុង 35

រចនាសម្ព័ន្ធរបស់
ធនាគារ អ៊ីរី (ខេមបូឌា) ម.ក

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022



អំពី ក្រុមប្រឹក្សាភិបាល



លោក ចង់ សុងអ៊ូក

ប្រធានក្រុមប្រឹក្សាភិបាល

លោក ចង់ ទទួលបានបរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យកូរ៉េ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក ធុរកិច្ច ពាណិជ្ជកម្មនៅសាកលវិទ្យាល័យឌូក។

លោកបានចាប់ផ្តើមអាជីពការងារនៅធនាគារ អ៊ូរី ប្រមាណជា20ឆ្នាំមកហើយ ចាប់តាំងពីឆ្នាំ1997។ ជាដំបូងបង្អស់ លោកបានបំពេញការងារនៅការិយាល័យសាខាដែលធ្វើឱ្យលោកទទួលបាននូវចំណេះ និង ជំនាញល្អៗជាច្រើន ក្នុងការចាប់យកតួនាទីថ្មីជាប្រធានផ្នែករតនាគារ បន្ទាប់មកក្លាយជាប្រធានផ្នែកគ្រប់គ្រងហានិភ័យជាន់ខ្ពស់។ ចាប់តាំងពីឆ្នាំ2012 គាត់ត្រូវបានតែងតាំងក្នុងតំណែងជាថ្នាក់ដឹកនាំនៅក្នុង នាយកដ្ឋានយុទ្ធសាស្ត្រពាណិជ្ជកម្មសកល បន្ទាប់មកផ្ទេរមកគ្រប់គ្រងសាខាហេប៉ូជុងហ្គាង ហើយបច្ចុប្បន្ននេះលោកកាន់តួនាទីជាប្រធានគ្រប់គ្រងទូទៅនៅក្នុង នាយកដ្ឋានគាំទ្រពាណិជ្ជកម្មសកល។

លោក ចង់ ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល ចាប់តាំងពី ធនាគារ អ៊ូរី បានបំប្លែងខ្លួនទៅជាធនាគារពាណិជ្ជ។



លោក គីម ហុង ជូ

ម្ចាស់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកប្រតិបត្តិ

លោក គីម ហុង ជូ បានរៀនចប់ជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យជាតិ សេអ៊ូលនៃប្រទេសកូរ៉េ។ លោកបានចូលរួមបម្រើការងារជាមួយធនាគារ អ៊ូរី និងមានទូរបទពិសោធន៍យ៉ាងច្រើនលើវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសលោកមានឯកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មសកល។ លោកបានធ្វើការនៅនាយកដ្ឋានយុទ្ធសាស្ត្រសកលជាង 8 ឆ្នាំ។ លោកបានចូលរួមចំណែកក្នុងប្រតិបត្តិការទិញលក់ភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុម្លិះហ្វាយនែន ក្នុងឆ្នាំ 2014 និងក្រោយមកបានរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ម.ក និង គ្រឹះស្ថានដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក នៅដើមឆ្នាំ 2020។ លោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុនៃ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។ នៅចុងឆ្នាំ 2021 ក្រោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម លោកក៏បានក្លាយជាភាគទុនិករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនឈ្មោះថា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក)។

នៅដើមឆ្នាំ2022 **លោក គីម ហុង ជូ** ត្រូវបានតែងតាំងជាអគ្គនាយកប្រតិបត្តិថ្មីនៃ**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក.**។



លោកស្រី ហ្វីអូណា វ៉ាយត៍

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោកស្រី វ៉ាយត៍ ដែលមានសញ្ជាតិនូវែលសេឡង់បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** (រួមទាំងអតីតវីសិនហ្វាន់ ខេមបូឌា) តាំងពីខែមករា ឆ្នាំ2013។ លោកស្រីមានបទពិសោធន៍ 10ឆ្នាំ ទាក់ទងនឹងការរៀបចំបទប្បញ្ញត្តិនៅប្រទេសនូវែលសេឡង់ដែលមុនការងារនេះផងដែរ លោកស្រីមានបទពិសោធន៍ 23ឆ្នាំ លើផ្នែកធនាគារ នៅប្រទេសនូវែលសេឡង់ ដែលបូករួមទាំងបទពិសោធន៍12ឆ្នាំ ទាក់ទងនឹងការងារគ្រប់គ្រងហានិភ័យរូបិយប័ណ្ណអន្តរជាតិ។

លោកស្រី វ៉ាយត៍ បានសិក្សាផ្នែកធុរកិច្ច និងការគ្រប់គ្រងអន្តរជាតិនៅសាកលវិទ្យាល័យ Massey ក្នុងឆ្នាំ2007។

លោកស្រី វ៉ាយត៍ បច្ចុប្បន្នធ្វើការជាអ្នកប្រឹក្សាផ្នែកទំនាក់ទំនងកិច្ចការខាងក្រៅនៅក្នុងអាជ្ញាធរទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសនូវែលសេឡង់ ប្រធានក្រុមប្រឹក្សានិយ័តករហិរញ្ញវត្ថុ ផ្នែកហានិភ័យ បម្រៃបម្រួលអាកាសធាតុហើយមុននេះបន្តិចលោកស្រីធ្លាប់ធ្វើជាបរិធនបាលទាយករយៈពេលមួយអាណ្តត្តិជូនក្រុមប្រឹក្សាភិបាលរបស់អង្គការទស្សនៈពិភពលោកនូវែលសេឡង់។



លោក គី ប៊ុនទ្រាន

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក គី ប៊ុនទ្រាន បានចូលរួមជាមួយ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ លោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ ព្រមទាំងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ពីមុន លោកជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ចាប់ពីឆ្នាំ 2018 ដល់ត្រឹមដើមឆ្នាំ 2020។ ក្រៅពីនេះទៀតលោកក៏ជាសមាជិកមួយរូបនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងជាសាស្ត្រាចារ្យបង្រៀនក្រៅម៉ោងនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

បន្ទាប់ពីការគួបបញ្ចូលគ្នាដោយជោគជ័យរវាងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក លោក គី ប៊ុនទ្រាន ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**។



លោក ឃូ ខ្វាងហ៊ី

សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកហិរញ្ញវត្ថុ

លោក ឃូ ខ្វាងហ៊ី បានចូលរួមជាមួយ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** (អតីត ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) ចាប់តាំងពីឆ្នាំ 2020 ក្រោយការគួបបញ្ចូលគ្នាក្នុងតួនាទីជានាយកគ្រប់គ្រងយុទ្ធសាស្ត្រ ហើយក្រោយមកជាប្រធានអគ្គនាយកដ្ឋានយុទ្ធសាស្ត្រគ្រប់គ្រង។

លោកធ្លាប់កាន់តួនាទីជានាយកសវនកម្មផ្ទៃក្នុង ខណៈលោកកំពុងធ្វើការឱ្យ អ៊ូរី ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី។ មុននឹងធ្វើការនៅប្រទេសកម្ពុជា លោកមានបទពិសោធន៍ជាច្រើនប្រមាណជិត16ឆ្នាំ ជាមួយនឹងធនាគារ អ៊ូរី របស់កូរ៉េ ហើយបទពិសោធន៍ដ៏លេចធ្លោរបស់លោកមួយផងដែរនោះ គឺនៅក្នុងវិស័យយុទ្ធសាស្ត្រប្រតិបត្តិការ ទាក់ទងនឹងធនាគារសាជីវកម្ម និងធុរកិច្ចខ្នាតតូច និងមធ្យម។

លោកទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Sungkyunkwan ក្នុងប្រទេសកូរ៉េ។

អំពី គណៈគ្រប់គ្រងជាន់ខ្ពស់



លោក គីម ហុង ជូ

ម្ចាស់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកប្រតិបត្តិ

លោក គីម ហុង ជូ បានរៀនចប់ជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យជាតិ សេអ៊ូលនៃប្រទេសកូរ៉េ។ លោកបានចូលរួមបម្រើការងារជាមួយធនាគារ អ៊ូរី និងមាននូវបទពិសោធន៍យ៉ាងច្រើនលើវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសលោកមានឯកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មសកល។ លោកបានធ្វើការនៅនាយកដ្ឋានយុទ្ធសាស្ត្រសកលជាង 8 ឆ្នាំ។ លោកបានចូលរួមចំណែកក្នុងប្រតិបត្តិការទិញលក់ភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុម្ហិះហ្វាយនៃន ក្នុងឆ្នាំ 2014 និងក្រោយមកបានរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថាន អ៊ូរី ហ្វាយនៃន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនៃន ឯ.ក នៅដើមឆ្នាំ 2020។ លោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុនៃ ដាប់ប៊ែលយូប៊ី ហ្វាយនៃន ឯ.ក ។ នៅចុងឆ្នាំ 2021 ក្រោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម លោកក៏បានក្លាយជាភាគទុនិករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនឈ្មោះថា ដាប់ប៊ែលយូប៊ី ហ្វាយនៃន ឯ.ក)។

នៅដើមឆ្នាំ2022 **លោក គីម ហុង ជូ** ត្រូវបានតែងតាំងជាអគ្គនាយកប្រតិបត្តិថ្មីនៃ**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក.**។



លោក ឃូ ខ្វាងហ៊ី

សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកហិរញ្ញវត្ថុ

លោក ឃូ ខ្វាងហ៊ី បានចូលរួមជាមួយ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** (អតីត ដាប់ប៊ែលយូប៊ី ហ្វាយនៃន ឯ.ក) ចាប់តាំងពីឆ្នាំ 2020 ក្រោយការគ្របបញ្ចូលគ្នាក្នុងតួនាទីជានាយកគ្រប់គ្រងយុទ្ធសាស្ត្រ ហើយក្រោយមកជាប្រធានអគ្គនាយកដ្ឋានយុទ្ធសាស្ត្រគ្រប់គ្រង។

លោកធ្លាប់កាន់តួនាទីជានាយកសវនកម្មផ្ទៃក្នុង ខណៈលោកកំពុងធ្វើការឱ្យ អ៊ូរី ហ្វាយនៃន ខេមបូឌា ម.ក ។ មុននឹងធ្វើការនៅប្រទេសកម្ពុជា លោកមានបទពិសោធន៍ជាច្រើនប្រមាណជិត16ឆ្នាំ ជាមួយនឹងធនាគារ អ៊ូរី របស់កូរ៉េ ហើយបទពិសោធន៍ដ៏លេចធ្លោរបស់លោកមួយផងដែរនោះ គឺនៅក្នុងវិស័យយុទ្ធសាស្ត្រប្រតិបត្តិការ ទាក់ទងនឹងធនាគារសាជីវកម្ម និងធុរកិច្ចខ្នាតតូចនិងមធ្យម។

លោកទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Sungkyunkwan ក្នុងប្រទេសកូរ៉េ។



លោក សុខ សុថា

អគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច 1

លោក សុខ សុថា គឺជានាយកផ្នែកប្រតិបត្តិការប្រចាំក្រុមអាជីវកម្មទី1 នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ លោកមានបទពិសោធន៍18ឆ្នាំទៅលើវិស័យធនាគារ និងមីក្រូហ្វាយនែន។ លោកបានចូលបម្រើការជាមន្ត្រីឥណទានចាប់តាំងពីឆ្នាំ2005 ហើយបានវិវត្តន៍ខ្លួនជាបន្តបន្ទាប់នៅក្នុងមុខតំណែងសំខាន់ៗជាច្រើនដូចជា ប្រធានសាខា ប្រធានតំបន់ ប្រធានប្រតិបត្តិការ និងអគ្គនាយកនាយកផ្នែកប្រតិបត្តិការ។

លោក សុខ សុថា បានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅឆ្នាំ2004 និងអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មជំនាញហិរញ្ញវត្ថុ និងធនាគារពីសកលវិទ្យាល័យបៀលប្រាយ។ លោកក៏បានចូលរួមវគ្គសិក្សាជាច្រើនដែលទាក់ទងទៅនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងវគ្គសិក្សាអន្តជាតិពី Boulder Institute of Microfinance, Turin ប្រទេសអ៊ីតាលីក្នុងឆ្នាំ 2016។



លោក ព្រាប ពិសិដ្ឋ

អគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច 2

លោក ព្រាប ពិសិដ្ឋ មានបទពិសោធន៍ច្រើនជាងមួយទសវត្សរ៍លើវិស័យអភិវឌ្ឍន៍ បម្រើអតិថិជន ការគ្រប់គ្រងកម្មវិធីឧបត្ថម្ភទំនាក់ទំនង សាធារណៈ និងរដ្ឋបាល ព្រមទាំង ការគ្រប់គ្រង និងភាពជា អ្នកដឹកនាំ មុនពេលដែលគាត់ចូលខ្លួនប្រឡូកក្នុងវិស័យហិរញ្ញវត្ថុ។ អាជីពរបស់លោកមានជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺចាប់ផ្តើមតាំងពីឆ្នាំ 2008។ កាលពីមុនមក លោកបានបម្រើការងារឱ្យអង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) និងលេខាធិការដ្ឋានមុខងារសាធារណៈរបស់ រាជរដ្ឋាភិបាលកម្ពុជា។

លោក ព្រាប ពិសិដ្ឋ ទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត គ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Anglia Ruskin, Global FTMS Campus នៅប្រទេសស៊ីង្ហបូរី ។ លោកក៏មាន បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងសហគ្រាស និងវិញ្ញាបត្ររងនៃវិជ្ជាជីវៈច្បាប់ មកពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជាផងដែរ។



លោក លី ហ្សូសក

អគ្គនាយកគាំទ្រប្រតិបត្តិការ

លោក លី បានទទួលបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីមហាវិទ្យាល័យនយោបាយ និងសេដ្ឋកិច្ច (ជំនាញសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ) នៅក្នុងសាកលវិទ្យាល័យ ខ្យ៉ងហ៊ី នៃប្រទេសកូរ៉េក្នុងឆ្នាំ 2004។

នៅក្នុងឆ្នាំ 2006, **លោក លី** បានចូលបម្រើការងារជាមួយធនាគារ អ៊ូរី (កូរ៉េ)។ គាត់បានបន្តអាជីពការងាររបស់គាត់មួយនេះរហូតមកដល់បច្ចុប្បន្ន ជាមួយនឹងបទពិសោធន៍ជាច្រើនតាមរយៈមុខតំណែងផ្សេងៗ។ គាត់បានចាប់ផ្តើមធ្វើការជាជំនួយការអ្នកគ្រប់គ្រង ទីផ្សារនិងលក់ សម្រាប់នាយកដ្ឋានសាជីវកម្មធនាគារ។ បន្ទាប់ពីការខិតខំប្រឹងប្រែងធ្វើការអស់រយៈពេលជាង16ឆ្នាំជាមួយ ធនាគារ អ៊ូរី (កូរ៉េ) នាពេលបច្ចុប្បន្ននេះគាត់បានកំពុងធ្វើការជា អគ្គនាយកគាំទ្រប្រតិបត្តិការ នៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក ចាប់តាំងពីខែសីហា ឆ្នាំ2022។



លោក ហ៊ុន សុភ័ក្ត្រ

អគ្គនាយកឥណទាន

លោក ហ៊ុន សុភ័ក្ត្រ គឺជាអគ្គនាយកឥណទាននៃ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ លោកមានបទពិសោធន៍រយៈពេល 18ឆ្នាំក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបានបទពិសោធន៍11ឆ្នាំ នៅធនាគារ អេស៊ីលីដា ក្នុងតួនាទីជានាយករងឥណទានសាជីវកម្ម លោកបានបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដោយជោគជ័យក្រោមឈ្មោះថា ហ្គ្រីន សេនត្រល់ ចាប់តាំងពី ខែមេសា ឆ្នាំ2008 ដល់ ខែវិច្ឆិកា ឆ្នាំ 2010។ ហើយគាត់គឺជា ស្ថាបនិកនៃគ្រឹះស្ថាន ម្លិះ ហ្វាយនែន ចាប់ពីខែវិច្ឆិកា ឆ្នាំ 2010 និងបានកម្លាយខ្លួនដោយជោគជ័យជាគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ម.ក ដែលជាផ្នែកមួយនៃធនាគារ អ៊ូរី ប្រទេសកូរ៉េ ជាគ្រឹះស្ថានហិរញ្ញវត្ថុសកល ហើយលោកមានតួនាទីជានាយកគ្រប់គ្រងទូទៅ។

ចាប់តាំងពីមានការគួបបញ្ចូលជាមួយនឹងធនាគារ អ៊ូរី ពីឆ្នាំ2014 លោក ហ៊ុន សុភ័ក្ត្រ ដើរតួនាទីយ៉ាងសំខាន់ជានាយកគ្រប់គ្រងទូទៅ និងដឹកនាំប្រតិបត្តិការអាជីវកម្មទាំងមូលកើនឡើងជាលំដាប់ ទាំងបរិមាណ និងគុណភាពនៃឥណទានដែលធ្វើឱ្យគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ម.ក ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលេខ1 ចាប់តាំងពី ឆ្នាំ 2018 ផ្អែកលើគុណភាពឥណទាន ទ្រព្យសកម្ម និងប្រាក់ចំណេញ។ លោកទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រង និង ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រង នៅកម្ពុជា ព្រមទាំងបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែល ទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។



លោក វ៉ា លួង សូរិន

អគ្គនាយកព័ត៌មានវិទ្យា

លោក សូរិន បានចូលរួមជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក្នុងឆ្នាំ 2015។ **លោក សូរិន** ជាអ្នកដឹកនាំផ្នែកយុទ្ធសាស្ត្រព័ត៌មានវិទ្យា ជាមួយនឹងបទពិសោធន៍ជាង15ឆ្នាំ លើការគាំទ្រដោយជោគជ័យ ជាច្រើនខាងបច្ចេកវិទ្យាការអនុវត្ត និងការរួមចំណែកលើកំណើនធុរកិច្ច តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឱ្យមានប្រយោជន៍ ការកាត់បន្ថយការចំណាយប្រតិបត្តិការ ការបង្កើនគុណតម្លៃនៃអាជីវកម្ម និងម្ចាស់ហ៊ុន។ លោកមានបទពិសោធន៍ក្នុងសហគ្រាសព័ត៌មានវិទ្យានៃក្រុមហ៊ុនអភិវឌ្ឍន៍ Software Telco, ISP, Tech startup និងវិស័យធនាគារ ព្រមទាំង ក្រុមហ៊ុនពហុជាតិដែលមានវប្បធម៌ចម្រុះ។ ជំនាញគោលរបស់លោក សូរិនរួមមាន៖ ការផ្លាស់ប្តូរផ្នែកឌីជីថល ការអភិវឌ្ឍ Agile Software និងEnterprise Architecture អភិបាលកិច្ចនៃសហគ្រាសព័ត៌មានវិទ្យា ការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា ប្រតិបត្តិការព័ត៌មានវិទ្យា ការអភិវឌ្ឍព័ត៌មានវិទ្យា បច្ចេកវិទ្យាសន្តិសុខ ការច្នៃឡើងវិញ និងបង្កើតដំណើរការ អាជីវកម្មតាមបែបស្វ័យប្រវត្តិ និងរៀបចំផែនការ ថវិកា និងការគ្រប់គ្រងថវិកា។

លោក សូរិន បានចូលរួម និងទទួលបានការបណ្តុះបណ្តាលជាច្រើននៅក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញផ្សេងៗទាំងក្នុង និងក្រៅស្រុក ដូចជាប្រព័ន្ធទូទាត់ប្រាក់ ប្រព័ន្ធគិតប្រាក់និងវាយតម្លៃ ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដា ISO 9001: 2000 ផែនការនៃភាពដឹកនាំ ការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម បច្ចេកវិទ្យាសន្តិសុខនិងសវនកម្មព័ត៌មានវិទ្យា ITIL និងការបណ្តុះបណ្តាលបច្ចេកទេស T24 ។

លោក សូរិន ក៏ត្រូវបានអញ្ជើញឱ្យធ្វើការបង្រៀន នៅសាកលវិទ្យាល័យមួយចំនួននៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើ ការតែងតាំងតួនាទីជាអគ្គនាយកព័ត៌មានវិទ្យានាពេលបច្ចុប្បន្ន លោកក៏ទទួលតួនាទីជាអគ្គនាយកសន្តិសុខព័ត៌មានវិទ្យា តួនាទី ជាប្រធានគណៈកម្មាធិការព័ត៌មានវិទ្យា និងគណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៅ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព័ត៌មានវិទ្យាពីសកលវិទ្យាល័យ KMUT ដែលនៅភាគខាងជើងនៃទីក្រុង បាងកក ក្នុងឆ្នាំ 2009។



លោកស្រី តុប សុក្រសម្ភារ

អគ្គនាយិកាគ្រប់គ្រងហានិភ័យ

លោកស្រី សម្ភារ បានចូលរួមការងារជាមួយ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** នៅក្នុងឆ្នាំ 2002 ក្នុងតួនាទីជានាយិកា ហិរញ្ញវត្ថុ និងកិច្ចការរដ្ឋបាល។ លោកស្រីបានទទួលតំណែង ជាអគ្គនាយិកាប្រតិបត្តិការក្នុងឆ្នាំ 2008 ក្រោយមកក៏ផ្លាស់ប្តូរ តួនាទីទៅជាអគ្គនាយិកាគ្រប់គ្រងហានិភ័យនៅក្នុងខែមេសា ឆ្នាំ2021។ មុនពេលលោកស្រីបានចូលរួមនឹងធនាគារ អ៊ូរី (ខេមបូឌា) ម.ក លោកស្រីបានបម្រើការងារជាសវនករជាន់ខ្ពស់នៅក្រុមហ៊ុន Ernst & Young និង Price Water House - Coopers ។ បច្ចុប្បន្នលោកស្រីគឺជាសមាជិក ក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

លោកស្រីមានបទពិសោធន៍ច្រើនជាង 20 ឆ្នាំលើផ្នែកហិរញ្ញវត្ថុ គណនេយ្យ ការគ្រប់គ្រង យុទ្ធសាស្ត្រ និងផែនការធុរកិច្ច សវនកម្ម រដ្ឋបាល និងប្រាស្រ័យទាក់ទង។

លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យជាតិ គ្រប់គ្រងនៅប្រទេសកម្ពុជា។ លោកស្រីបានទទួលវិញ្ញាបនបត្រ ថ្នាក់ជំនាញបច្ចេកទេសជាន់ខ្ពស់ផ្នែកគណនេយ្យ និងរដ្ឋបាល ពីមហាវិទ្យាល័យ Noisy Le Grand នៃប្រទេសបារាំង។



លោកស្រី ធី គន្ធា

អនុប្រធានចាត់ការទូទៅ មេធាវី និងជា
ប្រធានស្តីទីផ្នែកប្រតិបត្តិតាម

លោកស្រី ធី គន្ធា គឺជាអនុប្រធានចាត់ការទូទៅ មេធាវី និងជាប្រធានស្តីទីផ្នែកប្រតិបត្តិតាម របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ មុនពេលចូលរួមជាមួយធនាគារ អ្នកស្រីមានបទពិសោធន៍រយៈពេល 09ឆ្នាំ ជាមួយធនាគារ និងក្រុមហ៊ុនច្បាប់នានាក្នុងស្រុកដូចជា DFDL, Bun & Associates, Barang & Associates, Asia Cambodia Law Group និងធនាគារ រួមមាន J-Trust (អតីតធនាគារ ANZ Royal) ធនាគារ ឯកទេស AEON និងធនាគារ MB Bank (វៀតណាម)។

លោកស្រីទទួលបានបទពិសោធន៍ធ្វើការងារអន្តរជាតិជាអ្នកហាត់ការនៅតុលាការសម្រាប់អនីតិជន Juvenile Court, Lowell Massachusetts សហរដ្ឋអាមេរិកក្នុងឆ្នាំ2013។ **លោកស្រី ធី គន្ធា** បានទទួលបរិញ្ញាបត្រផ្នែកច្បាប់ (កម្មវិធីថ្នាក់ខ្មែរ និងថ្នាក់ភាសាអង់គ្លេស) និង អនុបណ្ឌិតផ្នែកបេតិកភ័ណ្ឌ ពីសាកលវិទ្យាល័យ Jean Moulin Lumiere Lyon 3 (ប្រទេសបារាំង) និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះលោកស្រីក៏ទទួលបានកម្មវិធីផ្លាស់ប្តូរវប្បធម៌នៅសាកលវិទ្យាល័យ School for International Training (SIT) រដ្ឋVermont សហរដ្ឋអាមេរិកផងដែរ។



កញ្ញា ហ៊ុន សុជាតិ

ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង

កញ្ញា ហ៊ុន សុជាតិ គឺជាប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុងរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ កញ្ញាមានបទពិសោធន៍រយៈពេល 9ឆ្នាំទាក់ទងទៅនឹងវិស័យធនាគារ និងមីក្រូហ្វាយនែន រយៈពេល 16ឆ្នាំក្នុងវិស័យសវនកម្ម។ មុនពេលចូលបម្រើការនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក កញ្ញាធ្លាប់បានបម្រើការនៅក្រុមហ៊ុន PwC Cambodia ដែលមានការចូលរួមយ៉ាងច្រើនជាមួយវិស័យផ្សេងៗ ដូចជាវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ ទូរគមនាគមន៍ ផលិតកម្ម សណ្ឋាគារ តោជនីយដ្ឋាន ប្រេង ឧស្ម័ន ការលក់រាយ និង ការចែកចាយ។

កញ្ញា ហ៊ុន សុជាតិ បច្ចុប្បន្នគឺជាសមាជិកមួយរូបនៃសមាគមគណនេយ្យករជំនាញ ACCA ដែលកញ្ញាបានចូលជាសមាជិកតាំងពីឆ្នាំ 2014 មកម្លេះ។

កញ្ញាបានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មផ្នែកគណនេយ្យ និងហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រអប់រំពីវិទ្យាស្ថានភាសាបរទេស (IFL) នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ។



លោក តឹក ចាន់ណារ៉ុង

ប្រធាននាយកដ្ឋានសេវាកម្មអតិថិជន

លោក តឹក ចាន់ណារ៉ុង គឺជាប្រធាននាយកដ្ឋានផ្នែកបម្រើសេវាកម្មអតិថិជននៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក ហើយក៏ត្រូវបានតែងតាំងជា មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន។ លោកមានបទពិសោធន៍សរុប 13ឆ្នាំក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ហើយមានបទពិសោធន៍ 10ឆ្នាំទាក់ទងទៅនឹងការគ្រប់គ្រងតោជនីយដ្ឋានហ្វាសហ្វូត ក្រុមហ៊ុនឱសថដ្ឋាន ក៏ដូចជាវិស័យសណ្ឋាគារផងដែរ។ បន្ទាប់ពីបម្រើការងាររយៈពេល 8ឆ្នាំក្នុងនាមជា អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកសេវាកម្មអតិថិជន នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ លោកបានផ្លាស់ប្តូរទៅបម្រើការងារនៅធនាគារមួយទៀតនៅក្នុងឆ្នាំ 2018 ក្នុងនាមជាប្រធានផ្នែកគុណភាពសេវាកម្ម និងការគ្រប់គ្រងអចលនទ្រព្យ។

នៅក្នុងខែកក្កដា ឆ្នាំ2020 **លោក តឹក ចាន់ណារ៉ុង** បានចូលបម្រើការងារនៅ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក្នុងនាមជាប្រធាននាយកដ្ឋានសេវាកម្មអតិថិជនដែលមានតួនាទីគ្រប់គ្រងទៅលើសេវាអតិថិជន និងមជ្ឈមណ្ឌលទំនាក់ទំនងតាមទូរស័ព្ទ **លោក តឹក ចាន់ណារ៉ុង** បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគោលនយោបាយប្រតិបត្តិការស្តង់ដារសេវាកម្មអតិថិជន និងបង្កើតប្រព័ន្ធមជ្ឈមណ្ឌលគាំទ្រសេវាអតិថិជនតាមទូរស័ព្ទ ដើម្បីគាំទ្រការរីកចម្រើនរបស់ស្ថាប័ន ក៏ដូចជាគាំទ្រដល់អតិថិជនរបស់ធនាគារ អ៊ូរី ផងដែរ។

លោក តឹក ចាន់ណារ៉ុង បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកទីផ្សារអាជីវកម្ម ពីសកលវិទ្យាល័យជាតិគ្រប់គ្រង លោកក៏បានចូលរួមក្នុងវគ្គសិក្សាជាច្រើនដែលទាក់ទងទៅនឹងបទពិសោធន៍អតិថិជន សេវាកម្មអតិថិជន និង មជ្ឈមណ្ឌលទំនាក់ទំនងតាមទូរស័ព្ទផងដែរ។

ការគ្រប់គ្រង**ហានិភ័យ**

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក កំពុងបន្ត និងបង្កើនប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ មុខងារត្រួតពិនិត្យ សន្តិសុខ និងសុវត្ថិភាពទៅលើគ្រប់ផ្នែកហានិភ័យរបស់ធនាគារ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ខ្លួនដោយផ្អែកលើគោលការណ៍ “ខ្សែការពារបី” ដើម្បីគាំទ្រដល់ រចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យដ៏រឹងមាំ។


រចនាសម្ព័ន្ធអភិបាលកិច្ចរួមមាន គណនេយ្យភាព ទំនួលខុសត្រូវ ឯករាជ្យភាព ការរាយការណ៍ ការទំនាក់ទំនង និង តម្លាភាព ទាំងខាងក្នុង ព្រមទាំងជាមួយភាគីពាក់ព័ន្ធខាងក្រៅរបស់យើង។

វិធីសាស្ត្រគ្រប់គ្រងហានិភ័យរបស់ធនាគាររួមមាន ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកាត់បន្ថយហានិភ័យសំខាន់ៗ ព្រមទាំងការត្រួតពិនិត្យដែលត្រូវបានអនុវត្ត ទៅគ្រប់ផ្នែកទាំងអស់នៃអាជីវកម្មរបស់ធនាគារ។

ទំនួលខុសត្រូវចំពោះការគ្រប់គ្រងហានិភ័យ មាននៅគ្រប់កម្រិតទាំងអស់របស់ធនាគារ។ បុគ្គលិកគ្រប់រូបមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យ ទៅតាមផ្នែកនៃការប្រតិបត្តិការងារនីមួយៗរបស់ពួកគេ។ ពួកគេត្រូវតែយល់ និង គ្រប់គ្រងទៅលើហានិភ័យសំខាន់ៗ ដែលអាចកើតមាននៅក្នុងអាជីវកម្ម ហើយវិធីសាស្ត្រនេះត្រូវបានអនុវត្តដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ដំណើរការ ដែលត្រូវពឹងផ្អែកលើទំនួលខុសត្រូវរបស់បុគ្គលនីមួយៗ និង ការត្រួតពិនិត្យដោយឯករាជ្យ។

វិធានការគ្រប់គ្រងហានិភ័យ

គណៈគ្រប់គ្រងរបស់ធនាគារ ជឿជាក់ថាកត្តាហានិភ័យ អាចត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងមានការត្រៀមទុកជាមុន ដើម្បីបន្ថយកម្រិតសក្តានុពលនៃការបាត់បង់ទាំងផ្នែកហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ។



វិធានការគ្រប់គ្រងហានិភ័យឥណទាន

ធនាគារបានគ្រប់គ្រងយ៉ាងសកម្មទៅលើ ហានិភ័យនៃការប្រមូលផ្តុំផលប័ត្រឥណទាន ដើម្បីធានាបាននូវការធ្វើពិពិធកម្មផលប័ត្រឥណទានដ៏ល្អ ហើយថែមទាំងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ទៅលើសំពៀតឥណទានដែលបានរៀបចំសារឡើងវិញ សម្រាប់អតិថិជនដែលរងផលប៉ះពាល់ដោយសារ ជំងឺកូវីត19 និងគ្រោះទឹកជំនន់ ព្រមទាំងធ្វើស្ត្រេសតេស្តទៅលើសំពៀតឥណទាន ដែលបានរៀបចំសារឡើងវិញផងដែរ។

ធនាគារមានគោលនយោបាយគ្រប់គ្រងឥណទាន សៀវភៅណែនាំ និង ការណែនាំដើម្បីកាត់បន្ថយ ហានិភ័យឥណទាន ជាពិសេស ធនាគារមានក្រុមវិភាគ និងអនុម័តឥណទានដែលបានធ្វើការដោយឯករាជ្យ ក្នុងការវិភាគឥណទាន ព្រមទាំងអនុម័តប្រាក់កម្ចី។ លើសពីនេះទៅទៀត ធនាគារក៏បានដាក់ក្រុមត្រួតពិនិត្យក្រោយបញ្ចេញប្រាក់កម្ចី ដើម្បីពិនិត្យមើលភាពសមរម្យនៃប្រាក់កម្ចីក្រោយការអនុម័ត គុណភាពឯកសារ ការកំណត់នូវបញ្ហាអោយទាន់ពេលវេលា និងផ្តល់អនុសាសន៍ដល់បុគ្គលិកក្នុងការធ្វើការកែលម្អអោយកាន់តែប្រសើរឡើង។

វិធានការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ធនាគាររក្សាបាននូវ អនុបាតសំខាន់ៗ និងស្ថិរភាពនៃទ្រនាប់សន្ទនីយភាពនៃទ្រព្យសកម្មងាយស្រួល ។

ធនាគារបានធ្វើស្ត្រេសតេស្តទៅលើសន្ទនីយភាព ដើម្បីវាយតម្លៃសន្ទនីយភាពក្នុងស្ថានភាពវិបត្តិតាមរយៈសម្មតិកម្ម ទៅតាមសេណារីយ៉ូផ្សេងៗ ដើម្បីកែសម្រួល និងរៀបចំផែនការមូលនិធិការគ្រប់គ្រងសន្ទនីយភាព ព្រមទាំងផែនការសម្មភាពដែលត្រូវអនុវត្តផងដែរ។

វិធានការគ្រប់គ្រងហានិភ័យទីផ្សារ

ដើម្បីកាត់បន្ថយហានិភ័យនៃការបាត់បង់ប្រាក់ចំណេញ ឬ ដើមទុនពីការប្រែប្រួលរូបិយប័ណ្ណ ធនាគារបានគ្រប់គ្រងទៅលើ អនុបាតស្ថានភាពចំហរសុទ្ធ “Net Open Position” និង ធានាថាធនាគារបានអនុឡោមទៅតាមបទប្បញ្ញត្តិរបស់និយ័តករ។

ធនាគារត្រួតពិនិត្យយ៉ាងតឹងរ៉ឹងទៅលើអត្រាការប្រាក់នៅលើទីផ្សារ និងចាត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមាន។

វិធានការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក នឹងស្វែងរកវិធានការដើម្បីកាត់បន្ថយការខាតបង់ ពីហានិភ័យប្រតិបត្តិការ តាមរយៈការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងដែលរួមមានដូចជា៖

- ការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងម៉ត់ចត់ និង ការត្រួតពិនិត្យដំណើរការ ដើម្បីកាត់បន្ថយកំហុសរបស់មនុស្ស ឬ ប្រព័ន្ធនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ។
- ធនាគារបានធ្វើតេស្តសាកល្បងទៅលើផែនការនិរន្តរភាពអាជីវកម្ម ដើម្បីធានាប្រសិទ្ធភាព និងភាពរឹងមាំនៃបណ្តាញព័ត៌មានវិទ្យា ព្រមទាំងកាត់បន្ថយភាពអាក់អួល ចំពោះការប្រើប្រាស់សេវាកម្មរបស់អតិថិជន អោយនៅត្រឹមកម្រិតតិចតួច។

លើសពីនេះ ធនាគារក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការទទួលស្គាល់ ការវាយតម្លៃ និងកាត់បន្ថយហានិភ័យប្រតិបត្តិការ ដើម្បីកាត់បន្ថយសក្តានុពលនៃការបាត់បង់ ព្រមទាំងធានាបាននូវភាពរលូននៃប្រតិបត្តិការអាជីវកម្ម ហានិភ័យតាមអ៊ីនធឺណិត និងហានិភ័យផ្នែកបច្ចេកវិទ្យាផ្សេងទៀតក៏កំពុងកើនឡើងផងដែរ។ ដូច្នេះធនាគារ បានបង្កើតនូវគោលនយោបាយ សៀវភៅណែនាំ និងគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ ហើយសៀវភៅណែនាំ និងគោលការណ៍ណែនាំទាំងនោះត្រូវតែស្របតាមគោលការណ៍គ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យា របស់ធនាគារជាតិនៃកម្ពុជា។

ការប្រតិបត្តិតាម

មុខងារប្រតិបត្តិតាម គឺជាខ្សែរការពារទី2 ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានប្រតិបត្តិតាម។ ប្រធាននាយកដ្ឋានប្រតិបត្តិតាម ត្រូវរាយការណ៍ដោយផ្ទាល់ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ដើម្បីធានាអំពីឯករាជ្យភាពនៃមុខងារប្រតិបត្តិតាម។

ដើម្បីឱ្យការគ្រប់គ្រងផ្ទៃក្នុងរឹងមាំ និងជាផ្នែកមួយនៃមុខងារប្រតិបត្តិតាម ប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុង ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានប្រតិបត្តិតាម ដែលរួមមានគោលការណ៍ សៀវភៅណែនាំ ការណែនាំ របាយការណ៍ និងការគ្រប់គ្រង ត្រួតពិនិត្យ និងការធ្វើតេស្ត ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យប្រតិបត្តិតាមរបស់ធនាគារទាំងមូល។

ដូចដែលបានបញ្ជាក់នៅខាងលើ និងដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវផ្ទៃក្នុងច្បាប់ មុខងារប្រតិបត្តិតាមត្រូវបានចាត់ទុកជាឆ្អឹងខ្នងដ៏រឹងមាំរបស់ធនាគារ និងទទួលបានការគាំទ្រយ៉ាងខ្លាំងពីគណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ដោយអនុលោមតាមការណែនាំពីធនាគារជាតិនៃកម្ពុជា អង្គភាពសើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងនិយ័តករពាក់ព័ន្ធផ្សេងទៀត។ លើសពីនេះទៅទៀត ការណែនាំ និងលក្ខខណ្ឌតម្រូវសម្រាប់មុខងារប្រតិបត្តិតាម ដែលចេញដោយ ក្រុមហ៊ុនមេ ក៏ត្រូវបានយកមកអនុវត្តន៍ដើម្បីឱ្យការគ្រប់គ្រងផ្ទៃក្នុងនៃមុខងារប្រតិបត្តិតាមកាន់តែប្រសើរឡើង និងមានប្រសិទ្ធិភាពខ្ពស់ ដូចការរឹតបិតទុករបស់និយ័តករពាក់ព័ន្ធ។

ដើម្បីឆ្លុះបញ្ចាំងពីគោលការណ៍ធុរកិច្ចរបស់ធនាគារក្នុងការនាំមុខទីផ្សារ និងផ្តល់នូវភាពងាយស្រួល ឆាប់រហ័ស និងភាពឆ្នៃប្រឌិតខ្ពស់បំផុតទាក់ទងនឹងបទពិសោធន៍ធនាគារសម្រាប់ប្រជាជនកម្ពុជា ធនាគារអនុវត្តន៍យ៉ាងតឹងរឹងនូវរាល់ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលចេញដោយអាជ្ញាធរពាក់ព័ន្ធ មានដូចជាធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបន្ទាប់ពីបានផ្លាស់ប្តូរ និងទទួលបានការអនុញ្ញាតពីនិយ័តករពាក់ព័ន្ធឱ្យទៅជាធនាគារពាណិជ្ជនៅក្នុងខែធ្នូ 2021។ ក្នុងចំណោមមុខងារផ្សេងទៀត មុខងារប្រតិបត្តិតាម ត្រូវបានផ្តល់អាទិភាព ដើម្បីឱ្យការគ្រប់គ្រងផ្ទៃក្នុងកាន់តែល្អនិងប្រសើរឡើង រួមមានការបន្ថែតខំប្រឹងប្រែងក្នុងការពិនិត្យ និងបង្កើតបទប្បញ្ញត្តិផ្ទៃក្នុងពាក់ព័ន្ធរបស់ធនាគារ ការបោះពុម្ពផ្សាយទាំងអស់ និងផ្តល់ជាយោបល់ផ្សេងៗ និងការវាយតម្លៃលើគម្រោងផ្សេងៗ ពាក់ព័ន្ធនឹងផលិតផល សេវាកម្ម ឬកម្មភាពថ្មីៗរបស់ធនាគារ។

តួនាទីសំខាន់ៗនៃមុខងារប្រតិបត្តិតាមគឺ៖

1. ធានាអំពីអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន
2. ផ្តល់ប្រឹក្សាយោបល់
3. ផ្តល់ការបណ្តុះបណ្តាល និងចែករំលែកការយល់ដឹងផ្នែកប្រតិបត្តិតាម
4. វាយតម្លៃផលិតផល សេវាកម្ម ឬសកម្មភាពថ្មីៗ
5. កំណត់ វាស់វែង និងរាយតម្លៃហានិភ័យនៃការប្រតិបត្តិតាម
6. ត្រួតពិនិត្យគោលនយោបាយ សៀវភៅណែនាំ ការណែនាំ និង/ឬ និតិវិធី
7. ការត្រួតពិនិត្យ ការធ្វើតេស្ត និងរាយការណ៍អំពីការប្រតិបត្តិតាម
8. វីុសលប្លូវីង
9. ការបង្កើតកម្មវិធីប្រតិបត្តិតាម
10. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

សវនកម្មផ្ទៃក្នុង

មុខងារសវនកម្មផ្ទៃក្នុងមានឯករាជ្យភាពពេញលេញលើប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ និងមុខងារត្រួតពិនិត្យអចិន្ត្រៃយ៍ ដែលដឹកនាំដោយប្រធានសវនកម្មផ្ទៃក្នុង “HIA”។ ដើម្បីធានានូវឯករាជ្យភាពរបស់សវនកម្មផ្ទៃក្នុង HIA ត្រូវរាយការណ៍ដោយផ្ទាល់ទៅប្រធានគណៈកម្មាធិការសវនកម្ម, ក្រោយមកហៅថា "AC" ហើយ AC នឹង៖

- អនុម័តផែនការសវនកម្មផ្ទៃក្នុងផ្អែកលើហានិភ័យ និងអនុម័តគម្រោងថវិកា និងធនធានរបស់សវនកម្មផ្ទៃក្នុង
- ទទួលរបាយការណ៍ពី HIA អំពីលទ្ធផលនៃសវនកម្មផ្ទៃក្នុង ដែលទាក់ទងនឹងស្ថានភាពនៃការបំពេញផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ របាយការណ៍ និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងការធ្វើសវនកម្ម
- វាយតម្លៃសមិទ្ធិផលការងារប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់ការសម្រេចចិត្តលើការអនុម័តទាក់ទងនឹងការតែងតាំងនិងការដកហូតតំណែង HIA

បេសកកម្មរបស់សវនកម្មផ្ទៃក្នុងគឺដើម្បីលើកកម្ពស់ និងការពារតម្លៃរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដោយផ្តល់នូវ ការធានាការប្រឹក្សាដោយឯករាជ្យ មិនលំអៀង ដែលផ្អែកលើហានិភ័យ។ សវនកម្មផ្ទៃក្នុងជួយឱ្យ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក សម្រេចបាននូវគោលបំណងរបស់ខ្លួន ដោយនាំមកនូវវិធីសាស្ត្រជាប្រព័ន្ធ និងប្រកបដោយវិន័យ ដើម្បីវាយតម្លៃ និងកែលម្អប្រសិទ្ធភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងដំណើរការត្រួតពិនិត្យ។

សវនកម្មផ្ទៃក្នុងបង្កើតវិធីសាស្ត្រសវនកម្មដោយផ្អែកលើហានិភ័យ ដើម្បីកំណត់អាទិភាពសម្រាប់សកម្មភាពសវនកម្មផ្ទៃក្នុងស្របតាមគោលដៅរបស់ធនាគារ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើសវនកម្មដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំផ្អែកលើហានិភ័យ ដែលត្រូវបានអនុម័តដូចខាងក្រោម៖

- ធ្វើសវនកម្មផ្ទៃក្នុងរបស់សាខា និងការិយាល័យកណ្តាល
- ធ្វើសវនកម្មផ្ទៃក្នុង ព័ត៌មានវិទ្យា “IT” ស្របតាមផែនការ
- ធ្វើសវនកម្ម/ការស៊ើបអង្កេតពិសេស

នៅឆ្នាំ 2022 នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តការធ្វើសវនកម្មចំនួន 230 រួមទាំងសវនកម្មសាខាចំនួន 94 នាយកដ្ឋានការិយាល័យកណ្តាលចំនួន 14 ការធ្វើសវនកម្មចាំបាច់ចំនួន 2 និងសវនកម្មស៊ើបអង្កេតពិសេសចំនួន 120 ។

លទ្ធផលនៃសកម្មភាពសវនកម្ម ត្រូវបានរាយការណ៍ជារៀងរាល់ប្រចាំត្រីមាសទៅកាន់ AC និង ជូនដំណឹងលទ្ធផលសវនកម្មក្នុងទម្រង់ជារបាយការណ៍សរសេរ ជូនអ្នកគ្រប់គ្រង។

ការរកឃើញ និងអនុសាសន៍សវនកម្មទាំងអស់ដែលកើតចេញពីសវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ និងការតាមដានស្ថានភាពនៃការអនុវត្តអនុសាសន៍ជាមួយអ្នកគ្រប់គ្រងជារៀងរាល់ត្រីមាស។ អ្នកគ្រប់គ្រងតម្រូវឱ្យអនុវត្តអនុសាសន៍សវនកម្ម និងរាយការណ៍ពីស្ថានភាពនៃការអនុវត្តអនុសាសន៍ទៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងជារៀងរាល់ត្រីមាស។



III

លទ្ធផល សម្រេចបាន

ធនាគារ អ៊ូរី បានក្លាយខ្លួនជា ធនាគារពាណិជ្ជជាផ្លូវការ 38
ការបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត 40
ដៃគូអាជីវកម្មឌីជីថលថ្មី 40
ការបើកដំណើរការសាខាថ្មី 41
ការដាក់ដំណើរការផលិតផលថ្មីៗ 41

ធនាគារ អ៊ូរី បានក្លាយខ្លួនជា ធនាគារពាណិជ្ជជាផ្លូវការ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក. បានទទួលអាជ្ញាបណ្ណក្លាយជាធនាគារពាណិជ្ជដោយជោគជ័យពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី 21 ខែវិច្ឆិកា ឆ្នាំ 2021។ ចាប់ផ្តើមពីកម្មវិធីផ្តល់មូលនិធិក្នុងទសវត្សរ៍ឆ្នាំ 1990 ក្លាយជាក្រុមហ៊ុនដែលបានចុះបញ្ជីក្នុងឆ្នាំ 2003 និងបានផ្តល់អាជ្ញាបណ្ណជា MDI ក្នុងឆ្នាំ 2011 ការផ្លាស់ប្តូរកម្មសិទ្ធិទៅជាធនាគារ អ៊ូរី នៅក្នុងឆ្នាំ 2018 និងក្លាយជាធនាគារពាណិជ្ជផ្លូវការនៅឆ្នាំ 2021។ នេះជាព្រឹត្តិការណ៍នៃការផ្លាស់ប្តូរដ៏សំខាន់មួយក្នុងរយៈពេល ជាច្រើនឆ្នាំនៃប្រវត្តិសាស្ត្ររបស់ស្ថាប័នក្នុងការបម្រើសេវាកម្មហិរញ្ញវត្ថុជូនដល់ប្រជាជនកម្ពុជាទូទាំងប្រទេស។

ក្នុងកំឡុងឆ្នាំ 2022 ធនាគារបានរៀបចំស្តង់របស់ធនាគារនៅទីកន្លែងផ្សេងៗគ្នាដូចជា ផ្សារទំនើបអ៊ីអនម៉លភ្នំពេញ ផ្សារទំនើបអ៊ីអនម៉លសែនសុខនិង ផ្សារទំនើបខេម៉ល ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីម៉ាកយីហោទៅកាន់សាធារណជន និងចូលរួមជាមួយអតិថិជន។ ក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃបើកដំណើរការ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានទទួលការយកចិត្តទុកដាក់ និងការគាំទ្រយ៉ាងល្អពីសាធារណជន ហើយអាចបង្កើនចំនួនអតិថិជនដាក់ប្រាក់សន្សំដល់ 416,491 នាក់ កើនឡើង 25.9% បើធៀបនឹងឆ្នាំ 2021។

ការបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត



#	មុខងារថ្មី
1	បន្ថែមការបកប្រែភាសាខ្មែរ
2	អនុញ្ញាតអោយគណនីរួមអាចចុះឈ្មោះប្រើប្រាស់សេវាកម្មធនាគារចល័តបាន
3	ការផ្លាស់ប្តូររូបរាងថ្មី និងការកែលម្អបទពិសោធន៍អតិថិជន
4	បន្ថែមសេវាទូទាត់វិក្កយបត្រឯកជន
5	បន្ថែមសេវាទូទាត់នៅលើ Nham24
6	បន្ថែមសេវាទូទាត់ថ្លៃវិក្កយបត្រអនឡាញនៃអគ្គិសនីកម្ពុជា
7	ការស្កេនរហ័សដោយទាញយករូបភាព QR ដែលបានរក្សាទុកក្នុងសាលរូបភាព
8	ការស្កេនរហ័សទៅលើ KHQR ដើម្បីផ្ទេរប្រាក់ រឺទូទាត់
9	ការកំណត់ការផ្ញើសារព័ត៌មានប្រតិបត្តិការទៅកាន់ Telegram

បើកដំណើរការសាខាថ្មី

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គ្រោងនឹងបើកសាខាថ្មីចំនួន 2 ជាមួយរចនាបទដ៏ទាក់ទាញនៅក្នុងខណ្ឌដូនពេញ និងខណ្ឌសែនសុខ ដែលនឹងមានទីតាំងនៅកន្លែងដែលផ្តល់ភាពងាយស្រួលសម្រាប់អតិថិជនរបស់យើងក្នុងការស្វែងរក។ សាខាទាំងពីរនឹងត្រូវបានបំពាក់ដោយការរចនាទាំងផ្នែកខាងក្នុង និងខាងក្រៅយ៉ាងស្រស់ស្អាតនឹងមានភាពទាក់ទាញ រួមទាំងបរិក្ខារទំនើប រចនាឡើងជាពិសេសដើម្បីផ្តល់នូវបរិយាកាសរីករាយ និងសេវាកម្មហិរញ្ញវត្ថុដែលមានភាពងាយស្រួលសម្រាប់អតិថិជនរបស់យើង។ ដោយមានការគាំទ្រយ៉ាងខ្លាំង និងតម្រូវការកាន់តែកើនឡើងរបស់អតិថិជន ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន នៅទូទាំង រាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ទូទាំងប្រទេសកម្ពុជា។







ដៃគូអាជីវកម្មឌីជីថលថ្មី

ដោយស្របតាមទីផ្សារប្រកួតប្រជែង ក៏ដូចជាបំពេញតម្រូវការអតិថិជនដៃគូសហការតាមរយៈឌីជីថលត្រូវបានសហការជាមួយដៃគូដូចខាងក្រោម៖

ល.រ	ដៃគូសហការ	អំពីសេវាកម្មជាមួយដៃគូសហការ
1	**អគ្គិសនីកម្ពុជា**	អតិថិជនអាចទូទាត់វិក្កយបត្រភ្លើង ទៅកាន់ប្រព័ន្ធរបស់ភ្លើងរដ្ឋភ្លាមៗរយៈធនាគារអ៊ូរីខេមបូឌា។
2	**ញ៉ាំ24**	អតិថិជនអាចទិញផលិតផល និងទូទាត់វិក្កយបត្រតាមរយៈធនាគារ អ៊ូរីខេមបូឌា ម.ក នៅក្នុងប្រព័ន្ធរបស់ក្រុមហ៊ុនញ៉ាំ24។
3	**សេវាបង់វិក្កយបត្រឯកជន**	អតិថិជនអាចទូទាត់វិក្កយបត្រទឹក, ភ្លើង, សំរាម និងវិក្កយបត្រទូទៅ របស់សេវាឯកជនបានទូទាំងប្រទេសរហូតដល់ 200សេវាករ។

ការដាក់ដំណើរការផលិតផលថ្មីៗ

គណនីសន្សំធ្លឹស គឺជាប្រភេទផលិតផលគណនីសន្សំ ថ្មីមួយទៀត របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជូនអតិថិជន នូវភាពបត់បែនក្នុងការដកប្រាក់ និងដាក់ប្រាក់ ទៅតាមលំហូរសាច់ប្រាក់យ៉ាងទាក់ទាញ ទៅតាមទំហំទឹកប្រាក់របស់អតិថិជនផងដែរ។

គណនីសន្សំតាមផែនការ ធ្លឹស គឺជាប្រភេទផលិតផលដាក់ប្រាក់ បញ្ជើប្រចាំខែថ្មីមួយទៀត ដែលមានភាពបត់បែនលើការដាក់ប្រាក់។ មានន័យថាអតិថិជនអាចដាក់ប្រាក់បន្ថែម លើចំនួនទឹកប្រាក់ដែល បានកំណត់នៅក្នុងតារាង កាលវិភាគដាក់ប្រាក់សន្សំក្នុងអំឡុង ពេលកិច្ចសន្យា។

សេវា ថេប ប៊ែងឃីង ត្រូវបានបង្កើតឡើងជាមធ្យោបាយមួយផ្សេងទៀត សម្រាប់ការបើកគណនី ដើម្បីផ្តល់សេវាបម្រើអតិថិជនកាន់តែប្រសើរ និងដើម្បីកាត់បន្ថយពេលវេលា និងការចំណាយសម្រាប់ការបើកគណនី។ ដំណើរការនេះអនុញ្ញាតឱ្យបុគ្គលិកទទួលបន្ទុករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ធ្វើការចុះទៅបើកគណនីដល់ទីតាំងជូនអតិថិជន។

តណទានសហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានទទួលស្គាល់ថាជាតណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម។ តណទាននេះ ផ្តល់ជូនសម្រាប់អតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល / ក្រុមហ៊ុន / សហគ្រាស។

តណទានសាជីវកម្ម គឺជាតណទានដែលផ្តល់ឱ្យនីតិបុគ្គល/ក្រុមហ៊ុន/សហគ្រាសខ្នាតធំ ដែលត្រូវការហិរញ្ញវត្ថុដើម្បីទ្រទ្រង់ដល់ការចំណាយទូទាត់រយៈពេលខ្លី ឬដើមទុនទ្រទ្រង់ប្រតិបត្តិការអាជីវកម្ម និងការវិនិយោគ។

ផលិតផលហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានផ្តល់ជូនលោកអ្នកនូវសេវាកម្ម លិខិតឥណទាន, សេវាប្រមូលឯកសារ, លិខិតធានា, Standby Letter of Credit ក៏ដូចជា Advising, Negotiation ព្រមទាំងសេវាកម្មពាណិជ្ជកម្មអន្តរជាតិជាច្រើនទៀត។ ផលិតផលចម្បង របស់ហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិមានដូចជា លិខិតឥណទាន សេវាប្រមូលឯកសារ និងលិខិតធានា។

IV

ចំណុចសំខាន់ៗ អំពីអាជីវកម្ម

ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ 44
របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស 48
សក្តីកម្មរបស់បុគ្គលិក 49
ពត៌មានសំខាន់ៗ 52
អំពីភាពជោគជ័យរបស់អតិថិជន 58
អំពីផលិតផល និងសេវាកម្ម 60
របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន នីងសង្គម 78
បណ្តាញសាខា និងតំបន់ប្រតិបត្តិការ 80

ទិន្នន័យ ហិរញ្ញវត្ថុសំខាន់ៗ

ទិន្នន័យសំខាន់ៗ

	ឆ្នាំ 2022	ឆ្នាំ 2021
ចំនួនអតិថិជនប្រាក់កម្ចីសកម្ម	**196,821**	177,256
% អតិថិជនប្រាក់កម្ចីជាស្ត្រី	**71%**	73%
% អតិថិជនប្រាក់កម្ចីតាមជនបទ	**72%**	73%
% អតិថិជនប្រាក់កម្ចីផ្នែកកសិកម្ម	**33.40%**	40.63%
ចំនួនតំបន់ប្រតិបត្តិការ	**18**	18
ចំនួនស្រុកប្រតិបត្តិការ	**204**	203
ចំនួនបុគ្គលិកសរុប	**4,205**	3,780
ផលប័ត្រឥណទាន	**$1,183,324,067**	**$927,833,487**
ផលប័ត្រឥណទាន ជាមធ្យមសម្រាប់អ្នកខ្ចីម្នាក់	**$6,012**	$5,234
ផលប័ត្រឥណទាន ជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់	**$583,491**	$448,879
ផលប័ត្រឥណទាន មានហានិភ័យ > 30 ថ្ងៃ	**1.35%**	0.78%
ប្រាក់បញ្ញើរបស់អតិថិជន	**$353,464,472**	$217,455,161
ចំនួនអ្នកដាក់ប្រាក់បញ្ញើ	**416,491**	330,607
ទ្រព្យសកម្មសរុប	**$1,442,182,719**	**$1,162,460,491**
មូលនិធិម្ចាស់ហ៊ុនសរុប	**$323,330,161**	**$277,027,042**
ប្រាក់ចំណេញធៀបដើមទុន	**15.43%**	17.59%
ប្រាក់ចំណេញធៀបទ្រព្យសកម្ម	**3.56%**	4.63%


វិធីសាស្ត្រប្រាក់កម្ចី

តាមរយៈចំនួនអតិថិជន



វិធីសាស្ត្រប្រាក់កម្ចី

តាមទំហំផលប័ត្រឥណទាន



និន្នាការកំណើន

ខែធ្នូ ឆ្នាំ 2022

$1,183.32
ផលប័ត្រឥណទាន
(គិតជាលានដុល្លារអាមេរិក)


196,821
ចំនួនអតិថិជនកម្ចី

416,491
ចំនួនអតិថិជន
បញ្ញើសន្សំ

$353.46
សមតុល្យប្រាក់បញ្ញើ-សន្សំ
(គិតជាលានដុល្លារអាមេរិក)

$1,442.18
សរុបទ្រព្យសកម្ម
(គិតជាលានដុល្លារអាមេរិក)

ពីខែធ្នូឆ្នាំ 2018 ដល់ខែធ្នូឆ្នាំ 2022 (គិតជាលានដុល្លារអាមេរិក)



របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារពាណិជ្ជដែលមានតម្លាភាពមួយយើងខ្ញុំសូមធ្វើការផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ដូចមានបង្ហាញជូននៅតារាងខាងក្រោម៖


គិតជាដុល្លារអាមេរិក	2018	2019	2020	2021	2022
ពន្ធប៉ាតង់	$18,500	$18,500	$18,500	$18,500	$18,500
ពន្ធតែមសារពើពន្ធលើផ្ទាំងផ្សាយពាណិជ្ជកម្ម	$81,755	$64,790	$69,185	$115,098	$211,688
កម្រៃអាជ្ញាបណ្ណបង់ជូនធនាគារជាតិ	$305,125	$297,500	$308,750	$382,500	$822,500
ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ	$1,788	$2,278	$2,301	$3,593	$3,388
អាករលើតម្លៃបន្ថែម	$2,325	$2,266	$17,767	$0	$5,222
ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ	$391,678	$500,668	$843,090	$1,252,193	$1,708,308
ពន្ធលើប្រាក់ចំណូល	$ 728,045	$3,457,620	$6,876,812	$11,756,722	$11,800,719
ពន្ធលើប្រាក់បៀវត្ស	$ 937,310	$696,947	$1,029,252	$1,324,151	$1,639,996
ពន្ធកាត់ទុកលើនិវាសជនគណនីសន្សំមានកាលកំណត់	$ 194,655	$204,791	$226,698	$428,021	$919,642
ពន្ធកាត់ទុកលើនិវាសជនគណនីសន្សំគ្មានកាលកំណត់	$10,384	$13,954	$19,723	$28,874	$66,765
ពន្ធកាត់ទុកលើនិវាសជន ថ្លៃឈ្នួល	$204,772	$252,800	$330,297	$455,512	$589,700
ពន្ធកាត់ទុកលើនិវាសជនសេវាកម្មនានា	$56,964	$82,451	$68,456	$38,510	$47,860
ពន្ធកាត់ទុកលើអនិវាសជនសេវាកម្មនានា	$275,755	$170,383	$71,872	$236,046	$357,032
ពន្ធកាត់ទុកលើអនិវាសជន ការប្រាក់	$895,329	$1,084,350	$1,094,005	$725,590	$2,949,404
ពន្ធកាត់ទុកលើអនិវាសជនការបែងចែកភាគលាភ	$1,384,017	$-	$-	$-	$-
សរុប	**$5,488,402**	**$6,849,297**	**$10,976,708**	**$16,765,310**	**$21,140,724**
សរុបបង្គរទុក*	$25,829,340	$32,678,637	$43,655,345	$60,420,655	$81,561,379


* សរុប និងសរុបបង្គរទុក គិតចាប់តាំងពីឆ្នាំ 2003។

របាយការណ៍ **អភិវឌ្ឍន៍ធនធានមនុស្ស**

ដើម្បីជួយបុគ្គលិកឱ្យអភិវឌ្ឍន៍សមត្ថភាព ផ្នែកវិជ្ជាជីវៈ និងសមត្ថភាពផ្ទាល់ខ្លួនផង និងជម្រុញឱ្យមានការរីកចម្រើនផ្នែកការងារផង យើងបានចាត់ទុកការបណ្តុះបណ្តាលជាអាទិភាពនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិករបស់យើងនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ ដើម្បីគាំទ្រដល់កំណើនអាជីវកម្មនាយកដ្ឋានទទួលបន្ទុកផ្នែកជ្រើសរើសបុគ្គលិកបានធ្វើការយ៉ាងយកចិត្តទុកដាក់ដើម្បីទាក់ទាញបេក្ខជនដែលមានជំនាញនិងសក្តានុពលជាអ្នកដឹកនាំ ព្រមទាំងជ្រើសរើសបុគ្គលិកថ្មីបន្ថែមទៀតផងដែរ។ នៅក្នុងឆ្នាំ2022 នេះ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានដំឡើងហាន:ដល់បុគ្គលិកនៅក្នុងស្ថាប័នចំនួន373នាក់ និងមានបុគ្គលិកសរុបចំនួន 4,205 នាក់ ដែលក្នុងនោះមានបុគ្គលិកជាស្ត្រីចំនួន 796នាក់ បើប្រៀបធៀបកាលពីឆ្នាំកន្លងទៅ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានកំណត់យកការបណ្តុះបណ្តាលជាធាតុសំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស។ យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិករបស់យើង ដើម្បីឱ្យពួកគាត់មានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការងារបច្ចុប្បន្ន និងឆ្លើយតបទៅនឹងតម្រូវការការងារនាពេលអនាគត។ ក្នុងន័យនេះយើងប្តេជ្ញាក្នុងការបង្កើតនូវបទពិសោធន៍រៀនសូត្រដែលមានភាពទាក់ទាញ ឆ្លើយតបតាមតម្រូវការ និងអាចអនុញ្ញាតឱ្យបុគ្គលិកទាំងអស់ចូលរៀនសូត្របានតាមរយៈកម្មវិធី និងវិធីសាស្ត្របណ្តុះបណ្តាលផ្សេងៗ។





ក្នុងឆ្នាំ 2022 **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**. បានចំណាយទុនចំនួន 472,187 ដុល្លារអាមេរិក ដែលជាចំនួនទឹកប្រាក់ខ្ពស់បំផុតក្នុងរយៈពេល 3ឆ្នាំ ចុងក្រោយនេះ សម្រាប់ការអភិវឌ្ឍ សមត្ថភាពបុគ្គលិក តាមរយៈកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីប្រកួតប្រជែងចំណេះដឹងផ្សេងៗ ដើម្បីបង្កើនចំណេះដឹង និងជំនាញដល់បុគ្គលិករបស់ខ្លួនឱ្យមានលក្ខណៈសម្បត្តិជាបុគ្គលិកធនាគារពាណិជ្ជដ៏ពេញលេញ។ នៅឆ្នាំនេះយើងបានផ្តល់វគ្គបណ្តុះបណ្តាល ចំនួន 1,107 ដល់បុគ្គលិករបស់យើង ដែលក្នុងនោះមាន 993វគ្គ ជាការបណ្តុះបណ្តាលដែលរៀបចំឡើងខាងក្នុងស្ថាប័ន និង 49 វគ្គជាការបណ្តុះបណ្តាលខាងក្រៅស្ថាប័ន និង65វគ្គទៀតជាវគ្គបណ្តុះបណ្តាលដល់បុគ្គលិកថ្មី។ សរុបមកមានអ្នកចូលរួមទាំងអស់ចំនួន 130,469 នាក់ (63% តាមរយៈថ្នាក់និមិត្ត 28% តាមរយៈថ្នាក់រៀន និង 9% តាមរយៈអនឡាញ)។

មានបុគ្គលិកសរុបចំនួន

4,205

កើនចំនួន 422 នាក់ បើធៀបនឹងឆ្នាំមុន។

ចំនួនបុគ្គលិកដែលឡើងហាន:សរុប

373

ផ្តល់វគ្គបណ្តុះបណ្តាលសរុប 1,107 វគ្គ

គោលដៅចម្បងរបស់យើងក្នុងឆ្នាំ 2023 គឺដើម្បីលើកកម្ពស់សមត្ថភាពដល់បុគ្គលិកដែលមានស្រាប់ឱ្យកាន់តែមានចំណេះដឹង និងជំនាញ ប្រសើរជាងមុន និងពង្រឹងសមត្ថភាពដល់ប្រធានសាខារបស់យើងឱ្យក្លាយជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុ និងបណ្តុះបណ្តាលបុគ្គលិកថ្មីរបស់យើងឱ្យបានល្អនិងមានជំនាញច្បាស់លាស់មុនពេលចាប់ផ្តើមការងារ។ លើសពីនេះ យើងបន្តអ្នវត្តិ និងកសាងវប្បធម៌នៃការសិក្សារៀនសូត្រដល់បុគ្គលិកដែលមានស្រាប់របស់យើង តាមរយៈកម្មវិធីបណ្តុះបណ្តាលនានា និងការប្រកួតប្រជែងផ្សេងៗ ដូចជាការបណ្តុះបណ្តាលអំពីផលិតផលថ្មីៗ ការបណ្តុះបណ្តាលវគ្គរំលឹកឡើងវិញ ការបណ្តុះបណ្តាលលើមុខងារឯកទេសផ្សេងៗដល់បុគ្គលិកការិយាល័យរបស់យើង រួមទាំងប្រធាន និងអនុប្រធានសាខា មន្ត្រីគណៈទាន និងមន្ត្រីសន្សំ ជាដើម។ ការប្តេជ្ញាចិត្តរបស់យើងគឺរក្សាការរៀនសូត្រ និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកជាអាទិភាពរបស់យើង ដើម្បីធានាថាយើងបន្តបង្កើនសមត្ថភាពរបស់ពួកគេឲ្យបានពេញលេញក្នុងតួនាទីបច្ចុប្បន្ន និងអាចជួយឱ្យពួកគេត្រៀមខ្លួនរួចរាល់សម្រាប់តម្រូវការអាជីពការងារនាពេលអនាគតផងដែរ។

ការចែករំលែកបទពិសោធន៍ពីបុគ្គលិក



"ការបំពេញការងារដោយភាពស្មោះត្រង់ ការតាំងចិត្តខ្ពស់ ព្យាយាមធ្វើអ្វីដែលល្អបំផុតនោះអ្នកទទួលបានជោគជ័យលើវិថីការងារនៅពេលអនាគតជាក់ជាមិនខាន"

សុស ពុទ្ធានី
អ្នកគ្រប់គ្រងជាន់ខ្ពស់ប្រតិបត្តិការសាច់ប្រាក់
នាយកដ្ឋានរតនាគារ

ខ្ញុំបានចាប់ផ្តើមធ្វើការនៅធនាគារ អ៊ូរី នៅថ្ងៃទី 16 ខែសីហា ឆ្នាំ 2006 បើគិតទៅជិត 16 ឆ្នាំមកហើយ។ ការងារដំបូងរបស់ខ្ញុំគឺ ជាមន្ត្រីបម្រើសេវាអតិថិជន។ បន្ទាប់ពីធ្វើការនៅទីនេះមួយរយៈពេលខ្លី ខ្ញុំត្រូវបានផ្លាស់ប្តូរទៅជាបេឡាករ បន្ទាប់មកត្រូវបានតម្លើងតំណែងជាប់ន្តរបន្ទាប់ រហូតបច្ចុប្បន្ននេះជាអ្នកគ្រប់គ្រងជាន់ខ្ពស់ប្រតិបត្តិការសាច់ប្រាក់នៅក្នុងនាយកដ្ឋានរតនាគារ។ ការធ្វើការជាមួយធនាគារ អ៊ូរី គឺជាការសម្រេចចិត្តដ៏ល្អបំផុត។ ខ្ញុំជឿថាធ្វើការនៅធនាគារ អ៊ូរី គឺជាវិថីមួយដែលអាចជួយឱ្យការងារ និងជីវិតរបស់ខ្ញុំឱ្យកាន់តែប្រសើរ។

ថ្ងៃដែលរំភើបជាងគេនៅកន្លែងការងារសម្រាប់ខ្ញុំ អាចមានច្រើនដងគឺជាថ្ងៃដែលបានដំឡើងពីតំណែងមួយទៅមុខដំណែងមួយ ដែលខ្ពស់ជាងមុន។ ខ្ញុំពិតជារីករាយនៅពេលដែលមានឱកាស រៀនសូត្រពីអ្វីដែលថ្មីៗ ទាំងបទពិសោធន៍ការងារ និងការគ្រប់គ្រងបុគ្គលិកផងដែរ។ អាចនិយាយបាន ថាជាពេលដែលមានអារម្មណ៍ដែលរំភើប និងមានមោទនភាពចំពោះខ្លួនឯង ដែលបានឆ្លងកាត់ នូវការងារនិងការផ្លាស់ប្តូរតំណែងជាច្រើនតាំងពីកម្រិតដំបូង រហូតមកតំណែងការងារបច្ចុប្បន្ននេះ ជិត10 តំណែងមកហើយ។

កត្តាលើកទឹកចិត្ត៖ ធនាគារ អ៊ូរី តែងតែផ្តល់ឱ្យខ្ញុំនូវឱកាសដល់ខ្ញុំជានិច្ច រួមមានទាំងបរិយាកាសការងារដ៏រីករាយ ទំនាក់ទំនងល្អក្នុងការងារ ភាពជាអ្នកដឹកនាំល្អ ការងារជាក្រុម និងបុគ្គលិកដែលឧស្សាហ៍ព្យាយាម។ ពួកគេមានទំនួលខុសត្រូវខ្ពស់ក្នុងការធានាថាការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ បរិយាកាសការងារ ក្រុមការងារ គឺជាកត្តាមួយដែលធ្វើឱ្យខ្ញុំកក់ក្តៅនៅក្នុងការបំពេញការងារប្រចាំថ្ងៃ ។ ការធ្វើការ ដែលមានការរាប់អាន យល់ចិត្ត យល់ច្បើម និងជួយគ្នាដែលលើសពីមិត្តរួមការងារទៅទៀត។ ជាពិសេសគឺការជួយ បង្រៀន ណែនាំគ្នាទៅវិញទៅមកជាមួយគំនិត មតិយោបល់ល្អៗ ចំណុចទាំងនេះហើយ ដែលនាំឱ្យមានបុគ្គលិកដែលបំពេញការងារនៅទីនេះ អាចបំពេញការងារ រយៈពេលយូរ និងកាន់តែវែករាយក្នុងការបំពេញការងារ ដែលភាគច្រើនមានតែនៅទីនេះប៉ុណ្ណោះ ។ ខ្ញុំមានអារម្មណ៍ថាទីនេះជាគ្រួសារទីពីររបស់ខ្ញុំអញ្ចឹង។ ហេតុផលទាំងនេះបានធ្វើឱ្យខ្ញុំមានអារម្មណ៍កក់ក្តៅ និងដឹងគុណ ដែលបានធ្វើការនៅធនាគារ អ៊ូរី។

គោលដៅការងារ៖ តាមពិតទៅការងារដំបូងរបស់ខ្ញុំ គឺការងារគ្រូបង្រៀននៅបឋមសិក្សារ ដែលកាលនោះបាន ប្រាក់ខែត្រឹមតែ 10 មឺនរៀលប៉ុណ្ណោះ។ រីឯការងារក្រោយពីបាន ចាប់អាជីពនៅទីនេះ ខ្ញុំមានលទ្ធភាពទៅរៀនបន្តកម្រិតបរិញ្ញបត្រ និងត្រូវបានផ្លាស់ប្តូរទៅជាបេឡាករ បន្ទាប់មកត្រូវបានតម្លើងតំណែងជាបន្តបន្ទាប់ជាជំនួយការអ្នកគ្រប់គ្រងគណនេយ្យករប្រចាំតំបន់ អ្នកគ្រប់គ្រង គណនេយ្យករប្រចាំតំបន់ ហើយឥឡូវនេះជាអ្នកគ្រប់គ្រងជាន់ខ្ពស់នៃប្រតិបត្តិការសាច់ប្រាក់នៅក្នុងនាយកដ្ឋានរតនាគារ។ លើសពីសមត្ថភាពការងារ ភាពជាអ្នកដឹកនាំការប្រើប្រាស់តាសាសួធ្នែតទទួលបានពីទីនេះ ។ បើនិយាយអំពីគោលដៅជីវិតវិញ ខ្ញុំបានបន្តរការអភិវឌ្ឍសមត្ថភាពខ្លួនឯងជាបន្តបន្ទាប់ និងអាចមានលទ្ធភាព ផ្គត់ផ្គង់គ្រួសារក្នុងបាន:ជាអ្នករកចំណូលគោល មានជីវភាពសមរម្យ មានលំនៅដ្ឋាននិងធីង ហ្នឹងគេហ្នឹងឯង។

ដំបូន្មាន ៖ ធនាគារ អ៊ូរី ជាស្ថាប័នការងារដែលមានស្ថិរភាព ជាប្រភពឱកាស និងបទពិសោធន៍ថ្មីៗដែលអ្នកនឹងមិនដែលជួបពីមុនមក។ កន្លែងធ្វើការមិនមែនត្រឹមជា កន្លែងដែលគ្រាន់តែមកធ្វើការប៉ុណ្ណោះទេ តែវាជាកន្លែងដែលយើងអាច ស្រូបយកនូវចំណេះដឹងសម្រាប់ការអនុវត្តជាក់ស្តែងដែលមិនមាននៅតាម សាលារៀននោះទេ។ យើងអាចជាផ្នែកមួយនៃការជួយប្រជាជនក្នុងការអប់រំផ្នែកហិរញ្ញវត្ថុរបស់ពួកគេតាមរយៈការងាររបស់យើងនៅក្នុងធនាគារនេះ ហើយយើងក៏អាចជាផ្នែកមួយនៃការកែលម្អបច្ចេកវិទ្យាលើវិស័យធនាគារផងដែរ។ សូមចងចាំថា "ការខិតខំប្រឹងប្រែងដោយមានការតាំងចិត្តខ្ពស់ និងភាពស្មោះត្រង់នឹងនាំអ្នកទៅរកភាពជោគជ័យក្នុងដំណើរអាជីពការងាររបស់អ្នកនាពេលអនាគតជាក់ជាមិនខាន"។



> *“សម្រេចបានរឿងរ៉ាវល្អៗជាច្រើនក្នុងរយៈពេលជាង 10 ឆ្នាំរបស់ខ្ញុំនៅទីនេះ ដូចជាការក្លាយជាថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងមួយរូប ហើយអ្វីដែលពិសេសជាងគេបំផុតនោះ គឺការមានគ្រួសារដ៏មានសុភមង្គល។”*

ហាក់ សុភ័ក្រ
អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ

បានធ្វើការនៅធនាគារ អ៊ូរី ចាប់តាំងពីខែតុលា ឆ្នាំ 2012 ជាបុគ្គលិកហាត់ការផ្នែករដ្ឋបាល។ ពីមួយឆ្នាំទៅមួយឆ្នាំ ខ្ញុំត្រូវបានតម្លើងឋានៈពីថ្នាក់តូច ទៅបុគ្គលិកជាន់ខ្ពស់ ដោយឆ្លងកាត់មុខតំណែងជាច្រើន ពេលបច្ចុប្បន្ននេះ ខ្ញុំជាអនុប្រធាននាយកដ្ឋានកិច្ចការទូទៅនៅការិយាល័យកណ្តាល បន្ទាប់ពីឆ្លងកាត់បទពិសោធន៍នៅទីនេះអស់រយៈពេល 10 ឆ្នាំ 6 ខែ។ ការងាររបស់ខ្ញុំបានចាប់ផ្តើមនៅពេលដែលខ្ញុំជ្រើសរើសធនាគារ អ៊ូរី លើស្ថាប័នពីរផ្សេងទៀត ដែលខ្ញុំបានជាប់ការសម្ភាសន៍ពេលនោះ។ វាគឺជាការសម្រេចចិត្តដ៏ត្រឹមត្រូវសម្រាប់ខ្ញុំ ដែលជ្រើសរើសទីនេះ ដោយខ្ញុំបានរៀនសូត្រជាច្រើនជាមួយនឹងការងារផ្សេងៗពីគម្រូអ្នកដឹកនាំ និងអ្នកគ្រប់គ្រងដ៏ល្អជាច្រើន។

នៅធនាគារ អ៊ូរី ថ្ងៃល្អបំផុតរបស់ខ្ញុំនៅកន្លែងធ្វើការអាចមានអត្ថន័យខុសពីបទពិសោធន៍របស់អ្នកដទៃ។ ខ្ញុំចងចាំរយៈពេលដ៏លំបាកបំផុតសម្រាប់ខ្ញុំក្នុងឋានៈជាមន្ត្រីទទួលបន្ទុកប្រធាននាយកដ្ឋានរដ្ឋបាល ដែលរួមមានទំនួលខុសត្រូវផ្លាស់ប្តូរឈ្មោះ និងយីហោទាំងមូល និងការផ្លាស់ប្តូរបុគ្គលិកយ៉ាងច្រើនក្នុងអំឡុងពេលប្រធាននាយកដ្ឋានរបស់ខ្ញុំបានឈប់សម្រាកលំហែមាតុភាពរយៈពេលបីខែរបស់គាត់។ ពេលដែលខ្ញុំអាចបញ្ចប់គម្រោងលំបាកៗទាំងនោះ ទាំងខ្ញុំមិនដែលបានធ្វើពីមុនហើយបានបញ្ចប់គម្រោងប្រកបដោយលទ្ធផលល្អនោះហើយគឺជាថ្ងៃដ៏ល្អបំផុតរបស់ខ្ញុំ។

ធនាគារ អ៊ូរី គឺជាសាលារៀន និងជាគ្រួសារ ទីពីររបស់ខ្ញុំ ដែលជួយបង្រៀនជំនាញរបស់ខ្ញុំជារៀងរាល់ថ្ងៃ។ ខ្ញុំមានមោទនភាពដែលបានធ្វើការនៅធនាគារ អ៊ូរី ដោយសារតែធនាគារ អ៊ូរី គឺជាធនាគារលំដាប់សាកលដែលមានបណ្តាញសាខា 23 ប្រទេស និងមានអាយុកាលជាង 120 ឆ្នាំមកហើយ។ **“ខ្ញុំសម្រេចបានរឿងរ៉ាវល្អៗជាច្រើនក្នុងរយៈពេលជាង 10 ឆ្នាំរបស់ខ្ញុំនៅទីនេះ ដូចជាការក្លាយជាថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងមួយរូប ហើយអ្វីដែលពិសេសជាងគេបំផុតនោះ គឺការមានគ្រួសារដ៏មានសុភមង្គល។ ការធ្វើការនៅធនាគារ អ៊ូរី នឹងផ្តល់ឱ្យអ្នកនូវរឿងល្អៗជាច្រើន ដើម្បីលើកទឹកចិត្តអ្នកលើសពីការងារ។ ក្រុមការងារល្អ អ្នកដឹកនាំល្អ បុគ្គលិកល្អ និងនីតិវិធីការងារប្រកបដោយប្រសិទ្ធភាព គឺជាកត្តាជំរុញទឹកចិត្តដ៏សំខាន់សម្រាប់ខ្ញុំក្នុងការធ្វើការនៅទីនេះ”**។

សម្រាប់អ្នកដែលមានបំណងស្វែងរកការងារនៅធនាគារ អ៊ូរី ខ្ញុំសូមណែនាំថា ធនាគារមានចក្ខុវិស័យ និងបេសកកម្មច្បាស់លាស់ក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុតដល់អតិថិជន។ ធនាគារ អ៊ូរី ផ្តោតលើការបង្កើនសមត្ថភាពបុគ្គលិកដោយមានយុទ្ធសាស្ត្របណ្តុះបណ្តាល ដល់បុគ្គលិកជាបន្តបន្ទាប់ ។ ធនាគារ អ៊ូរី គឺជាកន្លែងការងារដ៏ល្អមួយដើម្បីចាប់ផ្តើមអាជីពរបស់អ្នក អភិវឌ្ឍជំនាញថ្មីៗ និងរៀនសូត្រការងារថ្មីជារៀងរាល់ថ្ងៃ។

ព័តិមានសំខាន់ៗ



ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ចុះអនុស្សរណៈជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីផ្តល់អាហារូបករណ៍ចំនួន 100កន្លែងក្នុងមួយឆ្នាំដល់និស្សិត

ភ្នំពេញ៖ នៅថ្ងៃទី10 ខែមករា ឆ្នាំ2023 ធនាគារ អ៊ូរី និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ(RUPP) បានចុះអនុស្សរណៈនៃការយោគយល់គ្នា ក្នុងការផ្តល់អាហារូបករណ៍ចំនួន 100កន្លែង ស្មើនឹង 50,000 ដុល្លារក្នុងមួយឆ្នាំ ដល់និស្សិតថ្នាក់បរិញ្ញាបត្រលើមុខជំនាញឯកទេសសំខាន់ៗ រួមមានឯកទេសបង្កើតថ្មី និងមានស្រាប់ ដូចជា៖ នគរូបនីយកម្ម និងការអភិវឌ្ឍន៍ក្រុងប្រកបដោយចីរភាព អភិវឌ្ឍន៍សេដ្ឋកិច្ច អភិវឌ្ឍន៍សហគមន៍ វិទ្យាសាស្ត្រកុំព្យូទ័រ គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ និងគណិតវិទ្យា។

កម្មវិធីប្រារព្ធឡើងក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញព្រមទាំងសហការី សាស្ត្រាចារ្យ សមាជិកមហាវិទ្យាល័យ បុគ្គលិកសិក្សា និងនិស្សិត និងលោក គីម ហុងជូ អគ្គនាយកប្រតិបត្តិនៃធនាគារ អ៊ូរី និងគណៈគ្រប់គ្រងជាន់ខ្ពស់ ។

ក្នុងឱកាសបើកពិធីនេះ **លោក គីម ហុងជូ** អគ្គនាយកប្រតិបត្តិនៃធនាគារ អ៊ូរី បានមានប្រសាសន៍ថា “ជាមួយនឹងបាវចនារបស់យើង យើងកំពុងធ្វើសកម្មភាពយ៉ាងសកម្មនូវ ទំនួលខុសត្រូវសង្គមរបស់សាជីវកម្មនៅក្នុងវិស័យជាច្រើនដូចជា សាលារៀន មន្ទីរពេទ្យ និងមណ្ឌលកុមារកំព្រា។ ហើយថ្ងៃនេះ ធនាគារ អ៊ូរី យើងមានសេចក្តីសោមនស្សរីករាយជាខ្លាំងដែលបានធ្វើជាដៃគូជាមួយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្ស។ ជំនួយហិរញ្ញវត្ថុរបស់យើងនឹងជួយសិស្សឱ្យបញ្ចប់ការសិក្សារបស់ពួកគេដោយជោគជ័យ ហើយពួកគេនឹងមានឱកាសការងារជាមួយ ធនាគារ អ៊ូរី ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សិស្សានុសិស្សទាំងអស់ដែលទទួលបានអាហារូបករណ៍ពី ធនាគារ អ៊ូរី នឹងក្លាយជាជំហាននៃការអភិវឌ្ឍន៍របស់កម្ពុជា។

ធនាគារ អ៊ូរី មើលឃើញពីសារៈសំខាន់នៃការអប់រំដែលជាឆ្អឹងខ្នងដ៏សំខាន់សំរាប់ការអភិវឌ្ឍប្រទេសកម្ពុជា។ គោលដៅរបស់ធនាគារ គឺការកែចំរើនប្រកបដោយចីរភាពជាមួយកម្ពុជា។ ដូច្នេះហើយ ការជួយជ្រោមជ្រែងទៅដល់វិស័យអប់រំនៅកម្ពុជា គឺជាផ្នែកមួយនៃកម្មវិធីទំនួលខុសត្រូវសង្គមសាជីវកម្មរបស់ខ្លួន។



ធនាគារ អ៊ូរី បានបិទបញ្ចប់ដោយជោគជ័យ កម្មវិធី “ការបណ្តុះបណ្តាលពន្លកថ្មី ជំនាន់ទី1

ធនាគារ អ៊ូរី បិទបញ្ចប់កម្មវិធី បណ្តុះបណ្តាលពន្លកថ្មីជំនាន់ទី1 ដោយជោគជ័យនៅថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2022 បន្ទាប់ពីបានបណ្តុះបណ្តាលអ្នកចូលរួមយ៉ាងមានប្រសិទ្ធភាពអស់រយៈពេល 3 ខែ។ កម្មវិធីនេះត្រូវបានចាប់ផ្តើមពីខែមេសា ដល់ខែកក្កដា ឆ្នាំ 2022។ គោលបំណងរបស់កម្មវិធីគឺដើម្បីជួយនិស្សិតកំពុងសិក្សា និងទើបបញ្ចប់ការសិក្សាថ្មីៗដែលមិនមានបទពិសោធន៍ពីមុន ដោយផ្តល់ឱ្យពួកគេនូវកម្មវិធីពង្រឹងសមត្ថភាពដ៏ទូលំទូលាយដែលនឹងពន្លឿនចំណេះដឹងការងារផ្នាល់ និងសមត្ថភាពរបស់ពួកគេនៅធនាគារ អ៊ូរី។ ជំនាន់នេះមានអ្នកចូលរួមចំនួន 45 នាក់ដែលត្រូវបានជ្រើសរើសដោយផ្អែកលើសមត្ថភាព និងចាប់ពីឆ្នាំសិក្សាទី2 ឡើងទៅ។





ធនាគារ អ៊ូរី បានចូលរួមចំណែកជាមួយ ធនាគារ ជាតិនៃកម្ពុជាដើម្បីចែកអំណោយ ដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយសារ ទឹកជំនន់ ក្នុងខេត្តកំពង់ធំ

នៅថ្ងៃទី 27 ខែតុលា ឆ្នាំ2022 ធនាគារ អ៊ូរី បានចូលរួមចំណែកនៅក្នុងការងារសប្បុរសជាមួយ ធនាគារ ជាតិនៃកម្ពុជា តាមរយៈសមាគមធនាគារ នៅកម្ពុជា នូវទឹកប្រាក់ចំនួន 3000ដុល្លារ ដើម្បីចូលរួមចែកអំណោយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយសារ ទឹកជំនន់ ចំនួនជាង 500គ្រួសារ ស្ថិតនៅឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ។



ទិវាអតិថិជន អ៊ូរី ទិវានៃការថ្លែងអំណរគុណ ដល់អតិថិជនទាំងអស់ របស់ធនាគារអ៊ូរី !

ភ្នំពេញ៖ ថ្ងៃទី21 ខែកញ្ញា ឆ្នាំ2022 ត្រូវបានកំណត់ជាថ្ងៃនៃទិវាអតិថិជន អ៊ូរី ដែល ត្រូវបានធ្វើឡើងជាលើកដំបូង ក្រោយពីបានក្លាយខ្លួនជា ធនាគារពាណិជ្ជកាលពីដើមឆ្នាំ 2022។ កម្មវិធីនេះ ប្រារព្ធឡើងក្នុង គោលបំណងបីសំខាន់ៗ រួមមាន ៖

1. ដើម្បីថ្លែងអំណរគុណ ដល់អតិថិជនរបស់ធនាគារ អ៊ូរី ទាំងអស់នៅគ្រប់ការិយាល័យសាខា។
2. ដើម្បីបង្កើនទំនាក់ទំនងរវាង ថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ អ៊ូរី ជាមួយអតិថិជន និងបុគ្គលិកសាខា តាមរយៈ ការបម្រើសេវាកម្មដោយផ្ទាល់ជូនដល់អតិថិជន នៅតាមបណ្តាសាខាទាំង 138 ទូទាំងប្រទេស។
3. ដើម្បីបង្កើតនូវបទពិសោធន៍ល្អៗ និងអារម្មណ៍ល្អៗ ជូនដល់អតិថិជនរបស់ធនាគារ អ៊ូរី នៅគ្រប់បណ្តាសាខាទាំងអស់ ក៏ដូចជាបង្ហាញឱ្យឃើញថា ការបម្រើសេវាអតិថិជន គឺជាទំនួលខុសត្រូវរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ រួមទាំងថ្នាក់គ្រប់គ្រងជាន់ខ្ពស់គ្រប់កម្រិតផងដែរ។

ចាប់ពីម៉ោង 8:00 ព្រឹក រហូត ដល់ 12:00 ថ្ងៃត្រង់ រាល់អតិថិជនទាំងអស់ដែលអញ្ជើញមកទទួលសេវាកម្មនៅ ធនាគារអ៊ូរី ដែលមានដូចជា បើកគណនី ដាក់ប្រាក់ ទូទាត់ប្រាក់កម្ចី ផ្ទេរប្រាក់ និងសេវាកម្មផ្សេងៗទៀត នឹងត្រូវបានអញ្ជើញជាភ្ញៀវកិត្តិយសជាមួយនឹងសេវាកម្មពិសេស ដែលមិនធ្លាប់មានពីមុនមក។

អតិថិជនដែលបានចូលរួម ទទួលបានការប្រគល់ជូននូវកាដូរអាហារសម្រន់ តេសជ្ជៈ ដើម្បីជាការស្វាគមន៍អតិថិជនពីសំណាក់លោកអគ្គនាយកប្រតិបត្តិ គណៈគ្រប់គ្រងគ្រប់ជាន់ខ្ពស់ និងប្រធានសាខា។ កម្មវិធីនេះ សបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ និងថ្លែងអំណរអរគុណពីសំណាក់ ធនាគារ អ៊ូរី ដល់អតិថិជនចំពោះការគាំទ្រ និងជឿជាក់មកលើសេវាកម្មហិរញ្ញវត្ថុរបស់យើងជាច្រើនឆ្នាំកន្លងមកនេះ។





អបអរសាទរទិវាអន្តរជាតិនារី!

នាព្រឹកថ្ងៃអង្គារ ទី08 ខែមីនា ឆ្នាំ2022 ថ្នាក់ដឹកនាំ**ធនាគារអ៊ូរី** បានចែកជូនផ្កាដល់បុគ្គលិកនារីគ្រប់ជាន់ថ្នាក់ក្នុងឱកាសទិវាអន្តរជាតិនារីដែលជាកម្លាំងមួយដ៏សំខាន់ក្នុងការជម្រុញការអភិវឌ្ឍរបស់គ្រួសារ ស្ថាប័ន និងសង្គមជាតិឈានទៅរកភាពរីកចម្រើន។ ស្ត្រីជាមាតានៃពិភពលោក សូមរួមគ្នាលើកកម្ពស់សិទ្ធិស្ត្រី ផ្តល់តម្លៃដល់ស្ត្រី និងសូមជូនពរឱ្យស្ត្រីគ្រប់រូបជួបតែសេចក្តីសុខ សុភមង្គល គ្រប់ក្រុមគ្រួសារ។





ធនាគារ អ៊ូរី បានប្រគល់រង្វាន់ជាទឹកប្រាក់ជិតមួយម៉ឺនដុល្លារសហរដ្ឋអាមេរិក ដល់ម្ចាស់ជ័យលាភី 3រូប ពីការប្រកួតប្រជែងរចនា UXUI របស់កម្មវិធីធនាគារ ចល័តជំនាន់ថ្មី!

ភ្នំពេញ៖ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2022 នៅទីស្នាក់ការកណ្តាលនៃ**ធនាគារ អ៊ូរី** បានប្រារព្ធកម្មវិធីប្រគល់រង្វាន់ដល់ម្ចាស់ជ័យលាភីទាំង 3រូប ពីការប្រកួតប្រជែងរចនាUXUI របស់កម្មវិធីធនាគារ ចល័តជំនាន់ថ្មី សរុបជាទឹកប្រាក់ចំនួន **9,000** ដុល្លាសហរដ្ឋអាមេរិក។ ម្ចាស់ជ័យលាភីទាំងបីរូប ទទួលបាននូវ ប្រាក់រង្វាន់ជាទឹកប់ចិត្តចំនួន **5,000** ដុល្លារ **3,000** ដុល្លារ និង **1,000** ដុល្លារ តាមលំដាប់ លេខ1 លេខ2 និងលេខ3។ កម្មវិធីប្រគល់រង្វាន់នេះ សបញ្ជាក់ពីការយកចិត្តទុកដាក់របស់ ធនាគារ អ៊ូរី ទៅលើការបង្កើតនូវបទពិសោធន៍ថ្មី នៃការប្រើប្រាស់កម្មវិធីធនាគារចល័ត និងធនាគារឌីជីថល ដែលស្របតាមនិន្នាការ នៃការប្រើប្រាស់និងតម្រូវការរបស់អតិថិជន នៅក្នុងយុគសម័យឌីជីថល។ កម្មវិធីប្រកួតប្រជែងរចនា UXUI របស់Woori Bank Mobile Banking ត្រូវបានប្រកាសចាប់ផ្តើមបើកទទួលការបង្ហាញស្នាដៃរយៈពេល2ខែពេញ ដោយចាប់ផ្តើមឡើងតាំងពី ថ្ងៃទី01 ខែមិថុនា រហូតដល់ថ្ងៃទី 31 ខែកក្កដា ឆ្នាំ2022។



ធនាគារ អ៊ូរី បានចូលរួមឧបត្ថម្ភដល់កម្មវិធី “យុទ្ធនាការបរិច្ចាគឈាមរួមគ្នាសង្គ្រោះជីវិត”

នៅថ្ងៃទី12 ខែឧសភា ឆ្នាំ2022 - ធនាគារ អ៊ូរី បានចូលរួមឧបត្ថម្ភដល់កម្មវិធី “យុទ្ធនាការបរិច្ចាគឈាមរួមគ្នាសង្គ្រោះជីវិត” ដែលបានរៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងបានសហការជាមួយ សហភាពសហព័ន្ធយុវជនកម្ពុជា របស់ធនាគារជាតិនៃកម្ពុជា និងសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានីភ្នំពេញ ដើម្បីជួយសង្គ្រោះដល់ប្រជាជនដែលត្រូវការឈាម ក៏ដូចជាទ្រទ្រង់ដល់មន្ទីរពេទ្យគន្ធបុប្ផា។បុគ្គលិក និងគណៈគ្រប់គ្រងរបស់ ធនាគារ អ៊ូរី សរុបចំនួន 20រូប បានចូលរួមបរិច្ចាគឈាមក្នុងយុទ្ធនាការដ៏ល្អនេះដើម្បីចូលរួមចំណែកក្នុងសង្គម និងជួយសង្គ្រោះជីវិតអ្នកដែលមានបញ្ហា។ ការបរិច្ចាគឈាម បានឆ្លុះបញ្ចាំងអំពីសេចក្តីស្រឡាញ់ និងការចែករំលែកដ៏ធំធេងសម្រាប់សង្គ្រោះជីវិតដល់អ្នកដែលត្រូវការបំផុត។



ធនាគារ អ៊ូរី បានចូលរួមឧបត្ថម្ភដល់កម្មវិធី CHANGWON K-POP WORLD FESTIVAL 2022

នៅថ្ងៃទី17 ខែមិថុនា ឆ្នាំ2022 - ធនាគារ អ៊ូរី បានចូលរួមឧបត្ថម្ភដល់កម្មវិធី “CHANGWON K-POP WORLD FESTIVAL 2022” ដែលបានរៀបចំឡើងដោយ K’ve Entertainment និងបានសហការជាមួយស្ថានទូតកូរ៉េប្រចាំនៅកម្ពុជា ជាមួយដៃគូជាច្រើនទៀត ដើម្បីស្វែងរកបេក្ខជនដែលមានសមត្ថភាពយ៉ាងអស្ចារ្យក្នុងការប្រកួតក្បាច់រាំ និងចម្រៀង ដែលបានប្រារព្ធធ្វើឡើងនៅសាល CKCC។ កម្មវិធីក៏បានបង្ហាញអំពីមិត្តភាពខួបលើកទី25ឆ្នាំ រវាងប្រទេសកូរ៉េ និងប្រទេសកម្ពុជាផងដែរ។



ទិវាបរិច្ចាគឈាម ដើម្បីសង្គ្រោះជីវិត ពីធនាគារ អ៊ូរី

ភ្នំពេញ៖ ថ្ងៃទី19 ខែតុលា ឆ្នាំ2022 ធនាគារ អ៊ូរី បានធ្វើការសហការជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម ដើម្បីរៀបចំកម្មវិធីផ្តល់ឈាមដោយស្ម័គ្រចិត្ត ក្រោមប្រធានបទ **“ទិវាបរិច្ចាគឈាម ដើម្បីសង្គ្រោះជីវិត”** នៅទីស្នាក់ការកណ្តាល ដែលមានទីតាំង នៅតាមបណ្តោយ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពី **លោកវេជ្ជបណ្ឌិត លី សុវិទ្យ** អនុប្រធានមជ្ឈមណ្ឌលជាតិផ្តល់ឈាម ព្រមទាំងសហការី និង **លោក ហ៊ុន សុភ័ក្ត្រ** អគ្គនាយកប្រតិបត្តិការ ក្រុមអាជីវកម្ម1 គណៈគ្រប់គ្រង និងបុគ្គលិករបស់ **ធនាគារ អ៊ូរី** ចំនួន60នាក់។

មូលនិធិ Love Fund

មូលនិធិ Love Fund មានគោលបំណងកសាងស្មារតីទំនួលខុសត្រូវសង្គមក្នុងចំណោមបុគ្គលិកតាមរយៈការបរិច្ចាគស្ម័គ្រចិត្តប្រចាំខែ។ មូលនិធិដែលបានបង្កើតឡើងតាំងពីខែធ្នូ ឆ្នាំ 2012 ត្រូវបានប្រើដើម្បីផ្តល់ជំនួយដល់បុគ្គលិក គ្រួសាររបស់ពួកគេ ក្នុងគ្រាលំបាក និងកិច្ចការសង្គមផ្សេងទៀត។

គិតត្រឹមខែធ្នូ ឆ្នាំ 2022 បុគ្គលិករបស់ធនាគារ អ៊ូរី បានរួមចំណែកក្នុង “មូលនិធិ Love Fund ” ចំនួន 185 ករណី ដល់ គ្រួសារ និងសហគមន៍របស់បុគ្គលិក ដែលប្រឈមមុខនឹងបញ្ហាសរុបជាទឹកប្រាក់ចំនួន 52,820 ដុល្លារអាមេរិក សម្រាប់ពិធីបុណ្យសព គ្រោះមហន្តរាយ ការព្យាបាលវេជ្ជសាស្ត្រ និងកិច្ចការសង្គមផ្សេងទៀត។

ជាពិសេសជាមួយនឹងខួបគម្រប់ 10 ឆ្នាំនៃមូលនិធិ Love Fund (25-ធ្នូ-2012 ដល់ 25-ធ្នូ-2022) បុគ្គលិករបស់ **ធនាគារ អ៊ូរី** បានធ្វើសកម្មភាពសប្បុរសធម៌នៅគ្រប់ការិយាល័យប្រចាំតំបន់ ការិយាល័យសាខា និងការិយាល័យកណ្តាល ដល់ប្រជាពលរដ្ឋដែលត្រូវការជំនួយ មន្ទីរពេទ្យ និងកិច្ចការសង្គមផ្សេងៗទៀត ដែលចំនួនវិភាគទានបន្ថែមគឺ USD 10,000 ។



អំពីភាពជោគជ័យ
របស់អតិថិជន



អ្នកស្រី ទទួលបានប្រាក់កម្ចីពី**ធនាគារ អ៊ូរី** ចំនួន 25,000$ ដើម្បីយកមកពង្រីកមុខរបរបោះដុំតវ៉ាន់ចាប់ហួយ ជាទុនសម្រាប់ការទិញតវ៉ាន់ចាប់ហួយបន្ថែម ក៏ដូចជាការពង្រីកឃ្លាំងដាក់តវ៉ាន់ផងដែរ

អតិថិជនឈ្មោះ នាង ចាន់សី

អ្នកស្រី នាង ចាន់សី អាយុ 36ឆ្នាំ និងស្វាមី អាយុ 38ឆ្នាំ មានមុខរបរជាអ្នកលក់និងបោះដុំតវ៉ាន់ចាប់ហ្គួយ មានទីលំនៅភូមិគរ ឃុំ ជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប។ សព្វថ្ងៃអ្នកស្រីនិងគ្រួសារមានកូនចំនួន2នាក់ កូនទី1 អាយុ13ឆ្នាំ កំពុងនៅរៀនសាលាបឋមសិក្សា និងកូនទី2 អាយុ8ឆ្នាំ ក៏កំពុងតែរៀនសាលាបឋមសិក្សាផងដែរ។

អ្នកស្រីនិងស្វាមី ទទួលបានប្រាក់កម្ចីពីធនាគារ អ៊ូរី ចំនួន 25,000$ ដើម្បីយកមកពង្រីកមុខរបរបោះដុំតវ៉ាន់ចាប់ហួយ។ ក្រោយពីទទួលបានប្រាក់កម្ចី អ្នកស្រីក៏បានយកធ្វើជាទុនតាមរយៈការទិញតវ៉ាន់ចាប់ហួយបន្ថែម ក៏ដូចជាការពង្រីកឃ្លាំងដាក់តវ៉ាន់ផងដែរ។

កាលពីមិនទាន់ទទួលបានប្រាក់កម្ចី ដើមទុន និងលុយបង្វិលរកស៊ី ជីវភាពរស់នៅប្រចាំថ្ងៃមានសភាពខ្វះខាត ផ្ទះមានទំហំតូចចង្អៀត ហូបចុកមិនសូវគ្រប់គ្រាន់ សំលៀកបំពាក់មិនស្អាតកូនៗក៏មិនទទួលបានអាហារូបត្ថម្ភល្អនោះទេ។

អ្នកស្រីបានបញ្ជាក់អំពីចំណូល ក្រោយពីទទួលបានកម្ចីធនាគារ អ៊ូរី ថានាពេលបច្ចុប្បន្ននេះ ចំណូលរបស់ខ្ញុំក្នុងមួយថ្ងៃ ចន្លោះពីមួយលានរៀលទៅពីរលានរៀល។ អតិថិជនកាន់តែច្រើនជាងមុន នេះដោយសារតែតវ៉ាន់នៅក្នុងស្តុកមានច្រើនប្រភេទ អាចទាក់ទាញម៉ូយបានកាន់តែច្រើននិងរីកចម្រើនកាន់តែខ្លាំងផងដែរ។

អ្នកស្រីក៏បានអរគុណដល់ធនាគារ អ៊ូរី ដែលជឿជាក់ និងបានផ្តល់ជាមតិយោបល់ល្អៗ ព្រមទាំងផ្តល់នូវកម្ចីសម្រាប់អាជីវកម្មរបស់គាត់ឱ្យកាន់តែរីកចម្រើនជាលំដាប់ផងដែរ។



ក្រោយពីទទួលបានប្រាក់កម្ចីពី **ធនាគារ អ៊ូរី** បានជួយឱ្យអាជីវកម្មរបស់គាត់រីកធំជាងមុន នឹងរកប្រាក់ចំណូលបានច្រើនជាងមុន25%ផងដែរ

អតិថិជនឈ្មោះ ថា សារឿន

អ្នកស្រី ថា សារឿន អាយុ32ឆ្នាំ សព្វថ្ងៃរស់នៅភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មានមុខរបរជាអ្នកលក់ដូរចាប់ហួយនៅផ្ទះ។

អ្នកស្រីបានទទួលប្រាក់កម្ចីពីធនាគារ អ៊ូរី ចំនួនមួយវគ្គដើម្បីយកទៅពង្រីកអាជីវកម្មលក់តវ៉ាន់ចាប់ហួយ ដែលកាលពីមុនអ្នកស្រីទទួលបានប្រាក់កម្រៃចំនួន 25ម៉ឺនរៀលក្នុងមួយថ្ងៃតែប៉ុណ្ណោះ មុនពេលពេលទទួលបានប្រាក់កម្ចីពីធនាគារ អ៊ូរី។

ក្រោយពីទទួលបានប្រាក់កម្ចីពីធនាគារ អ៊ូរី បានជួយឱ្យអាជីវកម្មរបស់គាត់រីកធំជាងមុន នឹងរកប្រាក់ចំណូលបានច្រើនជាងមុន25%ផងដែរ។ ក្នុងនោះក៏បានជួយដល់ជីវភាពគ្រួសារធូរធារជាងមុនមួយកម្រិតផងដែរ។ ដោយសារតែអាជីវកម្មធំជាងមុនមួយកម្រិត នឹងអាចរកប្រាក់ចំណូលបានច្រើនជាងមុន ធ្វើឱ្យគាត់អាចផ្តត់ផ្តង់ទៅលើការសិក្សារបស់កូនៗគាត់ប្រសើរជាងមុន ក៏ដូចជាអាចមានលទ្ធភាពក្នុងការទិញសម្ភារៈក្នុងផ្ទះមួយចំនួនសម្រាប់ប្រើប្រាស់ផងដែរ។ លើសពីនោះ គាត់ក៏មានគម្រោងបន្ទាប់ក្នុងការពង្រីកអាជីវកម្មឱ្យកាន់តែធំជាងនេះបន្តបន្ទាប់ផងដែរ ដែលនឹងមានរថយន្តសម្រាប់ដឹកជញ្ជូនឱ្យបានគ្រប់គ្រាន់សម្រាប់ការបោះដុំតវ៉ាន់ក្នុងតំបន់របស់គាត់នាពេលអនាគត។ ពួកគាត់ពិតជាសប្បាយចិត្តជាខ្លាំងដែលអាចទទួលបានជោគជ័យមួយកម្រិត និងអរគុណដល់ធនាគារ អ៊ូរី ដែលបានជឿជាក់ និងបានផ្តល់ឱកាសដល់ពួកគាត់តាមរយៈការផ្តល់កម្ចីក្នុងការពង្រីកអាជីវកម្ម។ ពួកគាត់សង្ឃឹមថា នាពេលអនាគតតាមរយៈកម្ចីរបស់ធនាគារ អ៊ូរី និងជួយឱ្យគោលដៅរបស់គាត់ទទួលបានជោគជ័យ ក៏ដូចជាជួយដល់ការសិក្សារបស់កូនគាត់ឱ្យចប់ចុងចប់ដើមដែលនឹងធ្វើឱ្យកូនរបស់គាត់រស់នៅក្នុងជីវភាពមួយដែលល្អប្រសើរ។

ជាថ្មីម្តងទៀត អ្នកស្រីបានថ្លែងអំណរគុណដល់ធនាគារ អ៊ូរី ដែលបានជឿជាក់ និងផ្តល់ប្រាក់កម្ចី ក៏ដូចជាបាននាំយកនូវបច្ចេកវិទ្យាថ្មីនៃ ខេអេចឃ្យូអរ ស្កេន (KHQR Scan) សម្រាប់បម្រើដល់អតិថិជនក្នុងតំបន់របស់គាត់ឱ្យមានភាពយល់ដឹង និងមានភាពងាយស្រួលក្នុងការប្រើប្រាស់មួយកម្រិតទៀត។ ព្រមទាំងជូនពរធនាគារ អ៊ូរី ឱ្យទទួលបានការរីកចម្រើនឈានមុខគេក្នុងប្រទេសកម្ពុជាផងដែរ។


ផលិតផល
ហិរញ្ញវត្ថុ
និងសេវាកម្ម
ប្រាក់សន្សំ
ប្រាក់កម្ចី
សេវាធនាគារ
ផ្សេងៗទៀត
សេវាផ្ទេរប្រាក់
សេវាធនាគារ
ឌីជីថល
ATM
សេវាអេធីអឹម
និងប័ណ្ណឥណពន្ធ



ប្រាក់សន្សំ

គណនីសង្ឃឹម

គណនីសង្ឃឹម គឺជាប្រភេទគណនីសន្សំស្ម័គ្រចិត្ត ដែលបង្កើតសម្រាប់ សហគ្រិន បុគ្គលិកក្រុមហ៊ុន ស្ត្រីមេផ្ទះ ដែលមានបំណងដាក់ប្រាក់សន្សំ របស់ពួកគេ ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុមួយដែលគួរឱ្យជឿទុកចិត្ត និងមានសុវត្ថិភាពខ្ពស់។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ការដាក់ប្រាក់តម្កល់ដំបូង	20,000 រៀល
	5 ដុល្លារ
	200 បាត
រយៈពេល	មិនកំណត់

គណនីសន្សំផ្លឹស

គណនីសន្សំផ្លឹស គឺជាប្រភេទផលិតផលគណនីសន្សំ ថ្មីមួយទៀត របស់ធនាគារ អ៊ូរី ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជូនអតិថិជន នូវភាពបត់បែនក្នុងការដកប្រាក់ និងដាក់ប្រាក់ទៅតាមលំហូរសាច់ប្រាក់ជាមួយអត្រាការប្រាក់យ៉ាងទាក់ទាញទៅតាមទំហំទឹកប្រាក់របស់អតិថិជនផងដែរ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ការដាក់ប្រាក់តម្កល់ដំបូង	400,000 រៀល
	100 ដុល្លារ
	4,000 បាត
រយៈពេល	មិនកំណត់

គណនីចម្រើនទ្រព្យ

គណនីចម្រើនទ្រព្យ គឺជាប្រភេទគណនីសន្សំ ដែលទទួលបានអត្រាការប្រាក់ ខ្ពស់ និងមានលក្ខណៈជាកិច្ចសន្យាដែលតម្រូវឱ្យរក្សាទុកនូវសមតុល្យ គណនី ក្នុងរយៈពេលកំណត់ជាក់លាក់មួយរហូតដល់កាលបរិច្ឆេទកំណត់។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
សមតុល្យគណនីអប្បបរមា	100,000 រៀល
	25 ដុល្លារ
	1,000 បាត
រយៈពេល	1 ខែ ទៅ 36 ខែ

គណនីកូនល្អ

គណនីកូនល្អ គឺជាប្រភេទគណនីសន្សំមានកាលកំណត់ថ្មីមួយទៀត ដែលបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ឪពុកម្តាយ ឬសាច់ញាតិ ដែលមានបំណងសន្សំប្រាក់សម្រាប់កូនៗរបស់ពួកគេ ដែលមាន អាយុក្រោម 18ឆ្នាំ។

រូបិយប័ណ្ណ	រៀល, ដុល្លារ
ការដាក់ប្រាក់តម្កល់ដំបូង	20,000 រៀល
	5 ដុល្លារ
រយៈពេល	រហូតដល់កុមារមានអាយុ 18ឆ្នាំ

គណនីសប្បុរស

គណនីសប្បុរស គឺជាប្រភេទគណនីមានកាលកំណត់មួយទៀត ដែលមានរួមបញ្ចូលកម្មវិធីសប្បុរសធម៌ ឬកម្មវិធីជួយសង្គម។ តាមរយៈផលិតផលថ្មីនេះ អតិថិជនអាចជ្រើសរើសអង្គការសប្បុរសធម៌ដែលខ្លួនពេញចិត្តដើម្បីបរិច្ចាគ។ នៅថ្ងៃកាលបរិច្ឆេទកំណត់អតិថិជននឹងទទួលបានការប្រាក់គោល ហើយចំនួនទឹកប្រាក់ដែលត្រូវ បរិច្ចាគនឹងត្រូវបានកាត់ចេញពីការប្រាក់ដែលទទួលបាន រួចផ្ទេរទៅគណនីរបស់អង្គការសប្បុរសធម៌ដែលបានជ្រើសរើសដោយបង្ហាញឈ្មោះរបស់អតិថិជន។

រូបិយប័ណ្ណ	រៀល, ដុល្លារ
សមតុល្យគណនីអប្បបរមា	100,000 រៀល
	25 ដុល្លារ
រយៈពេល	3 ខែ ទៅ 12 ខែ

គណនីសន្សំតាមផែនការ


គណនីសន្សំតាមផែនការ គឺជាប្រភេទផលិតផលដាក់ប្រាក់បញ្ញើប្រចាំខែ ដែលតម្រូវឱ្យមានការដាក់ប្រាក់ចូលក្នុងគណនីនូវចំនួនស្មើៗគ្នាជារៀងរាល់ខែ។ គណនីនេះត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានចំណូលទៀងទាត់ និងមានបំណងជ្រើសរើសវិធីសាស្ត្រសន្សំបង្គរសម្រាប់ការវិនិយោគ ឬតម្រូវការអនាគតដូចជា វិនិយោគក្នុងអាជីវកម្ម ទិញសម្ភារៈ ឬផែនការចូលនិវត្តន៍ ជាដើម។


រូបិយប័ណ្ណ	រៀល, ដុល្លារ
ការដាក់ប្រាក់តម្កល់ដំបូង	40,000 រៀល
	10 ដុល្លារ
រយៈពេល	3 ខែ ទៅ 36 ខែ


គណនីសន្សំតាមផែនការ ផ្លឹស

គណនីសន្សំតាមផែនការ ផ្លឹស គឺជាប្រភេទផលិតផលដាក់ប្រាក់បញ្ញើប្រចាំខែថ្មីមួយទៀត ដែលមានភាពបត់បែនលើការដាក់ប្រាក់។ មានន័យថាអតិថិជនអាចដាក់ប្រាក់បន្ថែម លើចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងតារាង កាលវិភាគដាក់ប្រាក់សន្សំក្នុងអំឡុងពេលកិច្ចសន្យា។

រូបិយប័ណ្ណ	រៀល, ដុល្លារ
ការដាក់ប្រាក់តម្កល់ដំបូង	20,000 រៀល
	5 ដុល្លារ
រយៈពេល	3 ខែ ទៅ 36 ខែ









ប្រាក់កម្ចី

កម្ចីអាជីវកម្ម

កម្ចីអាជីវកម្ម គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ជាទុនបង្វិល ដើមទុនវិនិយោគសម្រាប់អាជីវកម្ម ការទិញទ្រព្យអាជីវកម្ម ការជួញដូរអាជីវកម្ម រួមបញ្ចូលទាំង ការជួញដូរផ្នែកកសិកម្ម និងប្រើប្រាស់ផងដែរ សម្រាប់សកម្មភាពរកប្រាក់ចំណូលដែលទទួលផលចំណូលជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ជារៀងរាល់ 2សប្តាហ៍ ឬ ប្រចាំខែ។

រូបិយប័ណ្ណ	រៀល ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 2,000,000,000 រៀល
	រហូតដល់ 500,000 ដុល្លារ
	រហូតដល់ 15,000,000 បាត
រយៈពេលកម្ចី	03 - 240 ខែ

កម្ចីកសិកម្ម

កម្ចីកសិកម្ម គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ការចំណាយលើវត្ថុធាតុដើម ទ្រព្យសកម្មនៃអាជីវកម្មកសិកម្ម ឬសកម្មភាពរកប្រាក់ចំណូលទាំងឡាយដែលទទួលផលចំណូលតាមរដូវកាល ដូចជា ការដាំដំណាំ ការចិញ្ចឹមសត្វ។ល។

រូបិយប័ណ្ណ	រៀល ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 200,000,000 រៀល
	រហូតដល់ 50,000 ដុល្លារ
	រហូតដល់ 400,000 បាត
រយៈពេលកម្ចី	03 - 72 ខែ

កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន

កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ទិញសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិគ្រួសារ ក៏ដូចជាផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ក្នុងគោលបំណងធ្វើឱ្យជីវភាពរស់នៅជាមូលដ្ឋានមានភាពល្អប្រសើរ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 200,000,000 រៀល
	រហូតដល់ 50,000 ដុល្លារ
	រហូតដល់ 400,000 បាត
រយៈពេលកម្ចី	03 - 72 ខែ

កម្ចីគេហដ្ឋាន

កម្ចីគេហដ្ឋាន គឺជាប្រភេទកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ទិញ/សាងសង់ផ្ទះថ្មី ឬ កែលម្អផ្ទះដែលមានស្រាប់ ឬ ពង្រីក និងជួសជុលផ្ទះដែលមានស្រាប់។ កម្ចីនេះ ក៏អាចប្រើប្រាស់សម្រាប់ការទិញដីដើម្បីសាងសង់ផ្ទះផងដែរ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 2,000,000,000 រៀល
	រហូតដល់ 500,000 ដុល្លារ
	រហូតដល់ 15,000,000 បាត
រយៈពេលកម្ចី	03 - 240 ខែ

កម្ចីការសិក្សា


កម្ចីការសិក្សា គឺជាប្រាក់កម្ចីផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលឬឪពុកម្តាយ/អាណាព្យាបាល ដែលមានបំណងចង់ឱ្យកូនបានរៀនសូត្រនូវកម្មវិធីសិក្សាអប់រំចំណេះដឹងទូទៅ ឬ សម្រាប់បន្តការអប់រំជាន់ខ្ពស់ ឬ សិក្សាជំនាញវិជ្ជាជីវៈ សម្រាប់ប្រកបរបរចិញ្ចឹមជីវិត។


រូបិយប័ណ្ណ	រៀល និងដុល្លារ
ទំហំកម្ចី	រហូតដល់ 20,000,000 រៀល
	រហូតដល់ 5,000 ដុល្លារ
រយៈពេលកម្ចី	កម្រិតសិក្សាអប់រំចំណេះដឹងទូទៅ ៖ 03 - 12 ខែ
	កម្រិតបរិញ្ញាបត្ររង ៖ 03 - 48 ខែ
	កម្រិតបរិញ្ញាបត្រ ៖ 03 - 84 ខែ
	កម្រិតអនុបណ្ឌិត ៖ 03 - 48 ខែ
	វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ៖ 03 - 24 ខែ

កម្ចីគ្រាអាសន្ន

កម្ចីគ្រាអាសន្ន ជាប្រភេទកម្ចីផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់ដើម្បីធានាបាននូវការឆ្លើយតបទាន់ពេលវេលា ទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជន នៅក្នុងពេលមានហេតុការណ៍បន្ទាន់ និង/ឬព្រឹត្តិការណ៍ដែលមិនអាចគិតទុកជាមុន ទាំងគ្រោះធម្មជាតិ ឬ គ្រោះថ្នាក់ផ្ទាល់ខ្លួន។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 4,000,000 រៀល
	រហូតដល់ 1,000 ដុល្លារ
	រហូតដល់ 40,000 បាត
រយៈពេលកម្ចី	03 - 24 ខែ





កម្ចីកូនកាត់ពិសេស

កម្ចីកូនកាត់ពិសេស គឺសំដៅទៅលើឥណទានដែលមានរបៀបបង់សងពិសេស ដែល50% នៃកម្ចីសរុប អាចរក្សាទុកបង់សងនៅចុងវគ្គ និង50%ទៀត ត្រូវបង់សងរំលស់ប្រាក់ដើមប្រចាំខែ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 400,000,000 រៀល
	រហូតដល់ 100,000 ដុល្លារ
	រហូតដល់ 400,000 បាត
រយៈពេលកម្ចី	រហូតដល់ 60 ខែ

កម្ចីសហគ្រាសខ្នាតតូច និងមធ្យម

ឥណទានសហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានទទួលស្គាល់ថាជាឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម។ ឥណទាននេះ ផ្តល់ជូនសម្រាប់អតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល / ក្រុមហ៊ុន / សហគ្រាស។

រូបិយប័ណ្ណ	រៀល និងដុល្លារ
ទំហំកម្ចី	ឥណទានទំហំធំ ដែលស័ក្តិសមនឹងគ្រប់ប្រភេទអាជីវកម្មទាំងអស់។
រយៈពេល	រហូតដល់ 120 ខែ។
អត្រាការប្រាក់ប្រចាំឆ្នាំ	អត្រាការប្រាក់ប្រកួតប្រជែង។
របៀបបង់សង	ជម្រើសនៃការបង់សងបត់បែន
ទ្រព្យធានាដែលអាចទទួលយកបាន	• គ្រប់ប្រភេទអចលនវត្ថុទាំងអស់ដែលមានទីតាំងគ្រប់កន្លែងក្នុងរាជធានីភ្នំពេញ និងគ្រប់បណ្តាខេត្ត/ក្រុង។ • គណនីមានកាលកំណត់របស់ធនាគារអ៊ូរី។ • ការធានាដោយភាគីទី3។ • បញ្ញធានាពីធនាគារ។

កម្ចីសាជីវកម្ម

ឥណទានសាជីវកម្ម គឺជាឥណទានដែលផ្តល់ឱ្យនីតិបុគ្គល/ក្រុមហ៊ុន/សហគ្រាសខ្នាតធំ ដែលត្រូវការហិរញ្ញវត្ថុដើម្បីទ្រទ្រង់ដល់ការចំណាយទូទាត់រយៈពេលខ្លី ឬដើមទុនទ្រទ្រង់ប្រតិបត្តិការអាជីវកម្ម និងការវិនិយោគ។

រូបិយប័ណ្ណ	រៀល និងដុល្លារ
ទំហំឥណទាន	ឥណទានទំហំធំ ដែលស័ក្តិសមនឹងគ្រប់ប្រភេទអាជីវកម្មទាំងអស់។
រយៈពេល	រហូតដល់ 120 ខែ។
អត្រាការប្រាក់ប្រចាំឆ្នាំ	អត្រាការប្រាក់ប្រកួតប្រជែង។
របៀបបង់សង	ជម្រើសនៃការបង់សងបត់បែន
ទ្រព្យធានាដែលអាចទទួលយកបាន	• គ្រប់ប្រភេទអចលនវត្ថុទាំងអស់ដែលមានទីតាំងគ្រប់កន្លែងក្នុងរាជធានីភ្នំពេញ និងគ្រប់បណ្តាខេត្ត/ក្រុង។ • គណនីមានកាលកំណត់របស់ធនាគារអ៊ូរី។ • ការធានាដោយភាគីទី3។ • បញ្ញធានាពីធនាគារ។



សេវាផ្ទេរប្រាក់

សេវាផ្ទេរប្រាក់អន្តរធនាគារ

សេវាផ្ទេរប្រាក់អន្តរធនាគារ (FAST) គឺជាប្រភេទសេវាផ្ទេរប្រាក់ដែលធ្វើប្រតិបត្តិការរវាងស្ថាប័នហិរញ្ញវត្ថុ (ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) ដើម្បីផ្តល់សេវា ដែលមានភាពងាយស្រួល និងទាន់ពេលវេលាដល់អតិថិជន ជាមួយនឹងគោលបំណងនៃការផ្ញើប្រាក់ទៅកាន់គណនីអ្នកទទួល។

ចំនួនទឹកប្រាក់ផ្ទេរ (ជាប្រាក់រៀល)	តម្លៃសេវា (ជាប្រាក់រៀល)
≤ 4 លាន	4,000
> 4 លាន ដល់ 20 លាន	8,000
> 20 លាន ដល់ 40 លាន	12,000

សេវាផ្ទេរប្រាក់ឆ្លងសាខា

សេវាផ្ទេរប្រាក់ឆ្លងសាខា គឺជាប្រភេទសេវាផ្ទេរប្រាក់ដែលអតិថិជនអាចប្រើដើម្បីផ្ទេរប្រាក់ពីសាខាមួយ ទៅសាខាមួយទៀតរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ។ អតិថិជនអាចធ្វើការផ្ទេរ ឬទទួលប្រាក់នៅសាខាតែមួយ ឬសាខាផ្សេងទៅតាមការស្នើសុំរបស់អតិថិជន។

ប្រភេទប្រតិបត្តិការ	ពីសាច់ប្រាក់ទៅសាច់ប្រាក់ ឬ ពីគណនីទៅសាច់ប្រាក់			សាច់ប្រាក់ទៅគណនី ឬ ពីគណនីទៅគណនី		
រូបិយប័ណ្ណ	រៀល	ដុល្លារ	ថៃបាត	រៀល	ដុល្លារ	ថៃបាត
អត្រាកម្រៃសេវា	0.10%	0.10%	0.10%	0.08%	0.08%	0.08%
កម្រៃសេវាអប្បបរមា	4,000	1	40	3,000	1	40

សេវាផ្ទេរប្រាក់អន្តរជាតិ

សេវាផ្ទេរប្រាក់ចូលពីក្រៅប្រទេស

ការទទួលប្រាក់ដែលផ្ទេរចូលមកក្នុងប្រទេសតាមរយៈធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានភាពឆាប់រហ័ស សុវត្ថិភាព និងមានភាពងាយស្រួល។ អតិថិជនដែលមានគណនីសន្សំជាមួយ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចទទួលបានទឹកប្រាក់ដែលផ្ទេរចូលមកក្នុងប្រទេស ជាមួយនឹងភាពងាយស្រួលបន្ថែមទៀតដែលអាចពិនិត្យមើលទឹកប្រាក់ដែលផ្ទេរចូល និងសមតុល្យទឹកប្រាក់ក្នុងគណនីតាមរយៈ កម្មវិធីធនាគារចល័តក្នុងទូរស័ព្ទដៃ ដែលផ្តល់ជូនដោយមិនគិតថ្លៃ ។

ប្រភេទព័ត៌មាន	ព័ត៌មានដែលត្រូវបំពេញ
រូបិយប័ណ្ណ	ដុល្លារអាមេរិក និងថៃបាត
អ្នកទទួល	តាមរយៈគណនីរបស់អ្នកទទួលនៅ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
ព័ត៌មានរបស់អ្នកទទួល	ឈ្មោះអ្នកទទួល, លេខគណនីអ្នកទទួល, អាសយដ្ឋានអ្នកទទួល, ឈ្មោះធនាគារអ្នកទទួល, អាសយដ្ឋានធនាគារអ្នកទទួល, និងSWIFT កូដនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក (HVBKKHPP)

កម្រៃសេវាផ្ទេរប្រាក់ចូល	
គ្រប់ទំហំទឹកប្រាក់នៃប្រតិបត្តិការ	0.07% នៃចំនួនទឹកប្រាក់ដែលទទួល ឬ អប្បបរមា USD10

សេវាផ្ទេរប្រាក់ក្រៅប្រទេស

ជាមួយវិសាលភាពនៃបណ្តាញធនាគារដ៏ធំធេងនៅជុំវិញ ពិភពលោករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អតិថិជនអាចផ្ទេរប្រាក់ទៅប្រទេសជាច្រើននៅលើពិភពលោកតាមរយៈប្រព័ន្ធ SWIFT ដែលជាប្រព័ន្ធសុវត្ថិភាពមួយដែលធនាគារលំដាប់ថ្នាក់ពិភពលោកបានប្រើប្រាស់ក្នុងការផ្ទេរប្រាក់ជាលក្ខណៈអន្តរជាតិ។ អតិថិជនអាចផ្ញើប្រាក់អោយក្រុមគ្រួសារ ទូទាត់ថ្លៃទំនិញ និងគោលបំណងផ្សេងទៀត នៅគ្រប់ ១៣៨ សាខារបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លក្ខណៈពិសេស	
រូបិយប័ណ្ណ	ដុល្លារអាមេរិក និងថៃបាត
អ្នកផ្ទេរ	អនុវត្តចំពោះអតិថិជនដែលមានគណនីជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក តែប៉ុណ្ណោះ
ពត៌មានរបស់អ្នកទទួល	ឈ្មោះអ្នកទទួលផល, លេខគណនីអ្នកទទួលផល, អាសយដ្ឋានអ្នកទទួលផល, ឈ្មោះធនាគារអ្នកទទួលផល, អាសយដ្ឋានធនាគារអ្នកទទួលផល, និងSWIFT កូដនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក (HVBKKHPP)

ថ្លៃសេវាផ្ទេរប្រាក់ចេញ			
ចំនួនទឹកប្រាក់ (ដុល្លារ)	Telex	Commission Fee	OUR (FULLPAYFEE)
តិចជាង ឬ ស្មើ $1,000	$10	$5	$20
ចាប់ពី $1,001 ដល់ $10,000	$10	$10	$20
ចាប់ពី $10,001	$10	0.15% នៃចំនួនទឹកប្រាក់សរុប (ទាបបំផុត $10)	$20



ផលិតផលហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានផ្តល់ជូនលោកអ្នកនូវសេវាកម្ម លិខិតឥណទាន, សេវាប្រមូលឯកសារ, លិខិតធានា, Standby Letter of Credit ក៏ដូចជា Advising, Negotiation ព្រមទាំងសេវាកម្មពាណិជ្ជកម្មអន្តរជាតិជាច្រើនទៀត។

លិខិតឥណទាន គឺជាប្រភេទផលិតផលមួយដែល ធនាគាររបស់អ្នកទិញទំនិញ(អ្នកនាំចូល) ទទួលខុសត្រូវលើការទូទាត់សងទៅកាន់អ្នកលក់ជំនួសមុខឱ្យអ្នកទិញទំនិញក្នុងករណីដែលប្រតិបត្តិការគោរពតាមគ្រប់លក្ខខណ្ឌនៃលិខិតឥណទាន។ ផលិតផលប្រភេទនេះគឺជាប្រភេទដែលមានសុវត្ថិភាពខ្ពស់បំផុតក្នុងការទូទាត់ និងពេញនិយមក្នុងការប្រើប្រាស់ជាងគេក្នុងវិស័យហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ។

សេវាប្រមូលឯកសារ គឺជាការទទួលខុសត្រូវមិនអាចកែប្រែបានរបស់ធនាគារចេញផ្សាយ (ហៅថាអ្នកធានា) លើការទូទាត់សងទៅកាន់អ្នកទទួលផលពីលិខិតធានា (ហៅថាអ្នកទទួលផល) ក្នុងករណីដែលអ្នកស្នើសុំមិនអាចបំពេញគ្រប់កាតព្វកិច្ច ឬ ក៏បំពេញបានត្រឹមតែផ្នែកខ្លះៗ។

លិខិតធានា គឺជារិធីសាស្ត្រមួយរបស់ហិរញ្ញវត្ថុពាណិជ្ជកម្ម នៅពេលដែលធនាគារអ្នកនាំចេញធ្វើ នូវឯកសារពាក់ព័ន្ធទៅកាន់ធនាគាររបស់អ្នកនាំចូល ហើយធ្វើការប្រមូលការទូទាត់ពីការដឹកទំនិញនោះ។ អ្នកទិញទំនិញអាចមានសិទ្ធិទទួលបានទំនិញ ក្នុងករណីដែលពួកគាត់បានទូទាត់ទំនិញរួច ឬក៏ឯកសារដែលពាក់ព័ន្ធត្រូវបានព្រមព្រៀងថាទូទាត់នៅក្នុងកាលបរិច្ឆេទណាមួយជាក់លាក់ ឬក៏លក្ខខណ្ឌណាមួយ។



សេវាធនាគារឌីជីថល

សេវាធនាគារចល័ត គឺជាការផ្តល់ជូននូវសេវាធនាគារ ឬសេវាហិរញ្ញវត្ថុមួយ ជាមួយនឹងជំនួយទូរគមនាគមន៍ចល័ត ដែលអនុញ្ញាតអោយអតិថិជនធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯងតាមរយៈឧបករណ៍ ចល័តរបស់អតិថិជន។

ការបន្ថែមមុខងារថ្មី

ដោយស្របតាមទីផ្សារប្រកួតប្រជែង ក៏ដូចជាបំពេញតម្រូវការអតិថិជន សេវាកម្មធនាគារចល័តត្រូវបានអភិវឌ្ឍន៍ឥតឈប់ឈរ។ មុខងារទាំងនោះមានដូចជា៖

#	មុខងារ	សេចក្តីរៀបរាប់ពីមុខងារ
1	បន្ថែមភាសាខ្មែរ	បន្ថែមពីលើភាសាអង់គ្លេសដែលមានស្រាប់នៅលើកម្មវិធីធនាគារចល័ត យើងអាចផ្លាស់ប្តូររវាងភាសាខ្មែរ និងអង់គ្លេសបានដោយខ្លួនឯង តាមតម្រូវការ។
2	អនុញ្ញាតអោយគណនីរួមអាចចុះឈ្មោះប្រើប្រាស់កម្មវិធីធនាគារចល័តបាន។	អនុញ្ញាតអោយអតិថិជនដែលមានគណនីរួមចុះឈ្មោះប្រើប្រាស់កម្មវិធីធនាគារចល័ត ក៏ដូចជាបន្ថែមគណនីរួមចូលទៅក្នុងគណនីធនាគារចល័តដែលមានស្រាប់។
3	មុខងារស្កេន KHQR	ធនាគារ អ៊ូរី បានបើកអោយមុខងារស្កេនរហ័ស អាចធ្វើការស្កេនទៅលើ KHQR ដើម្បីផ្ទេរ រីទូទាត់បានទាំងក្នុង និងឆ្លងធនាគារ រីស្ថាប័នហិរញ្ញវត្ថុ។
4	ការស្កេន QR ពីសាលរូបភាព	អនុញ្ញាតអោយអ្នកប្រើប្រាស់ ប្រើប្រាស់ QR ដែលបានរក្សាទុកក្នុងសាលរូបភាពដើម្បីស្កេនផ្ទេរប្រាក់ រីទូទាត់។
5	ការធ្វើសារអំពីព័ត៌មានប្រតិបត្តិការតាមរយៈ Telegram	អនុញ្ញាតអោយអ្នកប្រើប្រាស់កំណត់ ការធ្វើសារព័ត៌មានប្រតិបត្តិការតាមរយៈ Telegram
6	ការរចនាថ្មីរបស់កម្មវិធីធនាគារចល័ត	ធនាគារអ៊ូរី បានផ្តល់ជូនអតិថិជននូវរូបរាងថ្មីរបស់កម្មវិធីធនាគារចល័ត ដោយរួមមកជាមួយនូវការកែលម្អមួយចំនួនទៅលើបទពិសោធន៍អតិថិជនផងដែរ។

សេវាទូទាត់បាគង

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺជាសមាជិកក្នុងប្រព័ន្ធបាគង ហើយបច្ចុប្បន្ននេះ ធនាគារ អ៊ូរី បានបញ្ចូលកម្មវិធីបាគងចូលទៅក្នុង WOORI Bank Cambodia ដែលអតិថិជនអាចប្រើប្រាស់ គណនីបាគង នៅលើ WOORI Bank Cambodia ដោយភាពងាយស្រួល ។

អត្ថប្រយោជន៍នៃការប្រើប្រាស់បាគងនៅលើ WOORI Bank Cambodia

- ការចុះឈ្មោះគណនីបាគងតាមរយៈ WOORI Bank Cambodia
- ផ្ទេរ និងទទួលប្រាក់ភ្លាមៗ ប្រកបដោយសុវត្ថិភាព ពីគណនីសន្សំ ធនាគារ អ៊ូរី ទៅកាន់ គណនីរបស់សមាជិកនៃប្រព័ន្ធបាគងដោយឥតគិតថ្លៃសេវារហូតដល់ថ្ងៃ31 ខែធ្នូ ឆ្នាំ2022 លើ WOORI Bank Cambodia
- ការដាក់ប្រាក់ចូលគណនីធនាគាររបស់សមាជិកបាគង
- ការទូទាត់តាមរយៈ QR
- បង្កើតQRកូដថ្មី ក្នុងករណីបាត់លេខកូដសម្ងាត់ដើម្បីប្រើប្រាស់គណនីបាគងឡើងវិញ
- ការចូលប្រើគណនីបាគងចាស់ឡើងវិញលើ WOORI Bank Cambodia
- ពិនិត្យសមតុល្យគណនី និងប្រវត្តិប្រតិបត្តិការបាគងលើ WOORI Bank Cambodia
- ពិនិត្យព័ត៌មានគណនីបាគងរបស់អ្នកលើ WOORI Bank Cambodia

ការប្រើប្រាស់សេវាកម្ម តាមរយៈ WOORI Bank Cambodia

- ធ្វើប្រតិបត្តិការហិរញ្ញវត្ថុ៖ ផ្ញើ; ទទួល; ការដាក់ប្រាក់; ទូទាត់តាមរយៈ QR
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីចរន្ត ឬ គណនីសន្សំ របស់សមាជិកនៃប្រព័ន្ធបាគង
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីបាគង
- ការចុះឈ្មោះគណនីបាគង
- ការស្តារចូលប្រើគណនីបាគងឡើងវិញ
- ការសង្គ្រោះគណនីបាគង
- បង្កើតកូដសង្គ្រោះថ្មី QR
- មើលសមតុល្យគណនីនិងប្រវត្តិប្រតិបត្តិការបាគង
- មើលព័ត៌មានគណនីបាគង

តាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី

- ប្រតិបត្តិការដាក់សាច់ប្រាក់
- ប្រតិបត្តិការដកសាច់ប្រាក់
- ប្រតិបត្តិការផ្ទេរ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់ គណនីបាគង
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីចរន្ត ឬគណនីសន្សំ របស់សមាជិកនៃប្រព័ន្ធបាគង

សេវាផ្ទេរមូលនិធិភ្លាមៗ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានក្លាយជាសមាជិកនៃសេវាផ្ទេរមូលនិធិភ្លាមៗ (RFT)។ ឥឡូវនេះអតិថិជនរបស់ ធនាគារ អ៊ូរី ទាំងអស់អាចរីករាយប្រើប្រាស់ជាមួយសេវាកម្មផ្ទេរប្រាក់បន្ថែមថ្មីមួយទៀត ប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាព។

អត្ថប្រយោជន៍ដែលទទួលបាន

- អតិថិជនអាចផ្ទេរប្រាក់ទៅធនាគារផ្សេងៗ (ដែលជាសមាជិករបស់ RFT) ភ្លាមៗ
- អតិថិជនអាចផ្ទេរប្រាក់បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដោយប្រើប្រាស់ WOORI Bank Cambodia
- វាមានភាពរហ័ស សុវត្ថិភាព និងងាយស្រួលសម្រាប់អតិថិជនក្នុងការផ្ទេរប្រាក់ឆ្លងធនាគារ។

ការប្រើប្រាស់សេវាកម្មតាមរយៈ WOORI Bank Cambodia

- ផ្ទេរប្រាក់តាមគណនី
- ផ្ទេរប្រាក់តាមលេខទូរស័ព្ទ

តាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី

- ផ្ទេរប្រាក់តាមគណនី
- ការលុបចោលការផ្ទេរប្រាក់តាមគណនី
- ផ្ទេរប្រាក់តាមលេខទូរស័ព្ទ
- ការលុបចោលផ្ទេរប្រាក់តាមលេខទូរស័ព្ទ
- ការទូទាត់សម្រាប់ប្រតិបត្តិការផ្ទេរប្រាក់ពីគណនីទៅលេខទូរស័ព្ទ
- ការសាកសួរអំពីការផ្ទេរប្រាក់

សេវាកម្ម KHQR

KHQR ត្រូវបានបង្កើតឡើងសម្រាប់ការទូទាត់លក់រាយនៅកម្ពុជា និងការទូទាត់ឆ្លងប្រទេសក្នុងតំបន់អាស៊ាន។ វាទាមទារតែ QR តែមួយប៉ុណ្ណោះ សម្រាប់ការទទួលការទូទាត់ពីកម្មវិធីទូរស័ព្ទនានា រួមទាំងកម្មវិធី Bakong App ដែលធ្វើឱ្យការទូទាត់ QR កាន់តែសាមញ្ញសម្រាប់ទាំងអតិថិជន និងអាជីវករក្នុងប្រទេសកម្ពុជាដោយប្រើបណ្តាញទូទាត់បាគង។



ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានដាក់ដំណើរការសេវាកម្ម KHQR ជាផ្លូវការនៅថ្ងៃទី07 ខែកុម្ភៈ ឆ្នាំ 2022។ អតិថិជនរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចស្កេន KHQR ដើម្បីផ្ទេរប្រាក់ និងទូទាត់ដោយប្រើកម្មវិធី Woori Bank Cambodia កាន់តែមានសុវត្ថិភាពខ្ពស់ និងងាយស្រួល។ លើសពីនេះទៀត ពាណិជ្ជករ KHQR របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចទទួលយកការទូទាត់ពី Bakong Generic App និងកម្មវិធីទូរស័ព្ទចល័តធនាគារផ្សេងទៀតដែលគាំទ្រសេវា KHQR។

អត្ថប្រយោជន៍ KHQR

សម្រាប់អតិថិជន

- មិនមានការភាន់ច្រលំជាមួយQRកូដ ច្រើនទៀតទេនៅពេលធ្វើការទូទាត់។ ដោយគ្រាន់តែរកមើលស្លាកKHQR ។
- ការប្រើប្រាស់កម្មវិធីដែលអ្នកចូលចិត្តរួមទាំងកម្មវិធី Bakong ដើម្បីទូទាត់គ្រប់ទីកន្លែងដែលមានស្លាក KHQR ។

សម្រាប់ពាណិជ្ជករ

- ការសន្សំទំហំសម្រាប់បញ្ជរពាណិជ្ជករ ដោយគ្រាន់តែត្រូវបង្ហាញជំហរ KHQR តែមួយដើម្បីទទួលយកការទូទាត់ពីគ្រប់ធនាគារដែលសមាជិកបាគង។
- ដំណោះស្រាយនៃការទូទាត់យ៉ាងសាមញ្ញ រហ័ស និងសុវត្ថិភាព។

ប្រភេទប្រតិបត្តិការ KHQR

សម្រាប់អតិថិជន

ប្រភេទប្រតិបត្តិការ	ការពិពណ៌នា
ស្កេនសម្រាប់ការទូទាត់ទៅឱ្យពាណិជ្ជករ KHQR	អតិថិជនរបស់ Woori Bank Cambodia អាចស្កេន និងទូទាត់ប្រាក់ជាមួយពាណិជ្ជករ KHQR ទាំងពាណិជ្ជករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក និងពាណិជ្ជករសមាជិកផ្សេងទៀត។
ស្កេនសម្រាប់ការផ្ទេរប្រាក់ទៅឱ្យគណនីរបស់សមាជិក KHQR ឬ គណនីរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក	អតិថិជនរបស់ Woori Bank Cambodia អាចស្កេន និងផ្ទេរប្រាក់គណនីរបស់សមាជិក KHQR ឬ គណនីរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ **សម្គាល់៖** ប្រតិបត្តិការនេះគឺជោគជ័យ លុះត្រាតែធនាគារសមាជិក KHQR បើកសេវានេះ។
ទទួលការផ្ទេរប្រាក់ពីធនាគារសមាជិក KHQR ឬកម្មវិធីបាគង	អតិថិជនរបស់ របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចទទួលការផ្ទេរប្រាក់ពីធនាគារសមាជិក KHQR ឬកម្មវិធីបាគង ដោយគ្រាន់តែបង្ហាញ QR កូដពីកម្មវិធីទូរស័ព្ទ Woori Bank Cambodia ។ **សម្គាល់៖** ប្រតិបត្តិការនេះគឺជោគជ័យ លុះត្រាតែធនាគារសមាជិក KHQR បើកសេវានេះ។
ស្កេនសម្រាប់ការផ្ទេរប្រាក់ទៅឱ្យគណនីបាគង	អតិថិជនរបស់ Woori Bank Cambodia អាចស្កេន និងផ្ទេរប្រាក់គណនីបាគង។

សម្រាប់ពាណិជ្ជករ

ប្រភេទប្រតិបត្តិការ	ការពិពណ៌នា
ទទួលយកការទូទាត់តាមរយៈ KHQR កូដ	ពាណិជ្ជករ របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចទទួលយកការទូទាត់ពី Woori Bank Cambodia, កម្មវិធីទូរស័ព្ទបាគង និងកម្មវិធីទូរស័ព្ទរបស់ធនាគារផ្សេងទៀតដែលជាសមាជិកបាគង។



សេវាអេធីអឹម និងប័ណ្ណឥណពន្ធ

សេវាអេធីអឹម និងប័ណ្ណ បានត្រៀមខ្លួនរួចជាស្រេចដើម្បីបម្រើអតិថិជនជាមួយនឹងភាពងាយស្រួល ភាពបត់បែន និងសុវត្ថិភាពនៅទូទាំងតំបន់ក្នុងប្រទេសកម្ពុជា។ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក៏បានភ្ជាប់ប្រព័ន្ធអេធីអឹម របស់ខ្លួនដោយជោគជ័យទៅនឹងប្រព័ន្ធ Cambodian Shared Switch (CSS) ដែលត្រូវបានរៀបចំ និងគាំទ្រដោយធនាគារជាតិនៃកម្ពុជា។ សេវាកម្មអេធីអឹម និងប័ណ្ណបានផ្តល់នូវភាពបត់បែននឹងភាពងាយស្រួល សម្រាប់អតិថិជនដើម្បីធ្វើប្រតិបត្តិការលើម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក្ប សេវាកម្ម អេធីអឹម និង ម៉ាស៊ីនឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រពន្ធ័ Cambodian Shared Switch តាមតម្រូវការដោយមិនគិតពីពេលវេលា និងកន្លែង។ ធនាគារ អ៊ូរី (ខេមបូឌា) ម.កត្រៀមខ្លួនជាស្រេចដើម្បីគាំទ្រជាមួយនឹងមុខងារផ្សេងៗរួមទាំងប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅលើម៉ាស៊ីន អេធីអឹម និង ម៉ាស៊ីនឆូតកាត (POS) ដូចខាងក្រោម។

សេវាកម្មម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch (CSS)៖

#	ប្រភេទប្រតិបត្តិការ	ការពិពណ៌នា
1	ការដកប្រាក់	អតិថិជនអាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
2	ការពិនិត្យសមតុល្យភាព	អតិថិជនអាចធ្វើប្រតិបត្តិការពិនិត្យសមតុល្យភាព តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
3	របាយការណ៍សង្ខេប	អតិថិជនអាចធ្វើប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
4	ការប្តូរលេខសំងាត់	អតិថិជនអាចធ្វើប្រតិបត្តិការប្តូរលេខសំងាត់របស់ប័ណ្ណ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
5	ការផ្ទេរប្រាក់ក្នុងធនាគារតែមួយ	ការធ្វើប្រតិបត្តិការនេះ គឺអនុញ្ញាតសម្រាប់តែអតិថិជនរបស់ ធនាគារ អ៊ូរី តែប៉ុណ្ណោះ
6	ការផ្ទេរប្រាក់អន្តរធនាគារ	អតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់អន្តរធនាគារ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch

តាមរយៈសេវាកម្មរបស់ម៉ាស៊ីន POS ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch (CSS)៖

#	ប្រភេទប្រតិបត្តិការ	ការពិពណ៌នា
1	ការដកប្រាក់	អតិថិជនរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ តាមរយៈម៉ាស៊ីន ឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
2	ការពិនិត្យសមតុល្យភាព	អតិថិជនរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចធ្វើប្រតិបត្តិការពិនិត្យសមតុល្យភាព តាមរយៈម៉ាស៊ីនឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
3	ការទូទាត់	អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការទូទាត់ការទិញទំនិញ តាមរយៈម៉ាស៊ីនឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch



សេវាធនាគារផ្សេងៗទៀត

សេវាបើកប្រាក់បៀវត្សរ៍

សេវាបើកប្រាក់បៀវត្សរ៍ គឺជាផលិតផលមួយក្នុងចំណោមផលិតផលជាច្រើនទៀតរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ត្រូវបានរៀបចំឡើងដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនដែលជានិយោជក តាមរយៈប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការទូទាត់ដូចជា (ប្រាក់បៀវត្សរ៍ ប្រាក់លើកទឹកចិត្ត និងប្រាក់រង្វាន់ផ្សេងៗ) ដល់បុគ្គលិករបស់ពួកគេ។ សេវានេះនឹងត្រូវបានអនុវត្តដោយយោងតាមសំណើរបញ្ជាលើសេវាបើកប្រាក់បៀវត្សរ៍ ដែលត្រូវបាន ផ្តល់ដោយនិយោជក។

សេវានេះ នឹងអនុញ្ញាតឱ្យនិយោជកអាចធ្វើការទូទាត់ប្រាក់បៀវត្សរ៍ឱ្យបុគ្គលិករបស់ពួកគេ ដោយការផ្ទេរប្រាក់ចេញពីគណនីទូទាត់របស់ខ្លួនទៅកាន់គណនីបុគ្គលិកតាមរយៈ ធនាគារ អ៊ូរី ប្រកបដោយភាពងាយស្រួល រហ័ស និងសុវត្ថិភាព។ សេវា នេះក៏នឹងផ្តល់នូវឱកាស និងអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដល់បុគ្គលិករបស់ពួកគេ តាមរយៈការប្រើប្រាស់ផលិតផល និងសេវា ផ្សេងទៀតរបស់ ធនាគារ អ៊ូរី ដូចជាទទួលបានត្រាការប្រាក់ខ្ពស់ពីប្រាក់សន្សំ ទទួលបានសេវាអេធីអឹម សេវាធនាគារចល័តជាដើម។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
កម្រៃសេវា	1,000 រៀល
	0.25 ដុល្លារ
	7.5 បាត
សម្គាល់	និយោជិត និងនិយោជកត្រូវមានគណនីសន្សំជាមួយធនាគារ អ៊ូរី

សេវា ថេប ប៊ែងយីង

សេវា ថេប ប៊ែងយីង ត្រូវបានបង្កើតឡើងជាមធ្យោបាយមួយផ្សេងទៀតសម្រាប់ការបើកគណនី ដើម្បីផ្តល់សេវាបម្រើអតិថិជនកាន់តែប្រសើរ និងដើម្បីកាត់បន្ថយពេលវេលា និងការចំណាយសម្រាប់ការបើកគណនី។ ដំណើរការនេះអនុញ្ញាតឱ្យបុគ្គលិកទទួលបន្ទុករបស់ធនាគារ អ៊ូរី ធ្វើការចុះទៅបើកគណនីដល់ទីតាំងជូនអតិថិជន។

សេវាកម្មបំពេញសមតុល្យគណនីរបស់ភ្នាក់ងារ

សេវាកម្មបំពេញសមតុល្យគណនីរបស់ភ្នាក់ងារ គឺជាសេវាមួយរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលបង្កើតឡើងដើម្បីជួយសម្រួលដល់ភ្នាក់ងារដែលជាដៃគូរបស់ ធនាគារ អ៊ូរី ដើម្បីចាត់ចែង Wallet ឬគណនីរបស់ពួកគេ។ សេវាកម្មនេះអនុញ្ញាតឱ្យភ្នាក់ងារធ្វើប្រតិបត្តិការដាក់ប្រាក់ចូល និងដកប្រាក់ចេញពី Wallet ឬគណនីតាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី ឬមធ្យោបាយផ្សេងទៀតរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

រូបិយប័ណ្ណ	រៀល និងដុល្លារ
វិសាលភាពនៃសេវាកម្ម	1. ការដាក់ប្រាក់ចូល 1.1. ដាក់សាច់ប្រាក់ចូលគណនី Wallet របស់ភ្នាក់ងារ 1.2. ផ្ទេរប្រាក់ពីគណនីសង្ឃឹម ទៅគណនី Wallet របស់ភ្នាក់ងារ
	2. ការដកប្រាក់ចេញ 2.1. ដកសាច់ប្រាក់ចេញពីគណនី Wallet របស់ភ្នាក់ងារ
ដៃគូបច្ចុប្បន្ន	• Wing Money



របាយការណ៍
ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

	2022	2021	2020	2019	2018
សូចនាករលើការអនុវត្តផ្នែកបរិស្ថាន					
សម្ភារ					
ក្រដាស ប្រើគិតជាគីឡូក្រាម /FTE (1)	22.09	10.74	18.83	21.27	19.8
ទម្រង់ប្រាក់កម្ចី ប្រើគិតជាគីឡូក្រាម / FTE	5.77	3.18	5.1	5.25	5.77
ក្រដាសប្រើប្រាស់ក្នុងការិយាល័យ ប្រើគិតជាគីឡូក្រាម /FTE	16.32	7.56	13.73	16.03	14.03
សំណល់					
សំណល់ក្រដាស គិតជាគីឡូក្រាម / FTE	1.08	1.13	2.1	2.45	3.12
ក្រដាសជូតមាត់ ប្រើគិតជាគីឡូក្រាម	2,784.36	2,767.95	2,973.78	2,304.51	2,360.23
ក្រដាសជូតដៃ ប្រើគិតជាគីឡូក្រាម	284.95	329.79	1,162.64	938.35	809.2
ក្រដាសបង្គន់ ប្រើគិតជាគីឡូក្រាម	806.41	830.88	846.94	658.11	1,152.26
ថាមពល					
ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង/FTE	417.24	428.14	549.59	607.07	617
ប្រេងសាំង ប្រើគិតជាលីត្រ /FTE	310.48	244.47	264.92	259.51	222.81
ប្រេងសាំងសម្រាប់ទោចក្រយានយន្ត ប្រើគិតជាលីត្រ	1,093,318.46	844,931.15	627,846.08	411,685.15	306,716.76
ប្រេងសាំងសម្រាប់រថយន្ត ប្រើគិតជាលីត្រ	17,588.50	4,863.87	1,063.74	1,717.28	1,648.71
ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE	12.69	15.12	25.21	39.64	48.23
ប្រេងម៉ាស៊ូតសម្រាប់ម៉ាស៊ីនភ្លើង ប្រើគិតជាលីត្រ	4,706.32	2,717.90	6,185.40	5,820.91	2,294.04
ប្រេងម៉ាស៊ូតសម្រាប់រថយន្ត ប្រើគិតជាលីត្រ	40,698.08	49,855.94	53,656.07	57,327.37	64,451
ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE		N/A	N/A	N/A	N/A

	2022	2021	2020	2019	2018
ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)(2)					
ចរន្តអគ្គិសនី	821.09	818.51	717.6	531.88	469.66
ប្រេងសាំង	2,666.18	2,039.51	1,509.41	992.17	740.08
ប្រេងម៉ាស៊ូត	124.86	144.58	164.56	173.66	183.55
ទឹក					
ទឹក ប្រើគិតជាម៉ែត្រគូប /FTE	**0.78**	**6.02**	**10.43**	**12.9**	**14.25**
ទឹក ប្រើគិតជាម៉ែត្រគូប	17090.04	20,580.32	24,294.76	20,163.30	19413.06
ទឹកបរិសុទ្ធ ប្រើគិតជាម៉ែត្រគូប	2,800	339.2	465.81	391.43	304.74
ការធ្វើដំណើរ					
ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE	136.58	160.68	235.27	427.17	545
ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE	27,971.00	9,764.89	10,579.71	9,791.05	9,223.70
សូចនាករលើការអនុវត្តផ្នែកបរិស្ថាន					
ការបម្រើការងារ					
ចំនួនបុគ្គលិក	4,205	3,780	2,984	1,682	1,429
ស្រី	1,058	2,908	632	462	445
ប្រុស	3,147	872	2,352	1,220	984
ចំនួនបុគ្គលិក (FTE)	3,578	3,476	2,374	1,593	1,384

(1) FTE (Full Time Equivalent): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុងមួយឆ្នាំ។

(2) សមមូលឧស្ម័នកាបូនិកត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol។


បណ្តាញសាខា
និងតំបន់ប្រតិបត្តិការ

តំបន់ប្រតិបត្តិការ

រាជធានី/ខេត្ត **25**

បណ្តាញសាខា **138**

ការិយាល័យប្រចាំតំបន់ **18**



គិតត្រឹមខែ ធ្នូ ឆ្នាំ2022

- ខណ្ឌច្បារអំពៅ
- ខណ្ឌដង្កោ
- ខណ្ឌមានជ័យ
- ខណ្ឌសែនសុខ
- ខណ្ឌទួលគោក
- ខណ្ឌដូនពេញ
- ខណ្ឌ 7មករា
- ខណ្ឌពោធិ៍សែនជ័យ
- ខណ្ឌជ្រោយចង្វារ
- ខណ្ឌព្រែកព្នៅ
- ខណ្ឌឫស្សីកែវ
- ខណ្ឌចំការមន

VI

របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ 84
របាយការណ៍ចំណូលលម្អិត 85
របាយការណ៍បម្រែបម្រួលមូលធន 86
របាយការណ៍លំហូរសាច់ប្រាក់ 87
របាយការណ៍របស់សវនការឯករាជ្យ 88
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល 92

របាយការណ៍**ស្ថានភាពហិរញ្ញវត្ថុ**

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម				
សាច់ប្រាក់ក្នុងដៃ	**12,238,185**	**50,384,608**	11,469,663	46,727,407
សមតុល្យជាមួយធនាគារជាតិ	**99,548,079**	**409,839,441**	83,355,538	339,590,462
សមតុល្យជាមួយធនាគារផ្សេងៗ-សុទ្ធ	**131,434,362**	**541,115,268**	122,652,452	499,686,089
ឥណទានផ្តល់អតិថិជន-សុទ្ធ	**1,161,229,951**	**4,780,783,708**	918,491,190	3,741,933,108
វិនិយោគលើមូលបត្រ	**15,353**	**63,208**	15,353	62,548
ទ្រព្យសម្បត្តិ និងបរិក្ខារ-សុទ្ធ	**9,654,433**	**39,747,301**	5,785,138	23,568,652
ទ្រព្យសកម្មអរូបី-សុទ្ធ	**5,764,271**	**23,731,504**	3,753,609	15,292,203
សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម-សុទ្ធ	**12,774,005**	**52,590,579**	9,840,596	40,090,588
ពន្ធពន្យាលើទ្រព្យសកម្ម-សុទ្ធ	**4,924,172**	**20,272,816**	3,674,847	14,971,327
ទ្រព្យសកម្មផ្សេងៗ	**4,599,908**	**18,937,821**	3,422,105	13,941,656
ទ្រព្យសកម្មសរុប	**1,442,182,719**	**5,937,466,254**	1,162,460,491	4,735,864,040
មូលធន និងបំណុល មូលធន				
ដើមទុន	**175,895,100**	**703,580,400**	175,895,100	703,580,400
ទុនបម្រុងតាមបទប្បញ្ញត្តិ	**3,239,827**	**13,338,368**	4,534,996	18,475,574
ប្រាក់ចំណេញរក្សាទុក	**138,238,734**	**564,981,706**	90,640,446	368,725,334
ទុនបម្រុងបញ្ចូលគ្នា	**5,956,500**	**24,284,651**	5,956,500	24,284,651
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**24,965,148**	-	13,542,210
មូលធនសរុប	**323,330,161**	**1,331,150,273**	277,027,042	1,128,608,169
បំណុល				
ប្រាក់បញ្ញើរបស់អតិថិជន	**353,464,472**	**1,455,213,231**	217,455,161	885,912,326
បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន	**11,614,705**	**47,817,740**	11,664,774	47,522,289
ប្រាក់កម្ចី	**128,431,315**	**528,751,724**	100,308,125	408,655,301
សមតុល្យដែលជំពាក់ភាគីពាក់ព័ន្ធ	**606,374,329**	**2,496,443,112**	539,505,568	2,197,945,684
បំណុលភតិសន្យា	**12,652,171**	**52,088,988**	9,764,532	39,780,703
បំណុលផ្សេងៗ	**6,315,566**	**26,001,186**	6,735,289	27,439,568
បំណុលសរុប	**1,118,852,558**	**4,606,315,981**	885,433,449	3,607,255,871
មូលធន និងបំណុលសរុប	**1,442,182,719**	**5,937,466,254**	1,162,460,491	4,735,864,040

របាយការណ៍**ចំណូលលម្អិត**

	សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022		សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់	**175,863,989**	**718,756,123**	128,706,507	523,578,070
ចំណាយការប្រាក់	**(48,808,733)**	**(199,481,292)**	(22,773,077)	(92,640,877)
ចំណូលការប្រាក់សុទ្ធ	**127,055,256**	**519,274,831**	105,933,430	430,937,193
ចំណូលកម្រៃសេវា និងកម្រៃជើងសា-សុទ្ធ	**328,446**	**1,342,359**	15,219	61,911
ចំណូលផ្សេងៗ-សុទ្ធ	**1,812,297**	**7,406,858**	963,158	3,918,127
ចំណាយបុគ្គលិក	**(33,586,591)**	**(137,268,398)**	(29,089,757)	(118,337,131)
រំលស់ទ្រព្យសកម្មរូបី និងរំលស់ទ្រព្យសកម្មអរូបី	**(5,402,032)**	**(22,078,105)**	(3,827,607)	(15,570,701)
ចំណាយប្រតិបត្តិការផ្សេងៗ	**(15,847,542)**	**(64,768,904)**	(12,070,787)	(49,103,966)
ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធលើឧបករណ៍ហិរញ្ញវត្ថុ	**(16,180,923)**	**(66,131,432)**	(5,798,219)	(23,587,155)
ប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល	**58,178,911**	**237,777,209**	56,125,437	228,318,278
ចំណាយពន្ធលើប្រាក់ចំណូល	**(11,875,792)**	**(48,536,362)**	(11,331,042)	(46,094,679)
ប្រាក់ចំណេញសុទ្ធក្នុងការបរិច្ឆេទ	**46,303,119**	**189,240,847**	44,794,395	182,223,599
ចំណូលលម្អិតផ្សេងៗ				
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**11,422,938**	-	7,322,716
ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ	**46,303,119**	**200,663,785**	44,794,395	189,546,315

របាយការណ៍បម្រែបម្រួលមូលធន

	ដើមទុន	ទុនបម្រុងទិដ្ឋាន បទប្បញ្ញត្តិ	ចំណេញរក្សាទុក	ទុនបម្រុងរួមបញ្ចូលគ្នា	លម្អៀងពីការប្តូរប្រាក់បរទេស	មូលធនសរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ថ្ងៃទី01 ខែមករា ឆ្នាំ2022	175,895,100	4,534,996	90,640,446	5,956,500	13,542,210	277,027,042
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ	-	-	46,303,119	-	-	46,303,119
លម្អៀងពីការប្តូរប្រាក់បរទេស	-	-	-	-	11,422,938	-
ចំណូលលម្អិតសរុប	-	-	46,303,119	-	11,422,938	46,303,119
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	(1,295,169)	1,295,169	-	-	-
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022	**175,895,100**	**3,239,827**	**138,238,734**	**5,956,500**	**-**	**323,330,161**
សមមូលជាពាន់រៀល	**703,580,400**	**13,338,368**	**564,981,706**	**24,284,651**	**24,965,148**	**1,331,150,273**

	ដើមទុន	ទុនបម្រុងទិដ្ឋាន បទប្បញ្ញត្តិ	ចំណេញរក្សាទុក	ទុនបម្រុងរួមបញ្ចូលគ្នា	លម្អៀងពីការប្តូរប្រាក់បរទេស	មូលធនសរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ថ្ងៃទី01 ខែមករា ឆ្នាំ2021	175,895,100	3,344,256	47,036,791	5,956,500	6,219,494	232,232,647
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ	-	-	44,794,395	-	-	44,794,395
លម្អៀងពីការប្តូរប្រាក់បរទេស	-	-	-	-	7,322,716	-
ចំណូលលម្អិតសរុប	-	-	44,794,395	-	7,322,716	44,794,395
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	1,190,740	(1,190,740)	-	-	-
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021	**175,895,100**	**4,534,996**	**90,640,446**	**5,956,500**	**-**	**277,027,042**
សមមូលជាពាន់រៀល	**703,580,400**	**18,475,574**	**368,725,334**	**24,284,651**	**13,542,210**	**1,128,608,169**

របាយការណ៍លំហូរសាច់ប្រាក់

	សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022		សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ				
ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល	**58,178,911**	**237,777,209**	56,125,437	228,318,278
និយ័តកម្មសម្រាប់៖				
ចំណាយការប្រាក់	**48,808,733**	**199,481,292**	22,773,077	92,640,877
ការខាតបង់លើឱនភាពតម្លៃសុទ្ធលើឧបករណ៍				
ហិរញ្ញវត្ថុ	**16,180,923**	**66,131,432**	5,798,219	23,587,155
រំលស់លើទ្រព្យរូបី និងរំលស់លើទ្រព្យអរូបី	**5,402,032**	**22,078,105**	3,827,607	15,570,701
ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ	**6,442**	**26,328**	1,169	4,755
ចំណូលការប្រាក់	**(175,863,989)**	**(718,756,123)**	(128,706,507)	(523,578,070)
លម្អៀងពីកាប្តូររូបិយប័ណ្ណបរទេស	**(92,710)**	**(378,906)**	(22,218)	(90,383)
ការជម្រះបញ្ជីលើទ្រព្យសកម្មអរូបី	**443,359**	**1,812,008**	-	-
ខាតបង់ប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល	**(46,936,299)**	**(191,828,655)**	(40,203,216)	(163,546,687)
បម្រែបម្រួលទុនបង្វិល បម្រែបម្រួលសុទ្ធក្នុង៖				
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	**(16,977,969)**	**(69,388,959)**	(40,028,641)	(162,836,512)
ឥណទានផ្តល់ជូនអតិថិជន	**(255,490,580)**	**(1,044,190,000)**	(305,498,343)	(1,242,767,259)
ទ្រព្យសកម្មផ្សេងៗ	**(1,177,803)**	**(4,849,015)**	1,559,731	6,344,989
ប្រាក់បញ្ញើសន្សំពីអតិថិជន	**131,403,976**	**537,048,050**	91,118,877	370,671,592
បំណុលផ្សេងៗ	**(3,288,485)**	**(13,440,038)**	857,052	3,486,488
សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ	**(192,467,160)**	**(786,648,618)**	(292,194,540)	(1,188,647,389)
ការប្រាក់ដែលបានទទួល	**171,798,165**	**702,139,100**	125,129,429	509,026,517
ការប្រាក់បានបង់	**(40,360,673)**	**(164,954,071)**	(19,150,331)	(77,903,547)
ពន្ធលើប្រាក់ចំណូលបានទូទាត់	**(13,175,186)**	**(53,846,985)**	(7,616,297)	(30,983,096)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ	**(74,204,854)**	**(303,310,574)**	(193,831,739)	(788,507,515)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ				
សាច់ប្រាក់បានទទួលពីការលក់ទ្រព្យសម្បត្តិ និង បរិក្ខារ	**398,174**	**1,627,337**	386	1,570
ទិញទ្រព្យសកម្មអរូបី	**(3,141,560)**	**(12,839,556)**	(2,359,152)	(9,597,030)
ទិញទ្រព្យសម្បត្តិ និងបរិក្ខារ	**(6,085,493)**	**(24,871,410)**	(3,288,697)	(13,378,419)
ការបន្ថែមទៅប្រាក់បញ្ញើមានកាលកំណត់	**(10,071,623)**	**(41,162,723)**	(49,809,350)	(202,624,436)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ	**(18,900,502)**	**(77,246,352)**	(55,456,813)	(225,598,315)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ				
សាច់ប្រាក់បានទទួលពីប្រាក់កម្ចី	**104,930,775**	**428,852,077**	95,238,095	387,428,570
ការទូទាត់សងប្រាក់កម្ចី	**(76,525,410)**	**(312,759,351)**	(71,168,539)	(289,513,617)
សាច់ប្រាក់បានទទួលពីសមតុល្យជំពាក់ ភាគី ពាក់ព័ន្ធ	**252,500,000**	**1,031,967,500**	468,700,000	1,906,671,600
ការទូទាត់សងលើសមតុល្យជំពាក់ភាគីពាក់ព័ន្ធ	**(185,631,239)**	**(758,674,874)**	(253,529,633)	(1,031,358,547)
ការទូទាត់បំណុលភតិសន្យា	**(3,462,767)**	**(14,152,329)**	(2,691,487)	(10,948,969)
សាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញវត្ថុ	**91,811,359**	**375,233,023**	236,548,436	962,279,037
បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូល សុទ្ធ	**(1,293,997)**	**(5,323,903)**	(12,740,116)	(51,826,793)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលចាប់ផ្តើម ការិយបរិច្ឆេទ	**45,899,069**	**186,992,808**	58,639,185	237,195,502
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	1,970,177	-	1,624,098
សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុង ការិយបរិច្ឆេទ	**44,605,072**	**183,639,082**	45,899,069	186,992,808

របាយការណ៍
របស់សវនករឯករាជ្យ

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត

ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង (កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

ជូនចំពោះភាគហ៊ុននិករបស់

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា“ធនាគារ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ព្រមជាមួយសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត លើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (”CIFRSs”) ព្រមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា។

មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”) ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីធនាគារ ដោយអនុលោមតាមក្រមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) (“IESBA Code”) រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវទាំងស្រុងទៅលើការរៀបចំព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានផ្តល់ជូនយើងខ្ញុំមុនកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំ ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថាបានរៀបចំរួចរាល់ សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ ហើយយើងខ្ញុំមិនផ្តល់ការធានា ឬសេចក្តីសន្និដ្ឋានក្នុងទម្រង់បែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើ ផ្អែកតាមការងារដែលយើងធ្វើសវនកម្ម យើងខ្ញុំសន្មតថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ ទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (”CIFRSs”) និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ កំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពធនាគារក្នុងការបន្តប្រតិបត្តិដោយផ្អែកលើមូលដ្ឋាននិរន្តរភាពការលាតត្រដាងប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងត្រួតពិនិត្យព្រមទាំងអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់

យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”) នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើង។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្នែកមួយនៃជាការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”) យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈភាគុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាល មកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនា ដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាល:ទេស: ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។
- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណ:គ្រប់គ្រង។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណ:គ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជា ជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនច្បាស់លាស់ជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញ របាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាច បណ្តាលឱ្យធនាគារមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំទាក់ទងជាមួយអ្នកទទួលបន្ទុកអភិបាលកិច្ចពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ ដូចជាការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្ម រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុងដែលបានរកឃើញនៅក្នុងកំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី



Grant Thornton
ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

របាយការណ៍
របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល (“អភិបាល”) សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា “ធនាគារ”) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់សេវាកម្ម និងផលិតផលហិរញ្ញវត្ថុដូចជាប្រាក់បញ្ញើ ឥណទាន រួមទាំងសេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស សេវាធនាគារចល័ត សេវាទូទាត់ប្រាក់ ការធានាពីធនាគារ សេវាកម្មម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ លិខិតធានាធនាគារ និងសេវាកម្មធនាគារផ្សេងៗទៀតដែលផ្តល់សេវាជូនប្រជាជនកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជា។

លទ្ធផលហិរញ្ញវត្ថុ

ការអនុវត្តសវនកម្មហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គឺត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណូលលម្អិត នៅទំព័រទី១១ ក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានអមមកជាមួយ។

ទុនបម្រុង និងសំវិធានធន

ពុំមានបម្រែបម្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទឡើយ លើកលែងតែបម្រែបម្រួលដែលត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ភាគលាភ

ពុំមានភាគលាភបានប្រកាស ឬបានបង់នៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ (ឆ្នាំ២០២១៖ មិនមាន)។

ដើមទុន

ដើមទុនដែលបានបង់របស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានសមតុល្យ ១៧៥.៨៩៥.១០០ ដុល្លារអាមេរិក ឬប្រហែលនឹង ៧០៣.៥៨០ លានរៀល (ឆ្នាំ២០២១៖ ១៧៥.៨៩៥.១០០ ដុល្លារអាមេរិក ឬប្រហែលនឹង ៧០៣.៥៨០ លានរៀល)។

ឥណទានអាក្រក់ និងជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការសមស្រប ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធនឹងការលុបចេញពីបញ្ជីនូវឥណទានអាក្រក់ ឬការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថារាល់ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី និងបានធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងច្បាស់លាស់បំផុត អភិបាលពុំបានយល់ដឹងពីស្ថានការណ៍ណាមួយដែលធ្វើឱ្យមានការជម្រះបញ្ជីលើឥណទានអាក្រក់ និងបុរេប្រទាន ព្រមទាំងសំវិធានធននៃសមតុល្យសាច់ប្រាក់របស់បំណុលអាក្រក់ និងឥណទានជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលមានភាពខ្វះខាតជាសារវន្តនោះទេ។

ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការសមស្រប ដើម្បីឈានដល់ការអះអាងថា បណ្តាទ្រព្យសកម្មដែលទំនងជាមិនអាចទទួលស្គាល់ក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយតម្លៃនៅត្រឹមតម្លៃដែលគេរំពឹងទុកថាអាចទទួលយកបាន។

នាកាលបរិច្ឆេទនៃរបាយកាណ៍នេះ អភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពពុំត្រឹមត្រូវជាសារវន្តនោះទេ។

វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក). ពុំមានការដាក់បន្ទុកលើទ្រព្យសកម្មណាមួយរបស់ធនាគារ លើការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទដែលបានបញ្ចប់មក លើកលែងតែបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(ខ). ពុំមានបំណុលយថាហេតុណាមួយ បានកើតមានឡើងចំពោះធនាគារតាំងពីចុងការិយបរិច្ឆេទ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារនោះទេ។

ផ្អែកតាមមតិយោបល់របស់អភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ធនាគារដែលត្រូវបានទាមទារឱ្យសងក្នុងអំឡុងការិយបរិច្ឆេទ ១២ ខែនេះបន្ទាប់ពីចុងការិយបរិច្ឆេទ ថាអាចនឹងមាន ឬអាចមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលនោះដល់កាលកំណត់សងឡើយ។

ការប្រែប្រួលនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ លើកលែងតែហេតុការណ៍ ដែលបានលើកឡើងនៅក្នុងរបាយកាណ៍នេះ ឬក៏របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្តាលឱ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហរិញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

សមាសធាតុមិនប្រក្រតី

ផ្អែកតាមមតិយោបល់របស់អភិបាល លទ្ធផលនៃប្រតិបត្តិការប្រចាំឆ្នាំរបស់ធនាគារ មិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ពីសមាសធាតុណាមួយ ឬប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយមានលក្ខណៈមិនប្រក្រតីនោះទេ។

ផ្អែកតាមទស្សនៈរបស់អភិបាល នៅចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះពុំមានសមាសធាតុណាមួយ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ធនាគារបានទទួលការអនុម័តជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ ធនាគារទទួលបានការអនុម័តជាផ្លូវការពីក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មក្រោមឈ្មោះ “ធនាគារ អ៊ូរី (ខេមបូឌា) ម.ក”។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ក៏បានអនុម័តក្នុងការផ្ទេរហ៊ុនចំនួន ១ហ៊ុនពីធនាគារ Woori Bank Korea ទៅឱ្យ លោក Hong Ju Kim ដែលជាជនជាតិកូរ៉េ។ ធនាគារបានប្រកាសជាផ្លូវការ និងបានចាប់ផ្តើមធ្វើប្រតិបត្តិការក្នុងនាមជាធនាគារពាណិជ្ជសាធារណៈជាផ្លូវការនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២។

ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទនៃរបាយការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់ណាមួយកើតឡើងបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះឡើយ ដែលតម្រូវឱ្យមានការកែតម្រូវ ឬការលាតត្រដាង ក្រៅពីការលាតត្រដាងដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលកាន់តំណែងក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចជា៖

ឈ្មោះ	មុខតំណែង	កាលបរិច្ឆេទតែងតាំង ឬកាលបរិច្ឆេទលាឈប់
លោក Hyun Seong Yoon	ប្រធានក្រុមប្រឹក្សាភិបាល	តែងតាំងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ និងបានលាឈប់នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២
លោក Sung Wook Jung	ប្រធានក្រុមប្រឹក្សាភិបាល	តែងតាំងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២
លោក Sun Kyu Kim	សមាជិក និងនាយកប្រតិបត្តិ	តែងតាំងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងបានលាឈប់នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២២
លោកស្រី Fiona Michelle Whyte	សមាជិក	តែងតាំងនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣
លោក Ky Buntrean	សមាជិក	តែងតាំងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
លោក Kwang Hui Ku	សមាជិក និងនាយកផ្នែកហិរញ្ញវត្ថុ	តែងតាំងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២
លោក Hong Ju Kim	សមាជិក និងនាយកប្រតិបត្តិ	តែងតាំងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ជាអភិបាលដោយទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ មានប្រសិទ្ធភាពនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២

ភាគកម្មរបស់អភិបាល

អភិបាលមួយរូបក្នុងចំណោមក្រុមប្រឹក្សាភិបាល គឺលោក Hong Ju Kim បានកាន់កាប់ភាគហ៊ុនចំនួន ១ ហ៊ុននៃមូលធនសរុបរបស់ធនាគារ។ ពុំមានការរៀបចំដែលកើតឡើងដែលមានធនាគារជាភាគីមួយ ក្នុងគោលបំណងធ្វើឱ្យអភិបាលទទួលបានផលប្រយោជន៍នៅក្នុងធនាគារ ឬអង្គភាពសាជីវកម្មណាមួយឡើយ។

អត្ថប្រយោជន៍របស់អភិបាល

ក្នុងអំឡុង និងចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងជួយដល់សមាជិកអភិបាលធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ។

ចាប់តាំងពីចុងកាលបរិច្ឆេទមុន ពុំមានអភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលរួមបញ្ចូលក្នុងសមតុល្យសរុបដែលបានទទួល ឬដល់កាលកំណត់ និងត្រូវទទួលដោយអភិបាល ដូចបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធជាមួយនឹងធនាគារដែលមានសមាជិកអភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារដែលសមាជិកអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលនូវបានបង្ហាញនូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ គណៈគ្រប់គ្រងតម្រូវឱ្យ៖

- អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព
- អនុវត្តតាមការតម្រូវនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”) ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវភាពទិដ្ឋភាពពិត និងត្រឹមត្រូវហើយធានាឱ្យបានថាការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋានបន្តនិរន្តរភាព លើកលែងតែវាមានភាពមិនសមស្របក្នុងការសន្មតថាធនាគារអាចបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត
- ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចជាសារវន្តទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង
- ថែរក្សាទ្រព្យសម្បត្តិរបស់ធនាគារ ហើយចាត់វិធានការឱ្យបានសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញពីការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការរៀបចំ ហើយក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការអនុម័តចុងក្រោយទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលគណៈគ្រប់គ្រងបានកំណត់ថាវាសមស្របនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានកំហុសឆ្គងជាសារវន្ត មិនថាកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងនោះទេ។

ការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
WOORI BANK (CAMBODIA) PLC.
KINGDOM OF CAMBODIA

លោក Hong Ju Kim
សមាជិកក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

2022

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

អគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់ចឹងកេងកង1 ខណ្ឌចឹងកេងកង រាជធានីភ្នំពេញ
www.wooribank.com.kh
info@wooribank.com.kh
(+855) 23 963 333 | 81 331 333